សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ដំណើរការវិនិយោគលើផ្សារមូលបត្រកម្ពុជា និងការប្រឈមនឹងហានិភ័យ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបរៀងដោយ
និស្សិតឈ្មោះ ប៊ុន អ៊ីសែ

សាស្ត្រាចារ្យណែនាំ
លោកស្រី ឡុង ម៉ាមីឌី

ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច
ជំនាន់ទី ៦

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ប៊ុន អ៊ីសែ ជានិស្សិតថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំទី៤ ជំនាន់ទី៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២១-២០២២ ដែលបានធ្វើសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី៖ ការវិនិយោគលើទីផ្សារមូលបត្រ និងការប្រឈមនឹងហានិភ័យ ។

ជាដំបូងព្រះករុណាយើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលជាអ្នកមានគុណដ៏ធំធេងគ្មានអ្វីប្រៀបប្រដូចបាន ក៏ជាព្រះរស់ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅ និងចាំជួយគាំទ្រាំគ្រប់ពេលនៅពេលកូនជួបប្រទះបញ្ហាផ្សេងៗ។ តាំងពីតូចដល់ធំលោកតែងតែអប់រំកូនឲ្យដើរតាមកន្លងធម៌ និងប្រកបដោយព្រហ្មវិហារធម៌ទាំង៤ប្រការ។ ទន្ទឹមនឹងនេះលោកមិនដែលភ្លេចឡើយពាក់ព័ន្ធនឹងការសិក្សាចំណេះវិជ្ជា ចំណេះជំនាញ ផ្សេងៗ ដោយខ្លាចកូនអវិជ្ជា ហេតុនេះហើយលោកទាំងពីរបានខិតខំរកប្រាក់មកផ្គត់ផ្គង់កូនតាំងពីថ្នាក់ទី១ រហូតដល់កម្រិតឧត្តមសិក្សាឆ្នាំទី៤នេះ។

**ឯឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់ជាចំណេះដឹង និងដំបូន្មានល្អៗ ព្រមទាំងចែករំលែកនូវបទពិសោធន៍ដ៏មានតម្លៃទាំងក្នុងការសិក្សាដល់យើងខ្ញុំក្នុងការក្លាយជាពលរដ្ឋល្អ និងជាសសរទ្រូងរបស់ប្រទេសជាតិនាថ្ងៃអនាគតផងដែរ ។

ជាពិសេស យើងខ្ញុំសូមធ្វើការថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ**អ្នកគ្រូសាស្រ្តាចារ្យ ឡុង ម៉ាមីឌី** ដែលជាសាស្រ្តាចារ្យណែនាំ និងដឹកនាំសរសេរសារណាបញ្ចប់ការសិក្សានេះ និងផ្តល់យោបល់ល្អៗដើម្បីជាជំនួយនៅក្នុងការសរសេរសារណានេះ ម៉្យាងវិញទៀតអ្នកគ្រូសាស្រ្តាចារ្យក៏បានកែលម្អនូវរាល់ចំណុចខ្វះខាតទាំងឡាយ ដើម្បីឲ្យអត្ថបទស្រាវជ្រាវនេះមានខ្លឹមសារគ្រប់គ្រាន់ និងអាចយកទៅប្រើប្រាស់បាន។

មិនត្រឹមតែប៉ុណ្ណោះយើងខ្ញុំក៏សូមអរគុណដល់ **និស្សិតរៀមច្បង** ដែលបានបន្សល់ទុកស្នាដៃសម្រាប់ធ្វើជាគំរូដល់យើងខ្ញុំ និង**មិត្តរួមជំនាន់ទាំងអស់** ដែលបានជួយជាមតិយោបល់តាំងពីពេលចាប់ផ្តើមរហូតដល់ចប់ជាស្ថាពរលើអត្ថបទមួយនេះក្នុងបំណងជួយធ្វើឲ្យអត្ថបទមួយនេះកាន់តែប្រសើរ និងមានគុណភាព ។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនដល់លោកអ្នកមានគុណទាំងទ្វារ ឯឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និស្សិតរៀមច្បង និងមិត្តរួមជំនាន់ទាំងអស់ ជាពិសេស**អ្នកគ្រូសាស្រ្តាចារ្យ ឡុង ម៉ាមីឌី** ឲ្យមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត និងទទួលបាននូវពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ទីផ្សារមូលបត្រ ជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុដែលប្រតិបត្តិការរបស់វាគឺ ប្រមូលនូវប្រភពមូលធនសន្សំមួយចំណែកតូចក្នុងសង្គម ឱ្យក្លាយទៅជាប្រភពមូលធនដ៏ធំសម្រាប់រយៈពេលវែងដល់សហគ្រាស ស្ថាប័នឯកជន និងស្ថាប័នរដ្ឋ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍផលិតកម្ម សេដ្ឋកិច្ច និងគម្រោងវិនិយោគផងដែរ។ ដោយហេតុនេះហើយ យើងខ្ញុំសង្កេតឃើញថា វិស័យមូលបត្រកម្ពុជាដែលកំពុងមានវត្តមានក្នុងប្រទេសកម្ពុជាយើងត្រូវបានទទួលការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់មហាជន ជាពិសេសវិនិយោគិនគ្រប់លំដាប់ថ្នាក់។ ស្របពេលជាមួយគ្នានេះដែរ ក៏មានប្រជាជនមួយចំនួនពុំទាន់មានការយល់ដឹងពីវិស័យនេះបានច្បាស់នៅឡើយទេ។

ដូចដែលបានរៀបរាប់ខាងលើ យើងខ្ញុំជានិស្សិតបរិញ្ញាបត្រគ្រប់គ្រងធុរកិច្ចដែលត្រៀមនឹងបញ្ចប់ការសិក្សា ទទួលបានឱកាសក្នុងការរៀបចំសរសេរសារណាមួយច្បាប់នេះឡើងក្រោមប្រធានបទ “ការវិនិយោគលើទីផ្សារមូលបត្រ” ដើម្បីជាផ្នែកមួយជួយដល់ការចែករំលែកចំណេះដឹងសម្រាប់មិត្តអ្នកអាន សិស្សនិស្សិតដែលមានបំណងចង់យល់ដឹងបន្ថែមពីអំពីផ្សារមូលបត្រនៅប្រទេសកម្ពុជាយើង។ នៅក្នុងសៀវភៅនេះយើងខ្ញុំនឹងធ្វើការសិក្សាទៅលើទីផ្សារមូលបត្រកម្ពុជានៅចំណុចមួយចំនួនដូចជា ប្រវត្តិទាក់ទងនឹងការបង្កើតផ្សារមូលបត្រ-កម្ពុជា ដំណើរការនៅក្នុងផ្សារមូលបត្រ និងបញ្ហាប្រឈមក្នុងវិស័យមូលបត្រកម្ពុជា។ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សានេះ អាចចូលរួមចំណែកជួយដល់ការលើកស្ទួយវិស័យមូលបត្រនៅកម្ពុជា និងជាឯកសារជំនួយដល់ការស្វែងយល់បន្ថែមដល់មិត្តអ្នកអានទាំងឡាយ។ យើងខ្ញុំធ្វើការស្រាវជ្រាវលើប្រធានបទក្នុងគោលបំណងផ្តល់ចំណេះដឹងបន្ថែមដល់ជនទាំងឡាយណាដែលមានបំណងចង់ដឹងពីផ្សារមូលបត្រកម្ពុជាយើងតែប៉ុណ្ណោះ យើងខ្ញុំមិនមានបំណងណែនាំ ឬផ្តល់ជាគំនិតទៅលើការវិនិយោគអ្វីមួយឡើយ។

យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវគឺតែងតែកើតមានកំហុសដោយអចេតនាណាមួយជាមិនខានឡើយ។ អាស្រ័យហេតុនេះហើយ យើងខ្ញុំក៏សូមអភ័យទោសនូវរាល់កំហុសឆ្គងដែលកើតមានឡើង និងមានចំណុចខ្វះខាតណាមួយដែលកើតឡើងក្នុងឯកសារស្រាវជ្រាវនេះ។

យើងខ្ញុំនឹងស្វាគមន៍នូវរាល់មតិរិះគន់ទាំងឡាយក្នុងន័យស្ថាបនា និងកែលម្អនូវចំណុចខ្វះខាតពីសំណាក់លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងអ្នកអានគ្រប់ៗគ្នាដើម្បីធ្វើឲ្យឯកសារស្រាវជ្រាវនេះមានលក្ខណៈគ្រប់គ្រាន់ និងសំរួលដល់ភាពមិនច្បាស់ទាំងឡាយផងដែរ។

# មាតិកា

ទំព័រ

បញ្ជីតារាង........................................................................................................v
បញ្ជីរូបភាព........................................................................................................vi

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................1
២. ចំណោទបញ្ហានៃការស្រាវជ្រាវ........................................................................3
៣. គោលបំណងនៃការស្រាវជ្រាវ........................................................................3
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ........................................................................3
៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................4
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ........................................................................4
៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ........................................................................6

## ជំពូកទី១
## រំលឹកទ្រឹស្តីនៃការវិនិយោគ

១.១. និយមន័យទូទៅ........................................................................7
១.១.១. ការវិនិយោគពិត (Real Investment)........................................................................7
១.១.២. ការវិនិយោគហិរញ្ញវត្ថុ (Financial Investment)........................................................................8
១.១.២.១. ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចជួញដូរបាន (Non-Marketable Financial Assets)............8
ក. ការដាក់ប្រាក់បញ្ញើ (Saving account or deposit)........................................................................8
ខ. ការដាក់ប្រាក់បញ្ញើមានកាលកំណត់ (Fixed account)........................................................................9
គ. មូលបត្រទីផ្សាររូបិយវត្ថុ (Money Market Instrument)........................................................................9
១.១.២.២. ទ្រព្យសកម្មហិរញ្ញវត្ថុអាចជួញដូរបាន (Marketable Financial Asset)........................10
ក. ភាគហ៊ុន (Stock)........................................................................10
ខ. មូលបត្រចំណូលថេរ (Fixed income securities)........................................................................11

គ. មូលនិធិសង្គហ ឬមូលនិធិរួម (Mutual funds) 12
ឃ. មូលបត្រដេរីវេទីវ ឬនិស្សន្ទ (Derivative securities) 13
១.២. ការទិញ និងលក់មូលបត្រ 14
១.២.១. ក្រុមហ៊ុនជើងសារ (Broker) 14
១.២.២. ការបើកគណនីក្រុមហ៊ុនជើងសារ 15
១.៣. មូលដ្ឋាននៃការសម្រេចចិត្តក្នុងការវិនិយោគ (The basic of investment decisions) 16
១.៣.១. ផលចំណេញនៃការវិនិយោគ (Investment return) 16
១.៣.១.១. ផលចំណេញជាដុល្លារ (Dollar return) 17
១.៣.១.២. ផលចំណេញជាភាគរយ (Percentage return) 17
១.៣.១.៣. ផលចំណេញជាមធ្យមនព្វន្ត (Average return) 18
១.៣.១.៤. ផលចំណេញមធ្យមនៃប័ណ្ណភាគហ៊ុន និងអត្រាគ្មានហានិភ័យ 18
១.៣.២. ហានិភ័យចំពោះការវិនិយោគ ( Investment risk) 18

## ជំពូកទី២

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

២.១.ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ផ.ម.ល (CSX) 20
២.១.១. ប្រវត្តិរបស់ (CSX) 20
២.១.២. រូបសញ្ញា និងនាមករណ៍របស់ CSX 21
២.១.៣. រចនាសម្ព័ន្ធរបស់ CSX 22
២.២. ចក្ខុវិស័យ និងបេសកម្មរបស់ CSX 23
២.៣. ប្រតិបត្តិករទាំង៣របស់ CSX 24
២.៤. ក្រុមហ៊ុនបានចុះបញ្ជីនៅ CSX 25
២.៥. សមាជិករបស់ CSX 26
២.៥.១. ក្រុមហ៊ុនធានាទិញមូលបត្រ 26
២.៥.២. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ 27

២.៦. អ្នកចូលរួមរបស់ CSX ..... 27
២.៦.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ ..... 27
២.៦.២. ភ្នាក់ងារបញ្ជិកាមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ..... 28
២.៦.៣. ភ្នាក់ងារទូទាត់ ..... 28
២.៧. ព័ត៌មានអំពី CSX ..... 28

## ជំពូកទី៣
## ដំណើរការនៃការវិនិយោគ

៣.១. ដំណើរការនៃការវិនិយោគលើទីផ្សារមូលបត្រកម្ពុជា ..... 29
៣.១.១. ការជ្រើសរើសក្រុមហ៊ុនចុះបញ្ជី ..... 29
៣.១.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ ..... 29
៣.១.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID) ..... 29
៣.១.១.៣. ការបើកគណនីជួញដូរ ..... 30
៣.១.១.៤. ការបើកគណនីសាច់ប្រាក់ ..... 31
៣.១.១.៥. ការដាក់បញ្ជា ..... 31
៣.១.២. វិធានប្រតិបត្តិការជួញដូរនៅលើទីផ្សារ ..... 33
៣.១.២.១. វគ្គជួញដូរ ..... 33
៣.១.២.២. ការបញ្ជា ..... 34
៣.១.២.៣. វិធីសាស្រ្តជួញដូរ ..... 34
ក. វិធីសាស្រ្តដេញថ្លៃដោយយកថ្លៃតែមួយ ..... 35
ខ. វិធីសាស្រ្តដេញថ្លៃដោយយកថ្លៃច្រើន ..... 36
គ. លក្ខណៈរបស់ផ្សារភាគហ៊ុន ..... 36
៣.២. អត្ថប្រយោជន៍នៃការវិនិយោគលើមូលបត្រ ..... 38
៣.២.១. ចំពោះវិនិយោគិន ..... 38
៣.២.២. ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ..... 39

៣.២.៣. ចំពោះសេដ្ឋកិច្ច ........ 40

## ជំពូកទី៤

## ការវិភាគ និងការប្រឈមនឹងហានិភ័យ

៤.១. វិភាគលើកត្តាមូលដ្ឋាន និងបច្ចេកទេស ........ 41
៤.១.១. វិភាគផ្អែកលើកកត្តាមូលដ្ឋាន ........ 41
៤.១.១.១. កត្តាសេដ្ឋកិច្ច ........ 41
៤.១.១.២. កត្តាអាជីវកម្ម ........ 43
៤.១.១.៣. កត្តារបាយការហិរញ្ញវត្ថុ ........ 44
៤.១.២. វិភាគផ្អែកលើបច្ចេកទេស ........ 46
៤.១.២.១. ទិន្នន័យទីផ្សារ ........ 46
៤.១.២.២. តម្រូវការ និងផ្គត់ផ្គង់ ........ 46
៤.១.២.៣. ឧបករណ៍វិភាគទិន្នន័យផ្អែកលើបច្ចេកទេស ........ 47
៤.២. បញ្ហាប្រឈម ........ 49
៤.២.១. ស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយ ........ 49
៤.២.២. ទំហំទីផ្សារ ព័ត៌មាន និងចំណាយ ........ 50

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ 51
២. អនុសាសន៍ ........ 52

## ឯកសារយោង

## ឧបសម្ព័ន្ធ

# បញ្ជីតារាង

តារាងទី១៖ អត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់បុគ្គល
តារាងទី២៖ ក្រុមហ៊ុនចុះបញ្ជី
តារាងទី៣៖ បញ្ជីក្រុមហ៊ុនធានាទិញមូលបត្រ
តារាងទី៤៖ បញ្ជីក្រុមហ៊ុនឈ្មួញជើងសារ
តារាងទី៥៖ បញ្ជីភ្នាក់ងារទូទាត់សាច់ប្រាក់
តារាងទី៦៖ បញ្ជីភ្នាក់ងារបញ្ជិការមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ
តារាងទី៧៖ បញ្ជីភ្នាក់ងារទូទាត់

# បញ្ជីរូបភាព

រូបភាពទី១៖ រូបសញ្ញាផ្សារមូលបត្រកម្ពុជា

រូបភាពទី ២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ CSX

រូបភាពទី៣៖ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

រូបភាពទី៤៖ ដំណើរកាដាក់បញ្ជារនៅក្នុងទីផ្សារមូលបត្រ

រូបភាពទី៥៖ ដំណើរការជួញដូរនៅក្នុងទីផ្សារមូលបត្រ

រូបភាពទី៦៖ គំរូបន្ទាត់និន្នាការ ( Trend lines)

រូបភាពទី៧៖ គំរូ Support and Resistance

រូបភាពទី៨៖ សញ្ញាណនៃ Price patterns

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការរីកចំរើនរបស់ប្រទេសនីមួយៗមានសន្ទុស្សន៍កើនឡើងជារៀងរាល់ថ្ងៃ ស្របពេលដែលបច្ចេកវិទ្យាក៏មានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ ប្រទេសដែលមានការរីកលូតលាស់ខ្លាំង គឺមានប្រព័ន្ធហិរញ្ញវត្ថុខ្លាំងដែលរក្សាបាននូវស្ថេរភាព និងមានដំណើរការល្អ។ សម័យកាលកាន់តែជឿនលឿនធ្វើឱ្យសកលលោកមានការវិវត្តន៍ទៅមុខយ៉ាងរហ័ស។ ជាពិសេសប្រទេសមហាអំណាចតែម្តងដែលមានការនាំមុខលើគ្រប់វិស័យមិនថាខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកបច្ចេកវិទ្យានោះទេ។ ដោយសារកត្តាប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសមហាអំណាចទាំងនោះមានសុខភាពល្អ រឹងមាំបែបនេះហើយ ទើបបានជាជំរុញឱ្យសេដ្ឋកិច្ចដំណើរការទៅបានទាំងរលូនគ្មានភាពរអាក់-រអួល។ ការដែលបង្កើតបានជាប្រព័ន្ធហិរញ្ញវត្ថុដែលមានសុខភាពល្អបែបនេះគឺមានកត្តាជាច្រើនដូចជា៖ ការធ្វើពាណិជ្ជកម្មជាតិ និងអន្តរជាតិ និងការវិនិយោគពីក្នុង និងក្រៅប្រទេស។ តួយ៉ាងដូចដែលយើងបានដឹងហើយថាសហរដ្ឋអាមេរិកជាប្រទេសដែលមានទីផ្សារមូលបត្រធំជាងគេមួយក្នុងសកលលោក នាពេលបច្ចុប្បន្នដោយសារសហរដ្ឋអាមេរិកមានបច្ចេកវិទ្យាទំនើប និងមានក្រុមហ៊ុនកំពូលៗជាច្រើនក្នុងប្រទេសរបស់ខ្លួន ហេតុ-នេះហើយធ្វើឱ្យអ្នកវិនិយោជាច្រើនធ្វើការវិនិយោគទៅលើទីផ្សារហិរញ្ញវត្ថុរបស់អាមេរិក។ យើងឃើញថាសន្ទុស្សន៍នៃការលូតលាស់ក្នុងទីផ្សារហិរញ្ញវត្ថុរបស់អាមេរិក គឺមានភាពរហ័សណាស់។ ទទឹមនឹងនេះយើងក៏សង្កេតឃើញថាសហរដ្ឋអាមេរិកមាននូវប្រព័ន្ធធនាគាមួយដ៏រឹងមាំ ដែលមានធនាគាល្បីមួយចំនួនដូចជា៖ [1]JPMorgan Chase, Bank of America, Wells Fargo & Co., Citigroup ដែលសុទ្ធសឹងជាធនាគាដែលតម្កល់នូវដើមទុនជាច្រើន និងផ្តល់ទំនុកចិត្តខ្ពស់ដល់អតិថិជន ឬក៏វិនិយោគិនជាដើមក្នុងការតម្កល់ទ្រព្យរបស់ខ្លួន។

[2] បើយើងនិយាយពីប្រទេសកម្ពុជាយើងវិញនៅក្នុងអំឡុងពេលជាងពីរទសវត្សរ៍មុននឹងផ្ទុះជំងឺកូវីដ-១៩រាតត្បាតទូទាំងសកលលោក ប្រទេសកម្ពុជាក៏ជាប្រទេសដែលកំពុងអភិវឌ្ឍ ដែលមានចំណូលកម្រិតទាបក្នុងឆ្នាំ២០១៥ ហើយនឹងឈានទៅក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ នាពេលខាងមុខ។ ដើម្បីជួយកំណើនសេដ្ឋកិច្ចឱ្យកាន់តែមានសន្ទុស្សន៍លូតលាស់ខ្លាំង ហើយប្រព័ន្ធហិរញ្ញវត្ថុមាន-សុខភាពល្អ និងមានស្ថេរភាពនោះយើងក៏មិនអាចមើលរំលងនូវទីផ្សារហិរញ្ញវត្ថុផងដែរ។ ដោយសារតែស្ថាប័ន-ហិរញ្ញវត្ថុនៅប្រទេសកម្ពុជាដែលស្ថិតក្រោមការគ្រប់គ្រង់របស់ធនាគាជាតិនៃព្រះរាជាណាចក្រកម្ពុជាយើងគឺអាចនិយាយបានថាមានភាពល្អប្រសើរមិនចាញ់បណ្តាប្រទេសជិតខាងប៉ុន្មានទេ។ ដោយហេតុនេះហើយប្រទេស-កម្ពុជាក៏មានលទ្ធភាពដូចប្រទេសដទៃដែលក្នុងការកសាងទីផ្សារហិរញ្ញវត្ថុដ៏រឹងមាំមួយ ដើម្បីលើកកំពស់សេដ្ឋ-

[1] www.bankrate.com/banking/biggest-banks-in-america/ ( ដកស្រង់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ )

[2] www.worldbank.org/km/country/cambodia/overview ( ដកស្រង់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ )

កិច្ចក្នុងប្រទេសយើង ដូចដែលយើងបានដឹងហើយទីផ្សារហិរញ្ញវត្ថុជាទីផ្សារមួយដែលសំខាន់ក្នុងការជំរុញដល់សេដ្ឋកិច្ចវាបានជួយដល់អ្នកវិនិយោគ ដែលត្រូវការដើមទុនសម្រាប់ការពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុន។ [3] ដូចជាក់ស្តែងនៅប្រទេសកម្ពុជាយើងសព្វថ្ងៃ នៅលើទីផ្សារមូលបត្រមានក្រុមហ៊ុន ៩ ដែលបានចុះបញ្ជីមានដូចជា៖

១. ជេអេស លែន ភីអិលស៊ី (JSL)

២. ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (DBDE)

៣. ផេសចិក (ខេមបូឌា) ម.ក (PEPC)

៤. ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC)

៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

៦. ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

៧. កំពង់ផែស្វយ័តភ្នំពេញ (PPAP)

៨. ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI)

៩. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)។

ដោយឡែកត្បិតតែប្រទេសយើងបានបង្កើតនូវទីផ្សារមូលបត្រពិតមែន ប៉ុន្តែកត្តាចំណេះដឹងរបស់ប្រជា-ពលរដ្ឋដែលយល់ដឹងពីការវិនិយោគក្នុងវិស័យនេះគឺនៅមានកម្រិត និងមិនទាន់ទូលំទូលាយដូចប្រទេសគេនៅឡើយទេ។ រឿងរ៉ាវដែលប្រជាជនយើងត្រូវដឹងមុននឹងវិនិយោគមានដូចជា ប្រវត្តិនៃផ្សារមូលបត្រកម្ពុជា ដំណើរការនៃការវិនិយោគ ស្ថានភាពទីផ្សារមូលបត្ររបស់ក្រុមហ៊ុននីមួយៗ ដែលដំណើរការទាំងនោះត្រូវបានរៀបចំឡើងយ៉ាងម៉ត់ចត់ពីសំណាក់មន្ត្រីពាក់ព័ន្ធ ក្នុងគណៈកម្មការមូលបត្រកម្ពុជា ព្រោះដើម្បីធានានូវសុក្រឹត្យភាពចំពោះម្ចាស់ក្រុមហ៊ុន និងអ្នកវិនិយោគលើមូលបត្រទាំងឡាយ។ ការសិក្សាយល់ដឹងច្បាស់ពីក្រុមហ៊ុមណាមួយដែលខ្លួនមានបំណងវិនិយោគគឺមានវាធ្វើឱ្យយើងមើលឃើញឱកាស និងអាចឱ្យយើងគ្រប់គ្រងហានិភ័យដែលអាចនឹងកើតមានក្នុងអំឡុងពេលដែលវិនិយោគ។ ហេតុដូច្នេះហើយ យើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសយកប្រធានបទ៖ “ការវិនិយោគលើទីផ្សារមូលបត្រ និងការប្រឈមនឹងហានិភ័យ” មកធ្វើការសិក្សាស្រាវជ្រាវ។

[3] www.csx.com.kh/data/lstcom/listPosts (ដកស្រង់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាទីផ្សារមូលបត្របានបង្កើតឡើងក៏ពិតមែន ប៉ុន្តែវាពុំសូវទទួលបានការចាប់អារម្មណ៍ពីសំណាក់ប្រជាជនយើងនៅឡើយទេ ដោយហេតុថាប្រភពព័ត៌មាននៅមានកម្រិតមិនទាន់ទូលំទូលាយ មិនអាចឱ្យក្រុមមនុស្ស សិស្ស និស្សិត សាធារណៈជន សហគ្រាស ក្រុមហ៊ុន និងវិនិយោគិនទទួលបានព័ត៌មានគ្រប់គ្រាន់ក្នុងការយកទៅវិនិច្ឆ័យធ្វើការសម្រេចចិត្តបាន។ ម្យ៉ាងវិញទៀតទីផ្សារមូលបត្រនៅប្រទេសកម្ពុជាជាវិស័យមួយថ្មីដែលទើបនឹងចាប់ផ្ដើមបើកដំណើរការជួញដូរក្នុងឆ្នាំ២០១២។ ដើម្បីទទួលបានព័ត៌មានបន្ថែម និងយល់ដឹងអំពីទីផ្សារមូលបត្រ ហើយអាចក្រឡេកមើលឱកាសល្អក្នុងការវិនិយោគ និងហានិភ័យប្រឈមក្នុងទីផ្សារ យើងគួរយល់ដឹងអំពីការដំណើរការសំខាន់ៗក្នុងវិនិយោគលើទីផ្សារហិរញ្ញវត្ថុ ហើយឈានទៅរកឱកាសមួយដែលសាកសមជាមួយនឹងហានិភ័យទាបបំផុត។

ផ្អែកតាមការរៀបរាប់ខាងលើ ក៏ដូចជាតាមការដែលដឹងពីសិស្សានុសិស្ស សាធារណៈជនមួយចំនួននាពេលបច្ចុប្បន្នតែងមានភាពងើងឆ្ងល់ដែលបង្កើតបានជាសំណួរដូចជាៈ

១. តើដំណើរការរបស់ផ្សារមូលបត្រកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

២. តើការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជាអាចជួបនឹងមានហានិភ័យអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

កិច្ចការចម្បងដែលបង្កើតឱ្យមានការស្រាវជ្រាវនេះឡើង គឺដើម្បីស្វែងយល់ពី **"ដំណើរការទីផ្សារមូលបត្រ និងហានិភ័យដែលអាចនឹងប្រឈមក្នុងទីផ្សារ"** ក៏ព្រោះតែកម្ពុជាយើងនៅមានទីផ្សារតូចចង្អៀត និងមានកត្តាមួយចំនួនដែលធ្វើឱ្យប្រជាជនកម្ពុជាពុំសូវមានការចាប់អារម្មណ៍លើទីផ្សារមូលបត្រក្នុងស្រុក។ ជារួមដូចដែលបានរៀបរាប់ខាងលើនេះហើយ ទើបយើងខ្ញុំធ្វើការសម្រេចចិត្តសិក្សាស្រាវជ្រាវលើប្រធានបទនេះ និងមានបំណងចង់ចែករំលែកនូវអ្វីដែលខ្លួនបានសិក្សាស្រាវជ្រាវនេះ ដើម្បីជាឯកសារសម្រាប់មនុស្សគ្រប់ជំនាន់ដែលចង់ដឹងពីទីផ្សារមូលបត្រកម្ពុជា។ ស្របពេលជាមួយគ្នានោះយើងនឹងសិក្សាទៅលើទ្រឹស្ដី ប្រវត្តិ ដំណើរ និងហានិភ័យដែលប្រឈមក្នុងទីផ្សារមូលបត្រ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងរយៈពេលកំណត់មួយជាក់លាក់ ហើយទីផ្សារមូលបត្រកម្ពុជាមានលក្ខណៈនៅមានកម្រិតផងទៀតនោះ ធ្វើឱ្យការសិក្សាស្វែងរកឯកសារមានភាពលំបាក ទោះជាយ៉ាងណាក៏យើងខ្ញុំនឹងខិតខំសិក្សាតាមដែរអាចធ្វើទៅបាន ដោយផ្ដោតលើប្រធានបទ **"ដំណើរការវិនិយោគលើផ្សារមូលបត្រកម្ពុជា និងការប្រឈមនឹងហានិភ័យ"** ដែលបានកើតមានឡើងក្នុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ តែប៉ុណ្ណោះ។

យើងធ្វើការសិក្សាលើទីផ្សារមូលបត្រនៅក្នុងកម្ពុជាយើងឱ្យបានស៊ីជម្រៅលើប្រធានបទនេះត្រង់ចំណុច ដំណើរការរបស់ផ្សារមូល-បត្រកម្ពុជា ការវិភាគជាមូលដ្ឋាន និងភាពប្រឈមនឹងហានិភ័យក្នុងវិស័យនេះតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្ហាញពីដំណើរការ និងភាពដែលអាចប្រឈមនឹងហានិភ័យក្នុងទីផ្សារមូលបត្រកម្ពុជាទៅដល់វិនិយោគិនសាធារណៈ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់របស់ប្រធានបទនេះ យើងខ្ញុំផ្ទាល់យល់ឃើញថាការសិក្សាលើប្រធានបទមួយនេះអាចនឹងផ្តល់ជាប្រយោជន៍មួយចំនួនដូចជា៖

- ចំពោះមិត្តនិស្សិតទាំងឡាយ និងអ្នកស្រាវជ្រាវ

សារណាដែលបានសិក្សាលើប្រធានបទខាងលើនេះ នឹងផ្តល់ជាគំនិតបង្ហាញដល់អ្នកអានដែលមានបំណងចង់ដឹងពីដំណើរការវិនិយោគលើវិស័យទីផ្សារមូលបត្រកម្ពុជា សិក្សាស្វែងយល់បន្ថែមហានិភ័យដែលអាចកើតមានឡើងក្នុងទីផ្សារហិរញ្ញវត្ថុ ហើយក៏អាចជាចំណេះដឹងបន្ថែមដែលទាក់ទងនឹងទីផ្សារមូលបត្រកម្ពុជា ដោយថ្ងៃមុខទៀតទីផ្សារមូលបត្រកម្ពុជានឹងក្លាយជារឿងមួយដែលមនុស្សទូទៅគួតែដឹង។

- ចំពោះវិនិយោគិន

ការស្រាវជ្រាវនេះអាចនឹងជាប្រយោជន៍ខ្លាំងដល់អ្នកវិនិយោគ ពិសេសគឺអ្នកណាដែលមានគំនិតចង់រៀនចង់ដឹងពីការវិនិយោគនេះតែនៅមានភាពស្ទាក់ស្ទើរ និងខ្លាចពីហានិភ័យដែលអាចកើតមានក្នុងទីផ្សារដោយសារកង្វះនូវព័ត៌មានពាក់ព័ន្ធនឹងទីផ្សារនៅប្រទេសកម្ពុជា។ យើងខ្ញុំគិតថាប្រធានបទនេះប្រហែលនឹងអាចជួយបកស្រាយ និងកាត់បន្ថយភាពស្ទាក់ស្ទើរ ភាពភ័យខ្លាចដែលអ្នកអានមាន។

- ចំពោះមហាជន ក៏ដូចជាប្រជាពលរដ្ឋទូទៅ

ប្រធានបទនេះបង្កើតឡើងមិនសំដៅទៅលើក្រុមមនុស្សណាមួយឡើយពោលគឺ វាជាឯកសារជំនួយស្មារតីមួយដែលជួយឱ្យប្រជាពលរដ្ឋទូទៅដែលបានយល់ដឹងពីអ្វីជាទីផ្សារមូលបត្រ ហើយថាតើវាបានជួយអ្វីខ្លះដល់សេដ្ឋកិច្ចប្រទេសកម្ពុជាយើង និងដឹងពីសារៈសំខាន់មួយចំនួនក្នុងវិស័យទីផ្សារមូលបត្រកម្ពុជា។ ដើម្បីឱ្យវិស័យមួយនេះដំណើរការបានល្អក៏មិនអាចខ្វះបាននូវការគាំទ្រពីសំណាក់ប្រជាជនទូទៅផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងដំណើរការនៃការស្រាវជ្រាវក្នុងការចងក្រងជាសៀវភៅនេះឡើង យើងខ្ញុំបានប្រើនូវវិធីសាស្ត្រមួយក្នុងការប្រមូលទិន្នន័យ។ វិធីសាស្ត្រនោះរួមមាន៖

- **ប្រភពទិន្នន័យ**

ដើម្បីធ្វើការស្រាវជ្រាវនេះបាន យើងខ្ញុំបានប្រើប្រាស់វិធីប្រមូលទិន្នន័យបន្ទាប់បន្សំ (Secondary data) ក្នុងការសម្រេចនូវការសិក្សាស្រាវជ្រាវលើចំណោទបញ្ហាដែលចោទសួរនៅខាងលើ។

- **ទិន្នន័យបន្ទាប់បន្សំ (Secondary data)**

វិធីសាស្ត្រនេះផងដែរជាវិធីសាស្ត្រដែលយើងខ្ញុំបានប្រើ និងមិនអាចមើលរំលងក្នុងការស្វែងរកឯកសារទាំងឡាយ ដែលពាក់ព័ន្ធប្រធានបទមួយនេះយើងខ្ញុំបានប្រមូលទិន្នន័យតាមរយៈ៖

១. ប្រព័ន្ធអ៊ីនធឺណេត៖

- គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា (CSX)។ ក្នុងនោះយើងបានពិនិត្យមើលលើឯកសារច្បាប់ អនុក្រឹត្យ និងប្រកាសដែលពាក់ព័ន្ធ ជាពិសេសយើងផ្តោតលើច្បាប់ និងប្រកាសដែលទើបនឹងសម្រេចនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។
- គេហទំព័រផ្សេងៗទៀតដែលពាក់ព័ន្ធមានដូចជា៖ វីដេអូការ Live របស់មន្ត្រីជំនាញនៃផ្សារមូលបត្រ និងវីដេអូជាច្រើនទៀត។

២. បណ្ណាល័យ៖

- យើងខ្ញុំបានទៅស្វែងរកឯកសារបន្ថែមពីបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាគារអន្តរជាតិ និងឯកសារមេរៀនដែលរៀនកន្លងមកជាមួយសាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងនោះរួមមានរបាយការណ៍របស់សិស្សច្បងជំនាន់មុនផងដែរ។
- យើងក៏បានរកឯកសារតាមរយៈ E-Library របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- **របៀបវិភាគ**

ចំពោះការវិភាគទិន្នន័យយើងនឹងធ្វើទៅតាមវិធីសាស្ត្រគុណវិស័យ (Qualitative data) ដែលវិភាគលើទិន្នន័យមិនមែនជាលេខ និងតាមបែបពិពណ៌នា។ យើងធ្វើការវិភាគការស្រាវជ្រាវនេះបាន ដោយពឹងផ្អែកឯកសារដែលយើងប្រមូលបាន ហើយធ្វើការវិភាគលើទិន្នន័យទាំងអស់នោះដោយយោងតាមការស្រាវជ្រាវកន្លងមក។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានបែងចែកដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១៖ រំលឹកនៃការវិនិយោគ
- ជំពូកទី២៖ ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា (CSX)
- ជំពូកទី៣៖ ដំណើរការនៃការវិនិយោគ
- ជំពូកទី៤៖ ឱកាសវិនិយោគ និងការប្រឈមនឹងហានិភ័យ
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

# ជំពូកទី ១
# រំលឹកទ្រឹស្ដីនៃការវិនិយោគ

# ជំពូកទី ១
# រំលឹកទ្រឹស្តីនៃការវិនិយោគ

## ១.១. និយមន័យទូទៅ

ការវិនិយោគ គឺជាទង្វើនៃការបែងចែកធនធានដែលមានដូចជា ថវិកា ពេលវេលា ជាមួយនឹងការរំពឹងទុកនឹងទទួលប្រាក់ចំណូល ឬប្រាក់ចំណេញនាពេលអនាគត។ យើងអាចវិនិយោគទៅលើការខិតខំប្រឹងប្រែងដូចជាការប្រើប្រាស់ថវិកាដើម្បីចាប់ផ្តើមអាជីវកម្ម ឬក្នុងទ្រព្យសកម្ម ដូចជាការទិញអចលនទ្រព្យដោយសង្ឃឹមថានឹងលក់វាវិញនៅពេលក្រោយក្នុងតម្លៃខ្ពស់ជាងពេលទិញ ប៉ុន្តែរាល់ការវិនិយោគសុទ្ធតែអាចប្រឈមនឹងហានិភ័យដែលកើតមានស្របពេលជាមួយគ្នា។

ការវិនិយោគលើ Financial assets គឺជាការបណ្តាក់ទុនដើម្បីទទួលបានភាគលាភ ឬការប្រាក់ និងចំណេញជាមូលធន។

ការវិនិយោគ គឺជាការប្រើប្រាស់សាច់ប្រាក់ដើម្បីបង្កើនសាច់ប្រាក់។ សំដៅទៅលើការដាក់ប្រាក់ក្នុងធនាគារដើម្បីទទួលបានការប្រាក់ជាដើម។

[4] ការវិនិយោគមាន ២ប្រភេទ គឺ៖ ការវិនិយោគពិត (Real Investment) និង ការវិនិយោគហិរញ្ញវត្ថុ (Financial Investment)។

ការវិនិយោគមានច្រើនយ៉ាង និងផ្អែកទៅតាមគោលបំណង និងការសម្រេចចិត្តរបស់បុគ្គលនីមួយៗ ថាតើចង់វិនិយោគបែបណា ហើយសង្ឃឹមថានឹងបានផលប្រយោជន៍អ្វីមួយពីការវិនិយោគនេះ។

### ១.១.១. ការវិនិយោគពិត (Real Investment)

ការវិនិយោគពិត គឺជាប្រាក់ដែលវិនិយោគលើទ្រព្យអរូបិយ អចលនៈវត្ថុ ការទិញមាស ប្រាក់ទុកជាដើម ដែលមិនមែនជាវិនិយោគលើការទិញឧបករណ៍ហិរញ្ញវត្ថុ។

ដោយសារប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍ យើងឃើញថាមានការវិនិយោគបែបនេះមានច្រើននៅលើវិស័យអចលនៈវត្ថុដូចជា ការទិញផ្ទះ ដីធ្លី សម្រាប់ដាក់ជួល ឬលក់យកប្រាក់ចំណេញនាពេលខាងមុខ។ ហើយវាក៏ជាការវិនិយោគមួយដែលមានសន្ទុស្សន៍ខ្លាំងផងដែរនៅប្រទេសកម្ពុជាយើង។

[4] DR. PREETI SINGH, *FUNDAMENTALS OF INVESTMENT*, First Edition 2018, 7

**១.១.២. ការវិនិយោគហិរញ្ញវត្ថុ** (Financial Investment)

ការវិនិយោគបែបហិរញ្ញវត្ថុ គឺសំដៅលើការទុកលុយមួយឡែក ហើយរំពឹងថានឹងទទួលបានផលចំណេញមួយចំនួនពីវា។ ការវិនិយោគបែបនេះមានក្នុងទម្រង់ដូចជា ដាក់ប្រាក់បញ្ញើមានកាលកំណត់ (Fixed account) ភាគហ៊ុន (Stock) មូលបត្រ (Securities) ផ្សេងៗជាដើម។

ក្នុងករណីដែលយើងមានប្រាក់ទំនេរមួយចំនួនក្នុងដៃ ចង់ធ្វើការវិនិយោគដើម្បីទទួលបានប្រាក់ចំណេញ ប៉ុន្តែមិនចង់វិនិយោគតាមបែបវិនិយោគពិតទេ ដូចនេះគេអាចវិនិយោគទៅលើទីផ្សារហិរញ្ញវត្ថុបាន។ ម្យ៉ាងវិញទៀតបើអ្នកចង់វិនិយោគដែរ ដោយហេតុថាបច្ចុប្បន្នមិនមានប្រាក់ច្រើនសម្រាប់វិនិយោគលើការវិនិយោគពិត នោះអ្នកអាចងាកមើលការវិនិយោគហិរញ្ញវត្ថុបាន ដោយមិនត្រូវការកញ្ចប់ថវិកាច្រើនដូចការវិនិយោគពិតទេ។ ចំពោះអ្នកដែលចង់បានការវិនិយោគដែលគ្មានហានិភ័យវិញក៏អាចវិនិយោគតាមបែបហិរញ្ញវត្ថុបានដែរពោល គឺការប្រាក់បញ្ញើយកការប្រាក់ពីធនាគារ។

ដើម្បីឱ្យមានភាពងាយយល់គេបានចែកការវិនិយោគហិរញ្ញវត្ថុជា ២ផ្នែកគឺ៖

១. ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចជួញដូរបាន (Non-Marketable Financial Assets)

២. ទ្រព្យសកម្មហិរញ្ញវត្ថុអាចជួញដូរបាន (Marketable Financial Assets)

**១.១.២.១. [5]ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចជួញដូរបាន** (Non-Marketable Financial Assets)

**ក. ការដាក់ប្រាក់បញ្ញើ** (Saving account or deposit)

ការដាក់ប្រាក់បញ្ញើជាវិធីសាស្ត្រវិនិយោគមួយដែលល្អសម្រាប់អ្នកដែលចូលចិត្ត និងមានទំនុកចិត្តលើស្ថាប័នធនាគារ ហើយដាក់ប្រាក់តម្កល់ក្នុងធនាគារ។ ជាមួយការសន្សំប្រាក់បែបនេះ គឺមានភាពងាយស្រួលណាស់ដោយគ្រាន់តែជ្រើសរើសស្ថាប័នធនាគារណាមួយដែលយើងពេញចិត្ត រួចហើយធ្វើការស្នើសុំបើកគណនីប្រាក់បញ្ញើប្រភេទណាមួយ ដែលយើងគិតថាទទួលបានការប្រាក់ច្រើនពីការដាក់ប្រាក់បញ្ញើនោះជាការស្រេច។ ប្រភេទនៃគណនីប្រាក់បញ្ញើទាំងនោះមានដូចជា៖ Saving Account, Current Account, Fixed Account or Time deposit account។ល។ ការដាក់ប្រាក់បញ្ញើក្នុងធនាគារទទួលជាការប្រាក់ពីធនាគារវិញនៅពេលវេលាកំណត់ណាមួយ ហើយយើងក៏អាចធ្វើការដកប្រាក់វិញផងដែរបើមានការចាំបាច់ត្រូវការប្រើប្រាស់ប្រាក់នោះ។ការសន្សំប្រាក់ក្នុង Saving account or Current account គឺមានភាពសាមញ្ញខ្លាំង ប៉ុន្តែការប្រាក់ដែលទទួលបានវិញក៏មិនសូវច្រើនដែរ។

[5] corporatefinanceinstitute.com (ដកស្រង់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

**ខ. ការដាក់ប្រាក់បញ្ញើមានកាលកំណត់** (Fixed account)

ចំណែកឯការដាក់ប្រាក់បញ្ញើមានកាលកំណត់នេះវិញ គឺទទួលបានការប្រាក់ច្រើនជាមួយអត្រាការប្រាក់ខ្ពស់ជាង Saving account ដោយសារ Fixed account មានលក្ខខណ្ឌពិបាកជាង Saving account។ ការដាក់ប្រាក់បញ្ញើមានកាលកំណត់ក៏មិនខុសគ្នា ពីរបៀបក្នុងការបើកគណនីប្រាក់បញ្ញើធម្មតាខាងលើដែរ។ ចំណុចពិសេសនៃគណនីប្រាក់បញ្ញើមានកាលកំណត់ គឺយើងទទួលបាននូវអត្រាការប្រាក់ខ្ពស់ ស្របពេលជាមួយគ្នានោះដែរ គណនីនេះតម្រូវឱ្យយើងតម្កល់ប្រាក់តាមចំនួនដែលធនាគារបានកំណត់ និងតម្កល់ក្នុងរយៈពេលមួយជាក់លាក់ដោយមិនតម្រូវឱ្យដកប្រាក់វិញក្នុងស្ថានភាពណាមួយឡើយ បើករណីយើងដកប្រាក់វិញការប្រាក់ដែលត្រូវទទួលបាននឹងថយចុះ ឬគិតជាអសាបង់ផ្អែកទៅតាមគោលការណ៍របស់ធនាគារ។

ជាឧទាហរណ៍ដូចធនាគារកាថេ (CUBC) ដែលមានទទួលទាំងគណនីសន្សំ និងគណនីដាក់ប្រាក់បញ្ញើមានកាលកំណត់ទៀតផង ដែលក្នុងនោះធនាគារកាថេ បានផ្តល់អត្រាការប្រាក់ពី ២% ដល់ ៤.៧៥%នៃចំនួនទឹកប្រាក់ចាប់ពី ១.០០០ដុល្លារអាមេរិកដល់ ៥០០.០០០ដុល្លារអាមេរិកចុះក្រោមជាមួយនឹងរយៈ ៣ខែ ៦ខែ និង១២ខែ។ ស្របពេលជាមួយគ្នានេះ លក្ខខណ្ឌនៃការដាក់ប្រាក់បញ្ញើមានកាលកំណត់នេះ តម្រូវឱ្យអតិថិជនតម្កល់ប្រាក់នោះពីពេលចាប់ផ្តើមរហូតដល់កាលកំណត់ទើបទទួលបានការប្រាក់ បើពុំដូច្នោះទេធនាគារនឹងធ្វើការទូទាត់ការប្រាក់តាមស្ថានភាពជាក់ស្តែងតាមគោលការណ៍ធនាគារបានចែង។

តារាងទី១៖ អត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់បុគ្គល

| រូបិយបណ្ណ | រៀល | ដុល្លារ |
|---|---|---|
| ប្រាក់បញ្ញើដំបូង | KHR ៤.០០០.០០០ រៀល | USD ១.០០០ < X |
| ៣ ខែ | ៤% ក្នុង១ឆ្នាំ | ២% ក្នុង១ឆ្នាំ |
| ៦ខែ | ៥% ក្នុង១ឆ្នាំ | ៣% ក្នុង១ឆ្នាំ |
| ១២ ខែ | ៦% ក្នុង១ឆ្នាំ | ៤.៧៥% ក្នុង១ឆ្នាំ |
| | ផ្លាស់ប្តូរវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ដែលបានបាត់ ២០.០០០រៀល | ផ្លាស់ប្តូរវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ដែលបានបាត់ ៥ ដុល្លារ |

ប្រភព៖ www.cathaybk.com.kh/km/personal/fixed-deposit (ដកស្រង់ថ្ងៃទី១ ខែសីហា ឆ្នាំ២០២២)

**គ. មូលបត្រទីផ្សាររូបិយវត្ថុ** (Money Market Instrument)

ជាមូលបត្រ (Securities) ដែលមានរយៈពេលតិចជាងមួយឆ្នាំចេញផ្សាយលក់ដោយក្រុមហ៊ុនសាជីវកម្ម និងរដ្ឋាភិបាលដើម្បីទទួលបានមូលនិធិរយៈពេលខ្លី។ មូលបត្ររបស់ទីផ្សាររូបិយវត្ថុមាន ៣ ប្រភេទដូចខាងក្រោម៖

១. ប័ណ្ណរតនាគាររយៈពេលខ្លី (T-Bills)៖ ជាកាតព្វកិច្ចបំណុលរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងរយៈពេលខ្លី ដែលគាំទ្រដោយរតនាគារ ជាមួយនឹងកាលកំណត់តិចជាងមួយឆ្នាំ។ ប័ណ្ណរតនាគារជាធម្មតាត្រូវបានលក់ចាប់ពីចំនួន ១.០០០ដុល្លារអាមេរិកឡើងទៅ ។ ទោះយ៉ាងណាក៏ដោយ ប័ណ្ណរតនាគារខ្លះអាចឈានដល់ចំនួនអតិបរមា ៥ លានដុល្លារ។ មូលបត្រទាំងនេះត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាជាការវិនិយោគដែលមានហានិភ័យទាប និងមានសុវត្ថិភាព។

២. ផលបត្រពាណិជ្ជកម្ម (Commercial paper)៖ ជាប័ណ្ណបំណុលដែលបោះពុម្ពដោយក្រុមហ៊ុនដែលគេទុកចិត្ត ហើយដែលមានកេរ្តិ៍ឈ្មោះល្បីឬប៉ុណ្ណោះ ហើយជាធម្មតាមិនត្រូវបានធានាទេដែលមានរយៈពេលមិនលើសពីមួយឆ្នាំឡើយ។

៣. វិញ្ញាបនបត្របញ្ញើ (Certificate of deposits)៖ ជាគឺប័ណ្ណដែលផ្តល់ដោយធនាគារ និងសហជីពឥណទាន ដែលផ្តល់បុព្វលាភអត្រាការប្រាក់ជាថ្នូរនឹងអតិថិជនដែលយល់ព្រមទុកប្រាក់បញ្ញើមួយចំនួន ដោយមិនប៉ះពាល់ក្នុងរយៈពេលដែលបានកំណត់ទុកជាមុន។ វាអាស្រ័យលើធនាគារនីមួយៗនូវលក្ខខណ្ឌដែលខ្លួនចង់ផ្តល់ជូនអត្រាខ្ពស់ជាង បើប្រៀបធៀបទៅនឹងផលិតផលសន្សំ និងទីផ្សារប្រាក់របស់ធនាគារ ហើយការពិន័យដែលវាអនុវត្តសម្រាប់ការដកប្រាក់មុនកាលកំណត់។ វិញ្ញាបនបត្រនេះស្រដៀងទៅនឹង Fixed deposit ដែលរៀបរាប់ខាងលើ។

### **១.១.២.២. ទ្រព្យសកម្មហិរញ្ញវត្ថុអាចជួញដូរបាន** (Marketable Financial Asset)

#### **ក. ភាគហ៊ុន** (Stock)

[6] ភាគហ៊ុន គឺជាប្រភេទនៃមូលបត្រ ដែលតំណាងឱ្យកម្មសិទ្ធិ ឬផលប្រយោជន៍ភាគហ៊ុននៃសាជីវកម្ម។ ភាគហ៊ុននោះត្រូវបានបង្កើតឡើងនៅលើមូលដ្ឋានក្នុងមួយហ៊ុន ហើយម្ចាស់ត្រូវបានសំដៅជាញឹកញាប់ថាជាភាគហ៊ុនិក ឬម្ចាស់ភាគហ៊ុន។ នៅពេលយើងទិញភាគហ៊ុនមួយ ឬច្រើននៃភាគហ៊ុន យើងកំពុងទិញការទាមទារសមាមាត្រលើទ្រព្យសម្បត្តិសុទ្ធរបស់ក្រុមហ៊ុន និងប្រាក់ចំណូលនាពេលអនាគតរបស់ក្រុមហ៊ុននោះ អាចនិយាយឱ្យងាយយល់មានន័យថា យើងវិនិយោគលើអនាគតរបស់ក្រុមហ៊ុន។

ផលប្រយោជន៍ដែលយើងទទួលបានពីភាគហ៊ុនមានដូចជា

- ភាគហ៊ុនឡើងថ្លៃ (Capital gain) ៖ ការចំណេញពីលក់ភាគហ៊ុននៅពេលភាគហ៊ុនយើងកាន់ក្នុងដៃមានការកើនឡើងមានតម្លៃខ្ពស់។

[6] www.investopedia.com (ដកស្រង់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២)

- ភាគលាភ (Dividend) ៖ ជាប្រាក់ចំណេញ ឬប្រាក់សំណងដែលក្រុមហ៊ុនបែងចែកទៅឱ្យម្ចាស់និងភាគហ៊ុនិកទាំងឡាយក្នុងការចូលរួមវិនិយោគទុន ដោយចែកទៅតាមប្រាក់ចំណូលដែលក្រុមហ៊ុនរកបានក្នុងពេលបច្ចុប្បន្ន។
- សិទ្ធិបោះឆ្នោត (Voting right) ៖ គឺអ្នកមានសិទ្ធិបោះឆ្នោតក្នុងការសម្រេចចិត្តរាល់បញ្ហាផ្សេងៗក្នុងក្រុមហ៊ុន ឬការជ្រើសរើសនាយកដឹកនាំក្រុមហ៊ុនជាដើម។ សិទ្ធិបោះឆ្នោតនេះអាចមានទៅតាមប្រភេទភាគហ៊ុន និងអាស្រ័យទៅតាមក្រុមហ៊ុនផងដែរ។ សិទ្ធិបោះឆ្នោត (Voting right) នេះមិនមានចំពោះភាគហ៊ុនបុរិមាទេ (Preferred stock)។

ភាគហ៊ុនទាំងអស់សុទ្ធតែមិនដូចគ្នាទេ វាជារឿងសំខាន់ក្នុងការយល់ដឹងអំពីប្រភេទនៃភាគហ៊ុន។ ជាទូទៅគេចែកប្រភេទភាគហ៊ុនជា ២ មានដូចជា៖

- ភាគហ៊ុនធម្មតា (Common stock) ៖ វិនិយោគិនភាគហ៊ុនភាគច្រើនជាម្ចាស់ភាគហ៊ុនទូទៅ ដែលបានជួញដូរជាសាធារណៈ។ ភាគហ៊ុននេះផ្តល់នូវសិទ្ធិបោះឆ្នោត និងលទ្ធភាពបានភាគលាភ និងការកើនឡើងតម្លៃ។
- [7]ភាគហ៊ុនបុរិមា ឬភាគហ៊ុនអាទិភាព (Preferred stock) ៖ ម្ចាស់ភាគហ៊ុនបុរិមាទទួលបានខ្ពស់ចំពោះភាគលាភ ឬការបែងចែកទ្រព្យសកម្មជាងម្ចាស់ភាគហ៊ុនធម្មតា។ ភាគហ៊ុនបុរិមាមានអាទិ-ភាពជាងម្ចាស់ភាគហ៊ុនទូទៅនៅពេលនិយាយអំពីភាគលាភ ដែលជាទូទៅបានទិន្នផលច្រើនជាងភាគហ៊ុនធម្មតា ហើយអាចបង់ប្រចាំខែ ឬប្រចាំត្រីមាស។ យើងអាចនិយាយម្យ៉ាងទៀតថា វាជាភាគហ៊ុនកូនកាត់ដែលមានលក្ខណៈដូចទៅនឹងមូលបត្រចំណូលថេរ ហើយអាចចំណេញពីការឡើងថ្លៃនៃភាគហ៊ុនថែមទៀត ។ ក្នុងករណីបើក្រុមហ៊ុនដែលវិនិយោគមានប្រកាសក្ស័យធន ហើយជម្រះបញ្ជីហិរញ្ញវត្ថុ វិនិយោគិនដែលមានភាគហ៊ុនបុរិមានឹងទទួលបានការបែងចែកទ្រព្យមុនវិនិយោគិនដែលកាន់ភាគហ៊ុនធម្មតា។ ប៉ុន្តែអ្នកកាន់ភាគហ៊ុននេះមិនមានសិទ្ធិក្នុងការចូលរួមបោះ-ឆ្នោតដូចអ្នកកាន់ភាគហ៊ុនធម្មតាទេ។

**ខ. មូលបត្រចំណូលថេរ** (Fixed income securities)

មូលបត្រចំណូលថេរ ជាប្រភេទមូលបត្រដែលវិនិយោគក្នុងរយៈពេលវែងជាមួយកិច្ចសន្យាមួយជាក់លាក់ និងទទួលបានការប្រាក់ថេរដែលបានកំណត់ក្នុងកិច្ចសន្យាជាមួយនឹងកាលកំណត់មួយជាក់លាក់។ មូលបត្រ

[7] www.investopedia.com ( ដកស្រង់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ )

ចំណូលថេរមានដូចជា សញ្ញាប័ណ្ណ (Bonds) ភាគហ៊ុនបុរិមា (Preferred stock) មូលបត្រអាចប្តូរជាភាគហ៊ុនធម្មតាបាន (Convertible securities)។

- សញ្ញាប័ណ្ណ ឬមូលបត្របំណុល (Bonds) គឺជាកម្ចីពីអ្នកវិនិយោគទៅឱ្យអ្នកខ្ចី ដូចជាក្រុមហ៊ុន ឬរដ្ឋាភិបាល។ អ្នកខ្ចីប្រើលុយដើម្បីផ្តល់មូលនិធិដល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន ហើយអ្នកវិនិយោគទទួលបានការប្រាក់ពីការវិនិយោគ។ តម្លៃទីផ្សារនៃសញ្ញាប័ណ្ណអាចផ្លាស់ប្តូរទៅតាមពេលវេលា។

សញ្ញាប័ណ្ណមាន ២ ប្រភេទធំៗគឺ៖ សញ្ញាប័ណ្ណសាជីវកម្ម (Corporate bond) សញ្ញាប័ណ្ណរដ្ឋាភិបាល (Government bonds)។ ក្នុងនោះផងដែរសញ្ញាប័ណ្ណរដ្ឋាភិបាលមានដូចជា៖

១. T-Bill មានរយៈពេលតិចជា ១ឆ្នាំ

២. T-Note មានរយៈពេលចាប់ពី ១ឆ្នាំឡើងទៅ និងត្រឹម ១០ឆ្នាំចុះក្រោម

៣. T-bond មានរយៈពេលចាប់ពី ១០ឆ្នាំឡើងទៅ ឬច្រើនជាងនេះ។

- ភាគហ៊ុនបុរិមា (Preferred stock) ៖ គឺជាភាគហ៊ុនដែលទទួលភាគលាភថេរដូចសញ្ញាប័ណ្ណដែរ។ ដោយសារភាគហ៊ុនមានលក្ខណៈជាកូនកាត់។
- [8] មូលបត្រអាចប្តូរជាភាគហ៊ុនធម្មតាបាន (Convertible securities) ៖ ជាប្រភេទមូលបត្រ ឬសញ្ញាប័ណ្ណដែលអាចប្តូរទៅជាភាគហ៊ុនធម្មតាបានក្នុងនោះរួមមាន ភាគហ៊ុនបុរិមា និងសញ្ញាប័ណ្ណអាចប្តូរជាភាគហ៊ុនធម្មតាបាន។ នៅពេលដែលវិនិយោគិនគិតថាចង់ប្តូរពីផលចំណេញថេរទៅជាភាគហ៊ុនធម្មតាវិញដើម្បីទទួលបានផលចំណេញខ្ពស់ជាងនេះ។ ប៉ុន្តែការប្តូរទៅជាភាគហ៊ុនធម្មតានេះគឺយើងអាចធ្វើបានតែម្តងតែប៉ុណ្ណោះ ពោលគឺមិនអាចប្តូរត្រលប់ពីភាគហ៊ុនធម្មតាវិញបានទេ។ ការដែលអាចប្តូរពីមូលបត្រ ឬសញ្ញាប័ណ្ណបែបនេះបានក៏អាស្រ័យលើការជ្រើសរើស និងការទិញផងដែរ។

### គ. មូលនិធិសង្គហ ឬមូលនិធិរួម (Mutual funds)

មូលនិធិសង្គហ (Mutual funds) គឺជាប្រភេទនៃហិរញ្ញវត្ថុដែលបង្កើតឡើងដោយក្រុមអ្នកវិនិយោគតូចតាចដែលមិនមានប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រជាដើម ដើម្បីវិនិយោគលើមូលបត្រដូចជា ភាគហ៊ុន មូលបត្របំណុល និងឧបករណ៍ទីផ្សារផ្សេងទៀត។ មូលនិធិសង្គហត្រូវបានដំណើរការដោយអ្នកគ្រប់គ្រងប្រាក់ដែលមានជំនាញវិជ្ជាជីវៈ ដែលបែងចែកទ្រព្យសម្បត្តិរបស់មូលនិធិ និងព្យាយាមបង្កើតប្រាក់ចំណេញ ឬប្រាក់ចំណូល

[8] www.investor.gov ( ដកស្រង់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ )

សម្រាប់អ្នកវិនិយោគទាំងនោះ។ ផលបត្ររបស់មូលនិធិទៅវិញទៅមកត្រូវបានរៀបចំឡើង និងរក្សាឱ្យត្រូវគ្នានឹងគោលបំណងនៃការវិនិយោគដែលមានចែងក្នុងសៀវភៅណែនាំរបស់ខ្លួន។ មូលនិធិមូលនិធិសង្គហផ្តល់ឱ្យអ្នកវិនិយោគតូចតាច ឬបុគ្គលម្នាក់អាចចូលប្រើប្រាស់បាននូវផលបត្រចម្រុះដែលគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ និងតម្លៃទាប។

**ឃ. មូលបត្រដេរីវេទីវ ឬនិស្សន្ទ** (Derivative securities)

មូលបត្រដេរីវេទីវ ជាកិច្ចសន្យាហិរញ្ញវត្ថុរវាងភាគីទាំងពីរសម្រាប់ការទិញ ឬលក់អចលនទ្រព្យ ទ្រព្យ-សម្បត្តិ ទំនិញ ឬមូលបត្រ សញ្ញាប័ណ្ណផ្សេងទៀតក្នុងតម្លៃដែលបានកំណត់ទុកជាមុន ក្នុងរយៈពេលមួយជាក់-លាក់។ វាជាឧបករណ៍ដែលវិនិយោគិនប្រើប្រាស់ក្នុងការវិនិយោគដើម្បីគ្រប់គ្រងលើហានិភ័យដែលអាចកើតមានឡើងដូច អតិផរណា បរិត្តផរណា និងការរំពឹងទុកនាពេលអនាគត។ [9]មូលបត្រដេរីវេទីវនេះមានច្រើនទម្រង់ដែលគេនិយមប្រើដូចជា៖ Forward, Future, Option និង Swaps ជាដើម។

- Option ៖ ជាកិច្ចសន្យាដែលផ្តល់ឱ្យម្ចាស់កម្មសិទ្ធិនូវសិទ្ធិ (ប៉ុន្តែមិនមែនជាកាតព្វកិច្ច) ដើម្បីទិញ ឬលក់មូលបត្រជាក់លាក់ក្នុងតម្លៃជាក់លាក់មួយនៅពេលបច្ចុប្បន្ន និងមានកាលបរិច្ឆេទផុត-កំណត់ជាក់លាក់មួយ។ ក្នុងនោះផងដែរ Option មាន ២ ប្រភេទគឺ Put option និង Call option ។ Put option ផ្តល់ឱ្យម្ចាស់នូវសិទ្ធិក្នុងការលក់អ្វីមួយ ហើយ Call option ផ្តល់ឱ្យម្ចាស់នូវសិទ្ធិក្នុងការទិញអ្វីមួយ។
- Forward ៖ គឺជាកិច្ចសន្យាផ្ទាល់ខ្លួនរវាងភាគីទាំងពីរដើម្បីទិញ ឬលក់ទ្រព្យសម្បត្តិក្នុងតម្លៃជាក់-លាក់មួយនៅថ្ងៃអនាគត។ កិច្ចសន្យាទៅមុខអាចត្រូវបានប្រើសម្រាប់ការការពារ ឬការរំពឹងទុក។ កិច្ចសន្យានេះអាចកំណត់ពីទំនិញ ចំនួន និងកាលបរិច្ឆេទដឹកជញ្ជូន ចំពោះការទូទាត់អាចកើតមានឡើងលើមូលដ្ឋានសាច់ប្រាក់ក្រោយពេលដឹកជញ្ជូន។ កិច្ចសន្យា Forward មានលក្ខណៈឯកជន និងមិនមានជួញដូរលើទីផ្សារនោះទេ។
- Future ៖ ជាកិច្ចសន្យាព្រមព្រៀងផ្លូវច្បាប់ដើម្បីទិញ ឬលក់ទ្រព្យសកម្មជាក់លាក់មួយ ឬមូលបត្រក្នុងតម្លៃដែលបានកំណត់ទុកជាមុននៅពេលជាក់លាក់ណាមួយ។ កិច្ចសន្យា Future មានស្តង់ដារសម្រាប់គុណភាព និងបរិមាណ ដើម្បីជួយសម្រួលដល់ការជួញដូរ។ ម៉្យាងទៀត អ្នកទិញត្រូវតែទិញ ឬអ្នកលក់ត្រូវតែលក់ទ្រព្យសកម្មក្រោមតម្លៃដែលបានកំណត់ ដោយមិនគិតពីតម្លៃទីផ្សារបច្ចុប្បន្ននៅកាលបរិច្ឆេទផុតកំណត់មួយ។

[9] www.thestreet.com (ដកស្រង់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២)

ដូចគ្នានេះដែរ មូលបត្រដេរីវេទីវត្រូវបានគេនិយមប្រើប្រាស់យ៉ាងទូលំទូលាយលើប្រតិបត្តិការពាណិជ្ជ-កម្មអន្តរជាតិ បើគេចង់វិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុនសាជីវកម្មណាមួយជាមួយកាលបរិច្ឆេទជាក់លាក់ពោលគឺគេគ្រាន់តែទិញសិទ្ធិ Call option ពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុដទៃទៀតដោយគ្រាន់តែបង់ប្រាក់បន្ថែម (Premium) ដើម្បីធានាដំណើរការប្រតិបត្តិការនេះ បន្ទាប់មកចាំដល់កាលបរិច្ឆេទកំណត់នៃកិច្ចសន្យា (Strike price)។ ក្នុងករណីដែលស្ថានភាពមិនអំណោយផលដល់ការវិនិយោគរបស់យើង គឺថាយើងត្រូវបោះបង់ចោលកិច្ចសន្យាទិញ Call option នោះ ស្មើនឹងយើងត្រូវខាតប្រាក់បង់បន្ថែម (Premium) ដែលបានបង់នោះ។ ចំណែកឯការទិញ Forward និង Future វិញពុំមានចំណាយលើប្រាក់បន្ថែម (Premium) ទេ។

## ១.២. ការទិញ និងលក់មូលបត្រ

ជាទូទៅគោលបំណងចម្បងរបស់វិនិយោគិនដែលរំពឹងពីការវិនិយោគក្នុងទីផ្សារមូលបត្រ គឺចង់ទទួលបានវិញនូវភាគលាភច្រើន និងចំណេញច្រើនពីការលក់មូលធន (Capital gain) នៅពេលដែលភាគហ៊ុនក្នុងដៃឡើងថ្លៃខ្ពស់។ ក្នុងទីផ្សារមូលបត្រគេឃើញថាមានសកម្មភាពទិញលក់ភាគហ៊ុនមានច្រើនជាងការរងចាំភាគលាភពីក្រុមហ៊ុន។

### ១.២.១. ក្រុមហ៊ុនជើងសារ (Broker)

ក្រុមហ៊ុនជើងសារ គឺជាបុគ្គល ឬក្រុមហ៊ុនដែលដើរតួជាអន្តរការីរវាងអ្នកវិនិយោគ និងទីផ្សារមូលបត្រ។ ដោយសារតែក្នុងទីផ្សារមូលបត្រទទួលយកតែការបញ្ជាទិញពីបុគ្គល ឬក្រុមហ៊ុនដែលជាសមាជិកនៃទីផ្សារមូល-បត្រ(បានចុះឈ្មោះក្នុង Financial Industry Regulatory Authority (FINRA) ពាណិជ្ជករ និងវិនិយោគិនត្រូវការសេវាកម្មរបស់សមាជិកប្តូរប្រាក់នោះក្នុងការធ្វើប្រតិបត្តិការជួញដូរ។ [10] ក្រុមហ៊ុនជើងសារមានផ្តល់សេវា ២ ប្រភេទ៖ Discount និង Full-service ។

- Discount service ៖ អាចអនុវត្តការជួញដូរជាច្រើនប្រភេទជូនអតិថិជន ដែលពួកគេនឹងគិតប្រាក់កម្រៃជើងសារដែលបានកាត់ពីប្រតិបត្តិការពាណិជ្ជកម្មនោះ(តម្លៃផ្អែកតាមក្រុមហ៊ុនកំណត់)។ ក្នុងនោះផងដែរសេវានេះមិនផ្តល់ដំបូន្មានក្នុងការវិនិយោគ ការប្រឹក្សា និងព័ត៌មានទីផ្សារដល់វិនិយោគិនឡើយ។ ការប្រើប្រាស់សេវាកម្មនេះជួយឱ្យចំណាយអស់តិច។
- Full-service ៖ ផ្តល់ជូននូវសេវាកម្មជាច្រើន រួមទាំងការស្រាវជ្រាវទីផ្សារ ការណែនាំអំពីការវិនិ-យោគ និងផែនការផ្សេងៗ។ សម្រាប់សេវានេះ វិនិយោគិនអាចនឹងបង់កម្រៃជើងសារខ្ពស់សម្រាប់ការជួញដូររបស់ពួកគេជាង Discount service។

[10] www.investopedia.com (ដកស្រង់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២)

Online Broker ជាឈ្មួញកណ្តាលមួយដែរគេនិយមប្រើជួញដូរក្នុងទីផ្សារមូលបត្រវាមានភាពងាយស្រួលមិនស្មុគស្មាញ ហើយឆាប់រហ័សទៀតផង។ មិនត្រឹមតែប៉ុណ្ណោះថែមទាំងចំណាយតិចទៀតផង។ ប៉ុន្តែរាល់ការជួញដូរទាំងអស់គឺយើងត្រូវធ្វើដោយខ្លួនឯង។

### **១.២.២. ការបើកគណនីក្រុមហ៊ុនជើងសារ**

បន្ទាប់ពីបានស្គាល់ពីក្រុមហ៊ុនជើងសាររួចមក យើងនឹងធ្វើការបើកគណនីដើម្បីជួញដូរក្នុងទីផ្សារភាគ-ហ៊ុន។ ដើម្បីកំណត់ថាតើគណនីក្រុមហ៊ុនជើងសារប្រភេទណាដែលអ្នកគួរបើក អ្នកត្រូវដឹងពីគោលបំណងនៃការវិនិយោគរបស់ខ្លួន។ ស្វែងយល់ពីគោលបំណងនៃប្រាក់របស់ខ្លួនឯង ថាតើពេលវេលាដែលអ្នកចង់បានប្រាក់នោះជារយៈពេលវែង ឬខ្លី វានឹងជួយកំណត់ប្រភេទនៃគណនីដែលអ្នកត្រូវប្រើ។

ដំណើរការនៃការបើកគណនីក្រុមហ៊ុនជើងសារ គឺស្រដៀងគ្នាទៅនឹងការបង្កើតគណនីធនាគារដោយមានភាពខុសគ្នាសំខាន់មួយ។ សម្រាប់គណនីថ្មីនឹងត្រូវបានស្នើសុំឱ្យបំពេញទម្រង់គណនីថ្មី ដែលសាកសួរអំពីការអត់ឱនចំពោះហានិភ័យ គោលបំណងវិនិយោគ ពេលវេលា និងទំហំនៃចំណេះដឹងហិរញ្ញវត្ថុរបស់អ្នក ដើម្បីបង្កើតប្រវត្តិរូបរបស់វិនិយោគិន។

ជាទូទៅនៅសហរដ្ឋអាមេរិកវិនិយោគិនតែងតែមានគណនី ២ គឺ៖ គណនីសាច់ប្រាក់ (Cash account) និង គណនីធានា (Margin account) ដែលជួយដល់ការជួញដូររបស់វិនិយោគិន។

- គណនីសាច់ប្រាក់ (Cash account) ៖ ជាគណនីមួយដែលតម្រូវឱ្យវិនិយោគិនដាក់ប្រាក់ក្នុងគណនីនេះដើម្បីធ្វើការជួញដូររយៈពេលវែង។ យើងត្រូវមានសាច់ប្រាក់គ្រប់គ្រាន់ក្នុងទិញប័ណ្ណភាគហ៊ុនណាមួយដែលយើងចង់បាន។
- [11]គណនីធានា (Margin account) ៖ ជាគណនីមួយដែលអាចឱ្យវិនិយោគិនធ្វើការខ្ចីប្រាក់ពីក្រុម-ហ៊ុនជើងសារមកទិញភាគហ៊ុន។ ក្រោមបទបញ្ញត្តិ T បានកំណត់ថាក្រុមហ៊ុនជើងសារអាចឱ្យវិនិយោគិនខ្ចីជាប្រាក់ដើម្បីទិញប័ណ្ណភាគហ៊ុន និងផលិតផលហិរញ្ញវត្ថុផ្សេងៗទៀតបានយ៉ាងច្រើនត្រឹម ៥០% នៃតម្លៃទីផ្សាររបស់ប័ណ្ណភាគហ៊ុនដែលត្រូវទិញនោះ។ ចំណុចពិសេសនៃគណនីមួយនេះ គឺថាវិនិយោគិនពុំចាំបាច់មានប្រាក់ដល់ ១០០% នៃប័ណ្ណភាគហ៊ុនក៏អាចទិញភាគហ៊ុនបានដែរ។ ហើយមួយទៀតក្នុងករណីដែលភាគហ៊ុនមានការធ្លាក់ចុះខ្លាំងដល់កម្រិតកំណត់គណនីនឹងតម្រូវឱ្យវិនិយោគិនធ្វើការបន្ថែមទឹកប្រាក់ដើម្បីរក្សាភាគហ៊ុនទាំងនោះ ទឹកប្រាក់ដែលថែមនោះហៅថា (Margin Call)។

[11] money.usnews.com ( ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ )

## ១.៣. មូលដ្ឋាននៃការសម្រេចចិត្តក្នុងការវិនិយោគ (The basic of investment decisions)

យើងដាំដើមឈើដើម្បីចង់ទទួលផ្លែផ្កានៅពេលក្រោយ ចំពោះការវិនិយោគក៏មិនខុសគ្នាប៉ុន្មានដែរគោលបំណងពីការវិនិយោគរបស់វិនិយោគិន គឺសង្ឃឹមថានឹងទទួលបានធនលាភ (Return) ពីការវិនិយោគនោះនាពេលអនាគត។ ទន្ទឹមនឹងគ្នានេះផងដែរមុននឹងអាចទទួលបានចំណេញវាបាននាំមកនូវហានិភ័យផងដែរ ដូចនេះ ឥទ្ធិពលក្នុងការសម្រេចចិត្តរបស់វិនិយោគិនពិតជាសំខាន់លើផលចំណេញ និងប្រឈមនឹងហានិភ័យនាពេលអនាគត។ ពេលខ្លះគំរោងវិនិយោគមួយមានហានិភ័យខ្ពស់គឺផ្តល់ភាពប្រថុយប្រថានខ្ពស់ ហើយសង្ឃឹមបានផលចំណេញមកវិញខ្ពស់ សំដៅទៅដល់ High risk high return ហើយក៏មានករណីខ្លះវិនិយោគិនប្រឈមនឹងហានិភ័យខ្ពស់ទទួលបានផលចំណេញទាបក៏មាន។ ស្របពេលជាមួយគ្នានោះដែរ បើគេចង់បញ្ចៀសពីហានិភ័យឱ្យមានកម្រិតទាប គេនឹងទទួលបានផលចំណេញទាបដូចគ្នា សំដៅដល់ Low risk low return ។ យើងអាចនិយាយបានថាផលចំណេញកាន់តែខ្ពស់ បើធៀបនឹងហានិភ័យក៏ខ្ពស់ដូចគ្នាដែរ ។

មុននឹងសម្រេចចិត្តជ្រើសរើសវិនិយោគ គេត្រូវគិតគូរអំពីស្ថានភាព ឬកម្រិតហានិភ័យណាមួយដែលគេអាចទទួលយកបាន។ គេបានធ្វើចំណាត់ថ្នាក់វិនិយោគិនជា ៣ ក្រុមធំៗគឺ៖

- Risk averse investor ៖ វិនិយោគិនមិនចូលចិត្តហានិភ័យ
- Risk seeking investor ៖ វិនិយោគិនចូលចិត្តហានិភ័យ
- Neutral risk ឬ Risk indifferent investor ៖ ណឺតនឹងហានិភ័យ

ជាការពិតណាស់ហានិភ័យតែងតែកើតមានចំពោះវិនិយោគ យើងមិនបានបញ្ចៀសបាននូវហានិភ័យទាំងអស់នោះទេ ប៉ុន្តែយើងអាចគ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលអាចកើតមាននោះ ដោយវិនិយោគិនធ្វើការវិនិយោគជាលក្ខណៈផលបត្រ (Portfolio) ។

### ១.៣.១. ផលចំណេញនៃការវិនិយោគ (Investment return)

បន្ទាប់ពីបានស្គាល់ពីការសម្រេចចិត្តរួចមក ក្នុងចំណុចនេះយើងនិយាយទាក់ទងនឹង ធនលាភ (Return) ដែលវិនិយោគិនទាំងឡាយចង់បានត្រលប់មកវិញច្រើនពីការវិនិយោគរបស់ខ្លួន។ ដូចដែរបានរៀបរាប់ខាងលើការវិនិយោគដែលទទួលបានធនលាភខ្ពស់ គឺត្រូវប្រថុយនឹងហានិភ័យខ្ពស់ដែរ តែផ្ទុយទៅវិញយើងក៏អាចវិនិយោគទៅលើការប្រភេទវិនិយោគផ្សេងទៀតដែលមានហានិភ័យទាប ហើយទទួលបានធនលាភតិចឬល្មម។ វិនិយោគិនភាគច្រើននៅសហរដ្ឋអាមេរិកនិយមវិនិយោគទៅលើប័ណ្ណរតនាគារ (Government bonds) រយៈ-ពេលខ្លីតែមួយគត់ដែលគេចាត់ទុកថាគ្មានហានិភ័យ ឬហានិភ័យស្មើសូន្យ (Risk free rate = $R_f$)។ ការដែលគិតបែបនេះ ដោយសារប្រជាជនមានជំនឿទុកចិត្តលើប្រទេសរបស់ខ្លួនថានឹងមានលទ្ធភាពសងបំណុលដល់សាធារណៈជនទាន់ពេលនឹងគ្រប់ចំនួនទៅតាមអ្វីដែលបានកំណត់ក្នុងកិច្ចសន្យា។ មូលហេតុមួយទៀត គឺ

សហរដ្ឋអាមេរិកជាប្រទេសមហាអំណាចសេដ្ឋកិច្ច គម្រោងមួយចំនួនដែលបង្កើតឡើងមិនត្រឹមតែជួយដល់សង្គមទេថែមទាំងជួយដល់សេដ្ឋកិច្ចជាតិខ្លួនទៀតផង។

**១.៣.១.១. ផលចំណេញជាដុល្លារ** (Dollar return)

ផលចំណេញដែលទទួលបានពីការវិនិយោគទៅលើភាគហ៊ុន ក្នុងទីផ្សារភាគហ៊ុនផលចំណេញដែលត្រូវទទួលបានមាន ២ បែបគឺ៖

- ចំណូលរយៈពេលខ្លី (Current income) ៖ អាចជាភាគលាភ ឬសាច់ប្រាក់( ទិន្នផល )ដែលទទួលបានពីការវិនិយោគរបស់ខ្លួនទៅលើមូលបត្រ ភាគហ៊ុន សញ្ញាប័ណ្ណ ឬមូលនិធិរួម។

- ផលចំណេញមូលធន (Capital gain or loss) ៖ ជាភាពចំណេញ ឬខាតពីការលក់ភាគហ៊ុន។ យើងអាចនិយាយសំដៅដល់ការផ្លាស់ប្តូរតម្លៃក្នុងទីផ្សារ នៅពេលដែលវិនិយោគិនទិញហ៊ុន ឬសញ្ញាប័ណ្ណក្នុងតម្លៃទាបនៃកាលបរិច្ឆេទណាមួយ ហើយមួយរយៈក្រោយមានការកើនឡើងតម្លៃជាងមុនធ្វើការវិនិយោគិនលក់ទៅបានចំណេញហៅថា Capital gain និងច្រាស់មកវិញ គឺ Capital loss។

[12]នាំឱ្យយើងបាន៖

| Dollar return = Dividend income + Capital gain/(loss) |
|---|

**១.៣.១.២. ផលចំណេញជាភាគរយ** (Percentage return)

ការគណនាផលចំណេញ គិតជាភាគរយធៀបនឹងទុនដែលបានវិនិយោគ គឺជាវិធីសាស្ត្រដែលគេនិយមប្រើប្រាស់ក្នុងការគណនាផលចំណេញ។ វិធីសាស្ត្រនេះមានភាពងាយស្រួលសម្រាប់វិនិយោគិន ព្រោះថាលទ្ធផលទទួលបានងាយស្រួលក្នុងការបកស្រាយថាតើ $១ ដែលវិនិយោគនឹងផ្តល់ជាធនលាភវិញប៉ុន្មានភាគរយ។

[13]នាំឱ្យយើងបាន៖

$$Percentage\ return = \left[\frac{Capital\ gain(loss) + Dividend}{Initial\ share\ price}\right] * 100$$

Or $$R = \frac{(PE+PB)+D}{PB}$$

ដែល៖ $P_E$ = Ending price of the investment.

$P_B$ = Beginning price or initial share price.

D = Dividend paid at the end of period.

R = Total return over the period.

---

[12] www.wallstreetmojo.com ( ដកស្រង់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ )

[13] www.wallstreetmojo.com ( ដកស្រង់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ )

**១.៣.១.៣. ផលចំណេញជាមធ្យមនពន្ធ** (Average return)

គេក៏មានវិធីសាស្ត្រមួយបែបទៀតដែលគណនាតាមរបៀបគិតជាមធ្យម (Mean or Average return) ដែលបានតម្លៃមធ្យមនៃផលចំណេញផ្សេងៗគ្នា ឬក៏ឆ្នាំខុសៗគ្នា។

[14]នាំឱ្យយើងបាន៖

$$\bar{R} = \frac{\sum_{i=1}^{n} R_i}{n} = \frac{(R_1 + R_2 + R_3 \dots + R_n)}{n}$$

ដែល៖ $\bar{R}$ = Average or mean return.

$R_i$ = $i^{th}$ value of total return.

n = Number of total return.

**១.៣.១.៤. ផលចំណេញមធ្យមនៃប័ណ្ណភាគហ៊ុន និងអត្រាគ្មានហានិភ័យ**

យើងបានគណនា Average return រាល់ការវិនិយោគនីមួយៗដើម្បីងាយស្រួលក្នុងការសម្រេចចិត្តវិនិយោគ។ គេអាចប្រៀបធៀបតួរលេខទាំងនេះទៅនឹងផលចំណេញទទួលបានវិនិយោគលើប័ណ្ណរតនាគាររយៈពេលខ្លី T-bills ដែលគេចាត់ទុកថាគ្មានហានិភ័យ (Risk free rate) ក្នុងរយៈពេលខ្លី។ Risk premium គឺជាភាពខុសគ្នារវាង Return ដែលមានហានិភ័យ និងការវិនិយោគគ្មានហានិភ័យ។

[15]នាំឱ្យយើងបាន៖

$$\text{Risk premium} = R_i - R_f$$

**១.៣.២. ហានិភ័យចំពោះការវិនិយោគ** (Investment risk)

ប្រាកដណាស់ការវិនិយោគ គឺតែងតែមានហានិភ័យភ្ជាប់មកជាមួយ។ ក្នុងនោះហានិភ័យត្រូវបានបែងចែកជាច្រើនខុសៗពីគ្នា ដើម្បីជៀសផុតពីហានិភ័យ និងគ្រប់គ្រងវាបានយើងត្រូវដឹងពីហានិភ័យឱ្យបានច្បាស់។ [16]ហានិភ័យទាំងនោះរួមមាន៖

១. ហានិភ័យទីផ្សារ (Market risk)

ហានិភ័យនៃការវិនិយោគមានប្រែប្រួលដោយសារការអភិវឌ្ឍនៃសេដ្ឋកិច្ច ឬក៏បណ្តាលពីព្រឹត្តិការណ៍ផ្សេងទៀតដែលប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល។ ហានិភ័យទីផ្សារ គឺចង់សំដៅទៅដល់ការកើនឡើង ឬថយចុះក្នុងទីផ្សារមិនថា ភាគហ៊ុន សញ្ញាប័ណ្ណ ឬមូលបត្រក៏មិនចៀសផុតពីទ្រឹស្តីផ្គត់ផ្គង់ និងតម្រូវការដែរ។ បើសិនជា

[14] www.wallstreetmojo.com (ដកស្រង់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២)

[15] slideplayer.com (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)

[16] www.getsmarteraboutmoney.ca (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)

ភាគហ៊ុននោះល្អហើយមានគេវិនិយោគច្រើននោះនឹងធ្វើឱ្យតម្រូវការកើនឡើង ហើយធ្វើឱ្យតម្លៃភាគហ៊ុនកើនឡើងដូចគ្នា ទន្ទឹមនឹងការកើនក៏អាចថយចុះដែរបើផ្គត់ផ្គង់ច្រើនជាតម្រូវការ។ ហានិភ័យទីផ្សារ ជាហានិភ័យមួយដែលតែងតែកើតមានឡើងរៀងរាល់គ្រប់វិនាទីរវាងអ្នកផ្គត់ផ្គង់ និងអ្នកត្រូវការ។

២. ហានិភ័យនយោបាយ (Political risk)

ហានិភ័យមួយដែលអ្នកវិនិយោគមិនគួរមើលរំលងនោះ គឺហានិភ័យនយោបាយ។ ដោយសារហានិភ័យនយោបាយ គឺមានហានិភ័យខ្ពស់ខ្លាំងជាងហានិភ័យធម្មតា។ ឧទាហរណ៍៖ បើយើងវិនិយោគលើប្រទេសកំពុងមានភ្លើងសង្គ្រាមដូចប្រទេសអុយក្រែន និងប្រទេសមហាអំណាចរុស្ស៊ី ហានិភ័យដែលមានគឺខ្ពស់រហូតដល់ក្ស័យធនទៀតផងក៏មិនដឹង ព្រោះប្រទេសទាំង ២ មានសង្គ្រាមនឹងគ្នាហើយមិនទាន់មានដំណោះស្រាយណាមួយដែលអាចឱ្យប្រទេសទាំង ២ យល់ព្រមបញ្ចប់សង្គ្រាមឡើយ។ មួយវិញទៀត បើសង្គ្រាមនៅតែបន្តនោះធ្វើឱ្យភាពរាំរ៉ៃសេដ្ឋកិច្ចនៅតែកើតមាន។

៣. ហានិភ័យអតិផរណា (Inflation risk)

ហានិភ័យអតិផរណាធ្វើឱ្យយើងបាត់បង់អំណាចនៃការទិញ ដោយសារតែតម្លៃនៃផលិតផល និងទំនិញផ្សេងៗមានការកើនឡើងថ្លៃជារួម។ អតិផរណាតែងតែកើនឡើងជារៀងរាល់ឆ្នាំ ហើយមិនធ្លាក់ចុះវិញទេ វាធ្វើឱ្យយើងទិញទំនិញ ឬសេវាកម្មបានតិចជាងមុន។ ផលប៉ះពាល់របស់វាមានដូចជា៖

- ធ្វើឱ្យតម្លៃបច្ចុប្បន្ននៃការប្រាក់ (Present value of coupon) នៃសញ្ញាប័ណ្ណមានការថយចុះប្រសិនបើគេដាក់ទុនវិនិយោគលើសញ្ញាប័ណ្ណ។
- ចំណាយជាមូលធន (Capital expenditures) មានការកើនឡើងនៅពេលដែលក្រុមហ៊ុនដល់ពេលចំបាច់ត្រូវធ្វើវិនិយោគបន្ថែម។

៤. ហានិភ័យការប្រាក់ (Interest risk)

ហានិភ័យអត្រាការប្រាក់ក៏អាចប៉ះពាល់ដល់វិនិយោគដែរ ដោយភាគច្រើនយើងសង្កេតឃើញថាមានចំពោះមូលបត្រ (Securities) ពោលដូចជាការប្រកាសរបស់ធនាគារកណ្តាលដែលទាក់ទងនឹងការផ្លាស់-ប្តូរគោលនយោបាយរូបិយវត្ថុ។ វាធ្វើឱ្យអត្រាការប្រាក់ដែលទទួលបានពីមូលបត្រទាំងនោះតិចជាងមុនជាមួយនឹងហានិភ័យដដែរ។

ហានិយភ័យដែលបានរៀបរាប់ខាងលើនេះ ជាហានិភ័យដែលវិនិយោគិនមិនអាចមើលរំលងមុននឹងចង់វិនិយោគលើប្រភេទវិនិយោគណាមួយ។ ប្រាកដណាស់ហានិភ័យមិនមែនមានត្រឹមតែខាងលើនេះទេ វានៅមានជាច្រើនទៀតដូចជា៖ Credit risk, Liquidity risk, payment risk និង Foreign investment risk។ ដោយរើសយកនូវប្រភេទហានិភ័យសំខាន់ៗដែលត្រូវដឹងមុនធ្វើការវិនិយោគ ជៀសវាងការវិនិយោគបរាជ័យ។

# ជំពូកទី ២

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

(CSX)

# ជំពូកទី២

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX)

## ២.១. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ផ.ម.ល (CSX)

### ២.១.១. ប្រវត្តិរបស់ (CSX)

[17] ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតី តេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ ("ផ្សារមូលបត្រកម្ពុជា") ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា។ ផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

កាលបរិច្ឆេទសំខាន់ៗអំពីប្រវត្តិ (CSX)៖

- **ថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ២០០៦៖** ធ្វើការចុះអនុស្សរណៈយោគយល់អំពីការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

[17] www.csx.com.kh/kh ប្រវត្តិ ផ.ម.ក (ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២)

- **ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧៖** ការដាក់ឱ្យដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា។
- **ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨៖** ការចុះអនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។
- **ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩៖** ការចុះកិច្ចព្រមព្រៀង "ក្រុមហ៊ុនចម្រុះ" រវាងរាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- **ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០៖** បានចុះបញ្ជីពាណិជ្ជកម្ម
- **ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១៖** ការទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារប្រតិបត្តិករប្រព័ន្ធ-ជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រពី គ.ម.ក.
- **ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១៖** ការសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាប្រារព្ធឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួង-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។
- **ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២៖** ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា។

### ២.១.២. រូបសញ្ញា និងនាមករណ៍របស់ CSX

**រូបសញ្ញា ឬនិមិត្តសញ្ញារបស់ CSX**




រូបភាពទី១៖ រូបសញ្ញាផ្សារមូលបត្រកម្ពុជា

ប្រភព៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(ដកស្រង់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២)

- ផ្នែកខាងលើ មានអក្សរពណ៌ខៀវដាក់ថា "ផ្សារមូលបត្រកម្ពុជា" ដែលជាឈ្មោះតំណាងក្រុមហ៊ុនដែលហៅកាត់ថា "ផ.ម.ក" ។
- ផ្នែកខាងស្តាំ មានរូបហង្សពណ៌មាសមួយ ឈរបែរមុខទៅស្តាំ។

- ផ្នែកខាងឆ្វេង មានអក្សរពណ៌ខៀវជាភាសាអង់គ្លេសថា "CSX" ដែលជាអក្សរកាត់មកពីពាក្យថា Cambodia Securities Exchange ។

**នាមករណ៍**

រូបសញ្ញារបស់ក្រុមហ៊ុនមាននាមករណ៍ជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា ផ.ម.ក និងមានភាសាអង់គ្លេសជា Cambodia Securities Exchange ដែលហៅកាត់ថា CSX ។

### ២.១.៣. រចនាសម្ព័ន្ធរបស់ CSX




រូបភាពទី ២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ CSX

ប្រភព៖ www.csx.com.kh ( ដកស្រង់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២ )

- ក្រុមប្រឹក្សាភិបាលនៃ CSX រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់រដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុសប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។
- សមាជិកចំនួន ៤ រូបផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

[18]សមាជិកក្រុមប្រឹក្សាភិបាលទាំង ៧រូបមាន៖

- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប៖** ជាប្រធានក្រុមប្រឹក្សាភិបាល និងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **ឯកឧត្តម ហុង សុហួរ៖** ជាសមាជិក និងជាប្រតិភូរាជរដ្ឋាភិបាលអគ្គនាយកនៃក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា
- **Mr. KIM KYEONGHACK៖** ជាអនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយករងនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- **ឯកឧត្តម អ៊ូ ចាន់តារា៖** ជាសមាជិក និងជាអគ្គលេខាធិការនៃធនាគារជាតិនៃកម្ពុជា
- **លោក ហ៊ឹម ហ៊ាន៖** ជាសមាជិក និងទីប្រឹក្សាក្រសួងពាណិជ្ជកម្ម
- **Mr. YI BUYEON៖** ជាសមាជិក
- **Mr. WE SAE YOUN៖** ជាសមាជិក។

## ២.២. ចក្ខុវិស័យ និងបេសកកម្មរបស់ CSX

ចក្ខុវិស័យរបស់ CSX គឺ “ដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា” មានន័យថាធ្វើឱ្យវិស័យហិរញ្ញវត្ថុនៅកម្ពុជាមានដំណើរការប្រព្រឹត្តិទៅយ៉ាងល្អ។

បេសកម្មចម្បងរបស់ CSX រួមមាន៖

- បង្កើតឡើងនូវបរិយាកាសជួញដូរដែលប្រកបដោយភាពយុត្តិធម៌ តម្លាភាព និងភាពមានអំណោយផលដល់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក។
- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា។
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រ ដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក។
- ដើម្បីបង្កើតផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់។
- ដើម្បីដាក់ឱ្យដំណើរការនូវសហគ្រាសជាសាធារណៈមួយ ដែលមានស្វ័យចីរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រដ្ឋាភិបាលកម្ពុជា។

[18] www.csx.com.kh/kh ក្រុមប្រឹក្សាភិបាល (ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២)

## ២.៣. ប្រតិបត្តិករទាំង៣របស់ CSX

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានផ្តល់ការអនុញ្ញាតឱ្យធ្វើជាការប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា ក្រោម [19]ប្រកាសលេខ ០១១ គ.ម.ក. ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩។

- **ប្រតិបត្តិករទីផ្សារមូលបត្រ៖** មានតួនាទីផ្តល់នូវសេវាសម្របសម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរបញ្ជាទិញ និងលក់មូលបត្ររបស់ខ្លួន តាមទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក និងសកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។
- **ប្រតិបត្តិករផាត់ទាត់ និងទូទាត់មូលបត្រ៖** មានតួនាទីផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូរទាត់ថ្លៃទំនិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។
- **ប្រតិបត្តិកររក្សាទុកមូលបត្រ៖** បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ៖
  ១. កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតក្នុងនាមជាអតិថិជន ឬជាបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
  ២. ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមជាអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
  ៣. ផ្តល់សេវាកម្ម និងលក្ខណៈ ងាយស្រួលផ្សេងៗទៀត ដែលទាក់ទិននឹងការផ្តល់សេវាកម្ម ដូចមានចែងក្នុងកថាខណ្ឌ(១) និង(២)។

[19] ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិការទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩

## ២.៤. ក្រុមហ៊ុនបានចុះបញ្ជីនៅ CSX

នាពេលមួយរយៈនេះនៅផ្សារមូលបត្រកម្ពុជាមានក្រុមហ៊ុនដែលបានចុះបញ្ជីចំនួន ៩ក្រុមហ៊ុនក្នុងមាន ដូចជា៖

តារាងទី២៖ ក្រុមហ៊ុនចុះបញ្ជី

| | | |
|---|---|---|
| PWSA | GTI | PPAP |
| PPSP | PAS | ABC |
| PEPC | DBDE | JSL |

ប្រភព៖ phsarhun.com/companies (ដកស្រង់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២)

យើងក៏អាចចូលទៅក្នុងគេហទំព័រផ្សារហ៊ុនបានផងដែរ ដើម្បីដឹងពីព័ត៌មានអំពីក្រុមហ៊ុនចុះបញ្ជីនីមួយៗ ក៏ដូចជាគោលដៅ និងចក្ខុវិស័យរបស់ក្រុមហ៊ុនផ្ទាល់។

## ២.៥. សមាជិករបស់ CSX

### ២.៥.១. ក្រុមហ៊ុនធានាទិញមូលបត្រ

តារាងទី៣៖ បញ្ជីក្រុមហ៊ុនធានាទិញមូលបត្រ

| ស្លាកសញ្ញាក្រុមហ៊ុន | ឈ្មោះរបស់ក្រុមហ៊ុន | គេហទំព័រក្រុមហ៊ុន |
|---|---|---|
| | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | pps.com.kh |
| | អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក<br>RHB Indochina Securities PLC. | www.rhbgroup.com.kh |
| | កាណា ស៊ីឃ្យូរីធី អិលធីឌី<br>Cana Securities Ltd. | canasecurities.com.kh |
| | កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Campu Securities Plc. | www.campusecurities.com.kh |
| | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី<br>Yuanta Securities (Cambodia) Plc. | www.yuantacambodia.com |
| | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី<br>SBI Royal Securities Plc. | sbiroyal.com/jp/home-jp/ |
| | ខេមបូឌា ស៊ីឃ្យូរីធី ម.ក<br>CAMBODIA SECURITIES PLC. | cambodiasecurities.com |

ប្រភព៖ phsarhun.com/brokers (ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)

### ២.៥.២. ក្រុមហ៊ុនឈ្នួញជើងសារមូលបត្រ

តារាងទី៤៖ បញ្ជីក្រុមហ៊ុនឈ្នួញជើងសារ

| ស្លាកសញ្ញាក្រុមហ៊ុន | ឈ្មោះរបស់ក្រុមហ៊ុន | គេហទំព័រក្រុមហ៊ុន |
|---|---|---|
| CVS | ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី<br>Cambodia-Vietnam Securities Plc. | www.cvs.com.kh/ |
| អេស៊ីលីដា ACLEDA SECURITIES | អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី<br>Acleda Securities Plc. | www.acledasecurities.com.kh/as/khm/ |
| CAB SECURITIES ខេប ស៊ីឃ្យូរីធី លីមីតធីត CAB SECURITIES LIMITED | ខេប ស៊ីឃ្យូរីធី លីមីតធីត<br>Cab Securities Limited. | www.cab.com.kh |
| GFS 金运证券 GOLDEN FORTUNE SECURITIES | ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី<br>Golden Fortune (Cambodia) Securities Plc. | www.goldenfortune.com.kh/EN |
| PP Link Securities | ភីភី លីង ស៊ីឃ្យូរីធី ឯ.ក<br>PP Link Securities Co., Ltd. | www.pplinksecurities.com |

ប្រភព៖ phsarhun.com/brokers (ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)

## ២.៦. អ្នកចូលរួមរបស់ CSX

### ២.៦.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

តារាងទី៥៖ បញ្ជីភ្នាក់ងារទូទាត់សាច់ប្រាក់

| ស្លាកសញ្ញាក្រុមហ៊ុន | ឈ្មោះរបស់ក្រុមហ៊ុន | គេហទំព័រក្រុមហ៊ុន |
|---|---|---|
| អេស៊ីលីដា ACLEDA BANK | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | www.acledabank.com.kh/kh/eng/ |
| BIDC Bank BANK FOR INVESTMENT AND DEVELOPMENT OF CAMBODIA PLC. | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី<br>Bank For Investment And Development Of Cambodia Plc. | www.bidc.com.kh |
| ធនាគារ កាណាឌីយ៉ា 加華銀行 CANADIA BANK | ធនាគារកាណាឌីយ៉ា<br>Canadia Bank Plc. | www.canadiabank.com.kh |
| ធនាគារកម្ពុជាសាធារណៈ CAMBODIAN PUBLIC BANK 柬埔寨大众银行 | ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី<br>Cambodian Public Bank Plc. | www.cpbebank.com/Home |

ប្រភព៖ phsarhun.com (ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)

### ២.៦.២. ភ្នាក់ងារបញ្ជិការមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

តារាងទី៦៖ បញ្ជីភ្នាក់ងារបញ្ជិការមូលបត្រ និងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

| ស្លាកសញ្ញាក្រុមហ៊ុន | ឈ្មោះរបស់ក្រុមហ៊ុន | គេហទំព័រក្រុមហ៊ុន |
|---|---|---|
| អេស៊ីលីដា ACLEDA BANK | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | www.acledasecurities.com.kh/as/khm/ |
| tricor | ត្រាយខ័រ ស៊ីឃ្យូរីធី សឺវិស ភីអិលស៊ី<br>Tricor Securities Services Plc. | www.tricorglobal.com |
| PPS ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី PHNOM PENH SECURITIES PLC. 金邊證券 | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | www.pps.com.kh |

ប្រភព៖ csx.com.kh (ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)

### ២.៦.៣. ភ្នាក់ងារទូទាត់

តារាងទី៧៖ បញ្ជីភ្នាក់ងារទូទាត់

| ស្លាកសញ្ញាក្រុមហ៊ុន | ឈ្មោះរបស់ក្រុមហ៊ុន | គេហទំព័រក្រុមហ៊ុន |
|---|---|---|
| អេស៊ីលីដា ACLEDA BANK | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | www.acledasecurities.com.kh/as/khm/ |
| PPS ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី PHNOM PENH SECURITIES PLC. 金邊證券 | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី<br>Phnom Penh Securities Plc. | www.pps.com.kh |

ប្រភព៖ csx.com.kh (ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)

## ២.៧. ព័ត៌មានអំពី CSX

អាសយដ្ឋាន ៖ អគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ៖ ០២៣ ៩៥៨ ៨៨៨

ទូរសារ ៖ (៨៥៥) ២៣ ៩៥៥ ៥៥៨

ក្រសួង និងស្ថាប័នពាក់ព័ន្ធ ៖ info@csx.com.kh

គេហទំព័រ ៖ www.csx.com.kh

ហ្វេសបុកផេក ៖ www.facebook.com/cambodia.csx

# ជំពូកទី ៣
# ដំណើរការនៃការវិនិយោគ

# ជំពូកទី ៣

# ដំណើរការនៃការវិនិយោគ

## ៣.១. ដំណើរការនៃការវិនិយោគលើទីផ្សារមូលបត្រកម្ពុជា

ពេលយើងឈានមកដល់ចំណុចមួយនេះ យើងនឹងនិយាយអំពីការដំណើរវិនិយោគលើផ្សារមូលបត្រ-កម្ពុជា។ រួមជាមួយគ្នានេះផងដែរ មុននឹងវិនិយោគិនអាចចូលក្នុងទីផ្សារដើម្បីធ្វើការជួញដូរបានវិនិយោគិនត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID) បើកគណនីជួញដូរ និងការដាក់បញ្ជា។

### ៣.១.១. ការជ្រើសរើសក្រុមហ៊ុនចុះបញ្ជី

#### ៣.១.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

ជាជំហានដំបូងមុន វិនិយោគិនត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្រណាមួយដែលយើងគិតថាល្អ ហើយសាកសមក្នុងការវិនិយោគរបស់យើង។ ដើម្បីស្វែងរកក្រុមហ៊ុនមូលបត្រទាំងនោះបាន ដោយយើងគ្រាន់តែចូលទៅក្នុងគេហទំព័ររបស់ CSX (csx.com.kh/main.do) ឬក៏គេហទំព័រមួយទៀតមានឈ្មោះថា “ផ្សារហ៊ុន” (phsarhun.com/brokers) ដែលក្នុងនោះមានជាព័ត៌មានលម្អិត និងមានលេខទំនាក់ទំនងផ្សេងៗ។ យើងអាចមើលលើចំណុច ២ មុននឹងជ្រើសរើសក្រុមហ៊ុនមូលបត្រណាមួយៈ

ទី១. តម្លៃ៖ ថាតើក្រុមហ៊ុនមូលបត្រណាមួយយកដែលយកកម្រៃជើងសារសមរម្យ។

ទី២. សេវាកម្ម៖ ថាតើសេវាកម្មរបស់ក្រុមហ៊ុនមូលបត្រនោះមានសេវាកម្មល្អកម្រិតណា។

#### ៣.១.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID)

បន្ទាប់មកទៀតវិនិយោគិនត្រូវធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពី គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។ [20]ការស្នើសុំនេះអាចធ្វើឡើងបាន ២ របៀបគឺ៖

- ស្នើសុំដោយផ្ទាល់ពី គ.ម.ក.៖ បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. អាចធ្វើឡើងដោយផ្ទាល់ដោយមក គ.ម.ក.។
- ស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ៖ បុគ្គលអាចដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។

[20] ប្រកាសស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២

ជាទូទៅយើងគួស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រល្អជាង ហើយមានភាពងាយស្រួល និងចំណេញពេលវេលាដោយរៀបចំឯកសារមួយចំនួនតាមតម្រូវការរបស់ក្រុមហ៊ុនមូលបត្រជាការស្រេច។ [21] អំឡុងពេលស្នើសុំនោះវិនិយោគិនត្រូវត្រៀមនូវឯកសារមួយចំនួនដូចខាងក្រោម ដែលសម្រាប់វិនិយោគិនជារូបវន្តបុគ្គលទៅកាន់ គ.ម.ក.៖

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ( ទម្រង់ ក ) ដោយមានបិទរូបថត ដែលថតពីមុខ ទំហំ ៤ x ៦ មួយសន្លឹក។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។
- លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនជាសញ្ជាតិខ្មែរ។
- ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
- [22]ថវិកាចំនួន ២មឿនរៀល។

✦ បញ្ជាក់៖ រយៈពេលក្នុងការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនអាចមានរយៈដល់ទៅ ១ សប្តាហ៍ក្នុងសម្រាប់ដំណើរការ។ ដូច្នេះវិនិយោគិនត្រូវគិតគូពីពេលវេលាផងដែរក្នុងករណីមើលឃើញឱកាសភាគហ៊ុនមានតម្លៃល្អ។

### ៣.១.១.៣. ការបើកគណនីជួញដូរ

បន្ទាប់ពីយើងស្នើសុំលេខអត្តសញ្ញាណវិនិយោគិនបានសម្រេច យើងត្រូវទៅបើកគណនីជួញដូរជាមួយនឹងធនាគារជាដៃគូរបស់ក្រុមហ៊ុនមូលបត្រ (Broker) ដែលយើងបានជ្រើសរើស។ ការបើកគណនីជួញដូរមានភាពងាយស្រួល និងមានភាពឆាប់រហ័សមិនចំណាយពេលយូរ ដោយធ្វើឡើងតាមរយៈប្រព័ន្ធធនាគារសម័យទំនើប។ ជាធម្មតានៅពេលយើងទៅដាក់ប្រាក់ យើងត្រូវប្រាប់ធនាគារដែលជាដៃគូពី ឈ្មោះក្រុមហ៊ុនមូលបត្រ លេខអត្តសញ្ញាណវិនិយោគិន ឈ្មោះគណនី និងលេខគណនី ដើម្បីឱ្យធនាគារដាក់ប្រាក់របស់យើងចូលក្នុងគណនីជួញដូរនោះ។

✦ បញ្ជាក់៖ វិនិយោគិនម្នាក់អាចបើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្របានតែមួយគត់។

[21] គោលការណ៍ណែនាំស្តីពី ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រទី២

[22] ប្រកាសស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២

### ៣.១.១.៤. ការបើកគណនីសាច់ប្រាក់

ទន្ទឹមនឹងការបើកគណនីជួញដូរយើងក៏អាចបើកគណនីសាច់ប្រាក់ផងដែរ ដើម្បីបង្កភាពងាយស្រួលដល់ការផ្ទេរប្រាក់ពីធនាគារមួយទៅធនាគារមួយទៀត ជាជាងទៅដាក់ប្រាក់ក្នុងគណនីជួញដូរដោយផ្ទាល់។ មួយវិញទៀតការបើកគណនីជួញដូរនេះមិនតម្រូវឱ្យវិនិយោគិនដាច់ខាតត្រូវតែដាក់ប្រាក់ក្នុងគណនីនោះទេ វិនិយោគិនអាចដាក់ពេលដែលមានតម្រូវការជួញដូរភាគហ៊ុនក៏បាន។ ឧទាហរណ៍៖ បើសិនជាយើងជ្រើសរើសក្រុមហ៊ុនមូលបត្រ RHB Securities ជាក្រុមហ៊ុនជើងសាររបស់យើងនោះយើងត្រូវទៅរកធនាគារ កាណាឌីយ៉ាដែលជាធនាគាដៃគូសហកាជាមួយនឹងក្រុមហ៊ុនមូលបត្ររបស់យើង ដោយសារតែធនាគាកាណាឌីយ៉ាមានដៃគូជាមួយក្រុមហ៊ុនមូលបត្រច្រើនទៀត ហេតុនេះយើងត្រូវប្រាប់ពីឈ្មោះក្រុមហ៊ុនមូលបត្រ RHB Securities ដល់ធនាគារ។

- បញ្ជាក់ ៖ សាច់ប្រាក់ដែលវិនិយោគិនដាក់គឺនៅក្នុងធនាគារមិនមែនក្រុមហ៊ុនមូលបត្រជាអ្នកកាន់កាប់សាច់ប្រាក់វិនិយោគិននោះឡើយ។ ការធ្វើបែបនេះដើម្បីជៀសវាងពីហានិភ័យក្នុងការបាត់វត្ថុមានរបស់ក្រុមហ៊ុនមូលបត្រ។

រូបភាពទី៣៖ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

| អេស៊ីលីដា ACLEDA BANK | BIDC Bank BANK FOR INVESTMENT AND DEVELOPMENT OF CAMBODIA PLC. | ធនាគារ កាណាឌីយ៉ា 加華銀行 CANADIA BANK | ធនាគារកម្ពុជាសាធារណៈ CAMBODIAN PUBLIC BANK 柬埔寨大众银行 |
|---|---|---|---|
| Yuanta Securities (Cambodia) | Cambodia – Vietnam Securities | Phnom Penh Securities | Campu Securities |
| Acleda Securities | | RHB Securities | |
| | | Canadia Securities | |
| | | SBI Royal Securities | |
| | | Golden Fortune (Cambodia) Securities | |
| | | Cab Securities | |

ប្រភព៖ CSX.com.kh មូលដ្ឋានគ្រឹះនៃការវិនិយោគទីផ្សារមូលបត្រកម្ពុជា (ដក់ស្រង់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២)

### ៣.១.១.៥. ការដាក់បញ្ជា

ឈានមកចំណុចនេះ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ ឬលក់ក្នុងទីផ្សារមូលបត្របានហើយ។ ដោយឡែកវិនិយោគិនត្រូវមានសាច់ប្រាក់យ៉ាងហោច ១០០% (សម្រាប់បញ្ជាទិញ) ដែលមានរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោច ១០០% (សម្រាប់លក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។

រូបភាពទី៤៖ ដំណើរកាដាក់បញ្ជារនៅក្នុងទីផ្សារមូលបត្រ




ដំណើរការនៃការដាក់បញ្ជានេះផ្តើមចេញពីវិនិយោគិន ដោយដាក់បញ្ជាទៅឱ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួន បន្ទាប់មកក្រុមហ៊ុនមូលបត្រនោះនឹងធ្វើការបញ្ជូនបញ្ជាបន្តទៅកាន់ផ្សារមូលបត្រ រួចមកផ្សារមូលបត្រនឹងធ្វើការផ្គូរផ្គង ហើយផ្តល់ដំណឹងដល់ក្រុមហ៊ុនមូលបត្រ ចុងក្រោយក្រុមហ៊ុននឹងផ្តល់ដំណឹងមកកាន់វិនិយោគិនវិញ។ ការជួញដូរត្រូវបានធ្វើឡើងនូវលើប្រព័ន្ធជួញដូរចល័ត MTS របស់ផ្សារមូលបត្រ និយាយឱ្យងាយយល់គឺគេជួញដូរលើគេហទំព័រ MTS របស់ផ្សារមូលបត្រ។ ប្រព័ន្ធនេះជួញដូរចល័ត MTS អាចឱ្យយើងជួញដូរបានគ្រាប់ទីកន្លែង។

រូបភាពខាងក្រោមនេះជាការសង្ខេបពីដំណើរការក្នុងទីផ្សារមូលបត្រចាប់ពី ការបើកគណនីរហូតដល់ការបញ្ជាទិញ ឬលក់បានសម្រេច៖

រូបភាពទី៥៖ ដំណើរការជួញដូរនៅក្នុងទីផ្សារមូលបត្រ




ប្រភព៖ csx.com.kh/operation (ដកស្រង់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២)

១. វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រមុនថ្ងៃជួញ-ដូរមួយថ្ងៃ(T-១)។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

២. វិនិយោគិនដាក់បញ្ជាទិញ ឬលក់នៅថ្ងៃបានគណនីជួញដូរ (T+0) តាមប្រព័ន្ធជួញដូរចល័ត(MTS) ឬក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី(ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) សារអេឡិចត្រូនិចផ្សេងៗ ឬមធ្យោបាយអេឡិចត្រូនិចនានា។

៣. បន្ទាប់ពីដាក់បញ្ជាមកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0 បានជោគជ័យដោយមានមូលបត្រ និងសាច់ប្រាក់គ្រប់គ្រាន់ នៅក្នុងគណនីរបស់វិនិយោគិន សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅ២ថ្ងៃក្រោយការជួញដូរ (T+២)។

៤. ការដាក់បញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃនិងតាមវគ្គជួញដូររបស់ ផ.ម.ក. ដែលបានកំណត់ទុកជាមុន ។

៥. ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរវិញនៅថ្ងៃជួញដូរ (T+0)។

៦. ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅក្នុងថ្ងៃជួញដូរនោះ (T+0) ។

៧. ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃជួញដូរ (T+១)។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

៨. វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅ២ថ្ងៃក្រោយការជួញដូរ (T+២)។

៩. ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក.។

### ៣.១.២. វិធានប្រតិបត្តិការជួញដូរនៅលើទីផ្សារ

#### ៣.១.២.១. វគ្គជួញដូរ

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងជួញដូរ | វិធីសាស្ត្រដេញថ្លៃ |
|---|---|---|---|
| វគ្គបើក | ៨: 00 - ៩: 00 | ៩: 00 | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩: 00 - ២: ៥0 រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ២: ៥0 រសៀល | ៣: 00 រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

**ថ្ងៃជួញដូរ** គឺចាប់ពីថ្ងៃ ច័ន្ទ ដល់ សុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

**ម៉ោងជួញដូរ** គឺចែកចេញជា ៣ វគ្គ៖

- វគ្គបើក៖ ពីម៉ោង ៨ព្រឹក ដល់ ៩ព្រឹក (ទទួលបញ្ជាតែមិនទាន់ធ្វើការផ្គូរផ្គងទេ)។ ម៉ោង៩ព្រឹកទើបចាប់ផ្តើមផ្គូរផ្គងបញ្ជា ដោយអនុវត្តវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ។

- វគ្គនិរន្តរ៍៖ ពីម៉ោង ៩ព្រឹក ដល់ ២:៥០រសៀល ជាពេលដែលខាងផ្សារមូលបត្រផ្គូរផ្គងរាល់ការបញ្ជានាពេលនោះតែម្តង ដោយអនុវត្តវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន។
- វគ្គបិទ៖ ពីម៉ោង ២:៥០រសៀល ដល់ ៣រសៀល ( ទទួលបញ្ជាតែមិនទាន់ធ្វើការផ្គូផ្គងទេ ) ដល់ម៉ោង ៣រសៀលទើបធ្វើការផ្គូរផ្គង ដោយអនុវត្តវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ។

ចំណាំ៖ ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូរផ្គងនៅក្នុងថ្ងៃដដែល។

### ៣.១.២.២. ការបញ្ជា

ចំពោះការបញ្ជាក្នុងផ្សារមូលបត្រមានចំនួន ៣ ប្រភេទដូចជា៖ បញ្ជាដែនកំណត់ បញ្ជាទីផ្សារ បញ្ជាតាមការចរចារ។ ដោយឡែកបច្ចុប្បន្នគេធ្វើការបញ្ជាតែមួយប្រភេទប៉ុណ្ណោះគឺ បញ្ជាដែនកំណត់ (Limit Order) ដែលប្រើក្នុងប្រព័ន្ធជួញដូរចល័ត (MTS)។

បញ្ជាដែនកំណត់ (Limit Order)៖ ជាបញ្ជាដែលថ្លៃបញ្ជាទិញគឺជាថ្លៃដែលហ៊ានទិញខ្ពស់បំផុត ហើយថ្លៃបញ្ជាលក់គឺជាថ្លៃដែលហ៊ានលក់ទាបបំផុត។ ឧទាហរណ៍៖ ក្នុងការបញ្ជាដែនកំណត់ទិញដែលមានតម្លៃ ៦.០០០រៀល ឬទាបជាងនេះ ចំណែកបញ្ជាដែនកំណត់លក់ដែលមានតម្លៃ ៦.០០០រៀល ឬខ្ពស់ជាងនេះ។

### ៣.១.២.៣. វិធីសាស្ត្រជួញដូរ

ដូចដែលបានបង្ហាញពីខាងលើផ្សារមូលបត្រនឹងធ្វើតាមគោលការណ៍ដេញថ្លៃ។ ក្នុងនោះមានវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើនក្នុងករណីបញ្ជាដែនកំណត់ (Limit Order) ការដេញថ្លៃនេះយោងទៅតាមអាទិភាពថ្លៃ និងអាទិភាពពេលវេលា។

- **អាទិភាពថ្លៃ៖** បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង និង បញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។
- **អាទិភាពពេលវេលា៖** ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | : | |
| | ៦.៥០០ | ①៥០០(បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង) |
| | ៦.៤៨០ | ②១០០ ③២០០ |
| | ៦.៤៦០ | |
| ③៣០០ ②២០០ | ៦.៤២០ | |
| (បញ្ជាលក់ដែលមានថ្លៃទាបជាង) ①៤៥០ | ៦.៤០០ | |
| | : | |

* ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ ① និងបញ្ជាលក់ ① ត្រូវអនុវត្តការជួញដូរមុន យោងទៅតាមអាទិភាពថ្លៃ។

* ក្នុងចំណោមបញ្ជាដែលមានថ្លៃដូចគ្នា បញ្ជា ② ដែលទទួលបានមុន នឹងត្រូវអនុវត្តការជួញដូរមុនបញ្ជា ②។

### គ. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

បញ្ជាដែនកំណត់លក់ត្រូវបានផ្គូរផ្គងនៅថ្លៃបញ្ជា ( លក់ )នោះ ឬខ្ពស់ជាង ចំពោះបញ្ជាដែនកំណត់ទិញត្រូវបានផ្គូរផ្គងនៅថ្លៃបញ្ជា ( ទិញ )នោះ ឬទាបជាង។

**ឧទាហរណ៍ទី១៖** បើថ្លៃផ្គូរផ្គងមានតែមួយ

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៧.៥០០ | |
| ① ~~៣០០~~ | ៧.៤០០ | ~~៧០០~~ ៥០ |
| ③ ~~៥០~~ ② ~~២០០~~ | ៧.៣០០ | |
| ④ ~~១០០~~ | ៧.២០០ | |
| **៦៥០** | **សរុប** | **៧០០** |

* ថ្លៃជួញដូរគឺ ៧.៤០០ ៛ ហើយបរិមាណចំនួន ៦៥០ ភាគហ៊ុន នឹងត្រូវបានជួញដូរ។

* តម្លៃជួញដូរ = បរិមាណជួញដូរ x ថ្លៃជួញដូរ ឬ ៦៥០ x ៧.៤០០ ៛ = ៤.៨១០.០០០ ៛

**ឧទាហរណ៍ទី២៖** បើថ្លៃផ្គូរផ្គងលើសពីមួយ

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៧.៥០០ | ~~៧០០~~ |
| | ៧.៤០០<br>(ថ្លៃចុងក្រោយ) | |
| ③ ~~១០០~~ ② ~~៣០០~~ | ៧.៣០០ | |
| ① ~~៣០០~~ | ៧.២០០ | |
| **៧០០** | **សរុប** | **៧០០** |

* ថ្លៃផ្គូរផ្គងដែលអាចយកជាថ្លៃជួញដូរបាន៖ ថ្លៃពី ៧.៣០០៛ ដល់ ៧.៥០០៛។

* នៅពេលមានថ្លៃផ្គូរផ្គងច្រើន នោះថ្លៃជួញដូរគឺជាថ្លៃចុងក្រោយ ឬថ្លៃដែលនៅកៀកជាងគេធៀបនឹងថ្លៃចុងក្រោយ ។ ដូច្នេះ ថ្លៃជួញដូរ គឺ៧.៤០០ ៛ ( សន្មតថាជាថ្លៃចុងក្រោយ ) ហើយបរិមាណចំនួន៧០០ភាគហ៊ុន នឹងត្រូវបានជួញដូរ។

* តម្លៃជួញដូរ = បរិមាណជួញដូរ x ថ្លៃជួញដូរ ឬ ៧០០ x ៧.៤០០ ៛ = ៥.១៨០.០០០ ៛

### ខ. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

វិធីសាស្ត្រនេះត្រូវបាន CSX អនុវត្តក្នុងវគ្គនិរន្តរ៍ ដោយធ្វើការផ្គូរផ្គងភ្លាមៗបើសិនជាមានបញ្ជាដែលអាចផ្គូរផ្គងបាន (យោងតាមអាទិភាពថ្លៃ និងអាទិភាពពេលវេលា)។

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៦.៥០០ | |
| ③១០០ ②៣០០ | ៦.៤០០ | ~~៧០០~~ ១០០ |
| ①២០០ | ៦.៣០០ | |
| | ៦.២០០ | |
| ៦០០ | សរុប | ៧០០ |

* តម្លៃជួញដូរ៖

២០០ x ៦.៣០០ ៛ = ១.២៦០.០០០ ៛ (ភ្លាមៗ)

៤០០ x ៦.៤០០ ៛ = ២.៥៦០.០០០ ៛ (ភ្លាមៗ)

សរុប = ៣.៨២០.០០០ ៛

### គ. លក្ខណៈរបស់ផ្សារភាគហ៊ុន

ស្របពេលជាមួយគ្នាផងដែរ យើងត្រូវយល់ដឹងបន្ថែមពីលក្ខណៈសំខាន់ៗដែលមានក្នុងផ្សារភាគហ៊ុន។ ក្នុងនោះមានដូចជា ថ្លៃមូលដ្ឋាន ដែនកំណត់ថ្លៃប្រចាំថ្ងៃ ឯកតាបញ្ជា និងឯកតាគម្លាតថ្លៃ។

- ថ្លៃមូលដ្ឋាន

ជាថ្លៃគោលដែលប្រើប្រាស់សម្រាប់គណនាដែនកំណត់ថ្លៃប្រចាំថ្ងៃ។ យើងអាចនិយាយម្យ៉ាងទៀតបានថាជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ (ថ្លៃកាលពីម្សិលមិញ)។ ក្នុងនោះផងដែរថ្លៃមូលដ្ឋានជួញដូរសម្រាប់មូលបត្រ-កម្មសិទ្ធិចុះបញ្ជីលើកដំបូងស្ថិតនៅចន្លោះពី ៩០% ដល់ ១៥០% នៃថ្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង (IPO)។

ឧទាហរណ៍៖ ថ្លៃ IPO = ១០.០០០រៀល

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ (៥០%) | ១៥.០០០ | |
| | : | |
| | ១០.០០០ | ថ្លៃ IPO |
| ដែនកំណត់ថ្លៃខាងក្រោម (១០%) | ៩.០០០ | |

* ១០.០០០ x ៥០% = ៥.០០០ និង ១០.០០០ x ១០% = ១.០០០

ដែនកំណត់ខាងលើ ១០.០០០ + ៥.០០០ = ១៥.០០០

ដែនកំណតខាងក្រោម ១០.០០០ - ១.០០០ = ៩.០០០

- ដែនកំណត់ថ្លៃប្រែប្រួលប្រចាំថ្ងៃ

[23] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ឱ្យដំណើរការដែនកំណត់ថ្លៃប្រចាំថ្ងៃចាប់ពីចន្លោះ បូក ឬដក ១០% ប៉ុណ្ណោះក្នុងមួយថ្ងៃ។ ដែនកំណត់ប្រែប្រួលថ្លៃនេះជាការកែប្រែថ្មីដោយយោងតាមប្រកាសរបស់គណៈ-កម្មាធិការមូលបត្រកម្ពុជា ដែលបានដាក់ប្រើនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨។

ឧទាហរណ៍៖ ថ្លៃមូលដ្ឋាន = ៦.០០០រៀល

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ(១០%) | ៦.៦០០ | |
| | : | |
| | ៦.០០០ | ថ្លៃមូលដ្ឋាន |
| | : | |
| ដែនកំណត់ថ្លៃខាងក្រោម(១០%) | ៥.៤០០ | |

* ៦.០០០ x ១០% = ៦០០

ដែនកំណត់ខាងលើ ៦.០០០ + ៦០០ = ៦.៦០០

ដែនកំណត់ខាងក្រោម ៦.០០០ - ៦០០ = ៥.៤០០

- ឯកតាបញ្ជា និងឯកតាគម្លាតថ្លៃ

នៅក្នុងផ្សារមូលបត្រកម្ពុជាឯកតាបញ្ជាទិញ ឬលក់ចាប់ពី ១(មួយ)ឯកតាឡើងទៅ។

ចំពោះឯកតាគម្លាតថ្លៃភាគហ៊ុននៅផ្សារមូលបត្រកម្ពុជា អាស្រ័យលើឯកតាគម្លាតតម្លៃដែលបានកំណត់ដូចខាងក្រោម៖

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| P < ៤.០០០ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៩០ |
| ៤.០០០ ≤ P < ២០.០០០ | ២០ | ៤.២១០; ១៩.៥២៥ | ៤.២០០; ៤.២២០; ១៩.៥២០; ១៩.៥៤០ |
| ២០.០០០ ≤ P < ៤០.០០០ | ៥០ | ២០.១១០; ៣៥.៥៣០ | ២០.១០០; ២០.១៥០; ៣៥.៥០០; ៣៥.៥៥០ |
| ៤០.០០០ ≤ P < ១០០.០០០ | ១០០ | ៥០.៧២០; ៩០.៤៥០ | ៥០.៧០០; ៥០.៨០០; ៩០.៤០០; ៩០.៥០០ |
| ១០០.០០០ ≤ P < ២០០.០០០ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៤០០; ១៥០.៦០០; ១២៥.២០០; ១២៥.៤០០ |
| ២០០.០០០ ≤ P < ៤០០.០០០ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| P ≥ ៤០០.០០០ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

[23] វិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាសម្រេចថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ជំពូកទី២៖ លក្ខខណ្ឌនៃការជួញដូរមូលបត្រកម្មសិទ្ធិ "ប្រការ១៦ និងប្រការ១៧") ១២-១៣

ការដាក់បញ្ជារបស់វិនិយោគិនទាំងឡាយត្រូវគោរពតាមឯកតាគម្លាតថ្លៃខាងលើ ដើម្បីឱ្យការបញ្ជាមានភាពងាយស្រួល។ ចំពោះរាល់ដែនកំណត់ថ្លៃប្រែប្រួលប្រចាំថ្ងៃវិញ ក្នុងករណីការតម្លៃនោះក្រោយប្រែប្រួលមានតម្លៃមានមិនគត់ (៦០២រៀល នាំឱ្យ៦០០រៀល) គេនឹងបង្គត់តម្លៃនោះ។

## ៣.២. អត្ថប្រយោជន៍នៃការវិនិយោគលើមូលបត្រ

ដូចដែលយើងបានដឹងហើយថាវិស័យមូលបត្រនេះនៅកម្ពុជាមានវត្តមានជាយូរដែរហើយ តែដោយសារកត្តាមួយចំនួនធ្វើឱ្យវិស័យនេះស្ថិតនៅកម្រិតលូតលាស់មួយដែលមានសភាពយឺតនៅឡើយ បើធៀបទៅនឹងប្រទេសគេ។ ទន្ទឹមនឹងនេះរដ្ឋាភិបាលក៏បានចូលរួមចំណែកជួយក្នុងវិស័យមូលបត្រនេះផងដែរ ដោយលើកទឹកចិត្តតាមរយៈពន្ធ។ មានន័យថាវិនិយោគិននឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីការវិនិយោគក្នុងមូលបត្រមិនត្រឹមតែពន្ធមួយមុខប៉ុណ្ណោះទេ។

### ៣.២.១. ចំពោះវិនិយោគិន

- **ចំណេញពីភាគលាភ**

ការទិញភាគហ៊ុនរបស់មួយចំនួននឹងទទួលបានភាគលាភប្រចាំឆ្នាំ ឬប្រចាំឆមាសទៅតាមក្រុមហ៊ុន។ ក្រុមហ៊ុននឹងបែងចែកប្រាក់ចំណេញដល់វិនិយោគិនរបស់ខ្លួន នៅពេលដែលក្រុមហ៊ុនទទួលបានចំណេញ។ ភាគលាបនោះអាចជាប្រាក់ ឬជាចំនួនហ៊ុន។

- **ចំណេញមូលធន (Capital gain)**

ភាគហ៊ុនក្នុងទីផ្សារតែងមានការថយចុះ និងកើនឡើង នៅពេលភាគហ៊ុនយើងកាន់ក្នុងដៃមានការកើនឡើងថ្លៃ នោះយើងនឹងទទួលបានចំណេញពីការលក់ភាគហ៊ុននោះ។ វិនិយោគិនជាទូទៅតែងតែដាក់ទុនលើក្រុមហ៊ុនច្រើនផ្សេងៗគ្នាដែលមានស្ថានភាពហិរញ្ញវត្ថុល្អដើម្បីជៀសវាងហានិភ័យ។

- **ទទួលបានចំណេញខ្ពស់**

វិនិយោគិនអាចទទួលបានផលចំណេញពីការវិនិយោគខ្ពស់ជាងការដាក់ប្រាក់តម្កល់ក្នុងធនាគារ ដែលផ្តល់ការប្រាក់ទាប ចំណាយពេលយូរ និងមានរយៈពេលកំណត់។ ការវិនិយោគលើភាគហ៊ុនអាចជាប្រភពចំណូលអកម្មមួយបែប ក្រៅពីចំណូលថេររបស់អ្នក។

- **កំណើនសេដ្ឋកិច្ច**

កំណើនសេដ្ឋកិច្ចតែងតែកើតមានរៀងរាល់ឆ្នាំ ចង់សម្តៅទៅដល់អតិផរណាដែលកើតមានរៀងរាល់ឆ្នាំ។ ការវិនិយោគលើវិស័យមូលបត្រអាចទទួលផលត្រលប់វិញជាអត្រាមួយ ដែលអាចនឹងមានកម្រិតខ្ពស់ជាងអត្រាកំណើនសេដ្ឋកិច្ចនាពេលខាងមុខ។

- **ការអនុគ្រោះពន្ធ**

នៅផ្សារមូលបត្រកម្ពុជាយើងពុំមានពន្ធកាត់ទុកសម្រាប់ វិនិយោគិនជនជាតិខ្មែរ ឬជនបរទេសដែលជានិវាសនជន ចំណែកឯជនបរទេសដែលជាអនិវាសនជនត្រូវកាត់បន្ថយអាត្រពន្ធកាត់ទុកចំនួន ៥០%។

- **ងាយស្រួលបម្លែង**

ការវិនិយោគក្នុងមូលបត្រមានភាពងាយស្រួលក្នុងការដាក់ទុន ឬដកទុន។ ដោយហេតុថាផ្សារមូលបត្រមានដំណើរការជួញដូរជាប្រចាំ ករណីវិនិយោគិនចង់បានសាច់ប្រាក់វិនិយោគិនគ្រាន់តែធ្វើការលក់មូលបត្រនោះក៏បានដែរមិនចំណាយពេលយូរ។

- **យុទ្ធសាស្ត្រចាកចេញ**

វិនិយោគិន អាចដកប្រាក់វិនិយោគរបស់ខ្លួនចេញ ដោយលក់មូលបត្រកម្មសិទ្ធិ នៅពេលដែលវិនិយោគិនឃើញថាក្រុមហ៊ុនមានស្ថានភាពមិនល្អ។ មួយវិញទៀត វិនិយោគិន អាចដកខ្លួនទៅវិនិយោគលើឧបករណ៍ផ្សេងទៀត ដែលមានផលចំណេញខ្ពស់។

### ៣.២.២. ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្នុងការចូលរួមជាមួយផ្សារមូលបត្រចំពោះក្រុមហ៊ុនដែលបានចុះបញ្ជី ឬបោះផ្សាយលក់មូលបត្ររបស់ខ្លួនក្នុងផ្សារមូលបត្រក៏និងទទួលបានអត្ថប្រយោជន៍ដូចជា៖

- **បង្កើនដើមទុន**

ក្រុមហ៊ុនបោះផ្សារមូលបត្រដើម្បីកៀរគរមូលធនក្នុងការអភិវឌ្ឍក្រុមហ៊ុន ឬគម្រោងនានា។ ការធ្វើបែបនេះក៏បានជួយដល់ក្រុមហ៊ុនកាត់បន្ថយការចំណាយពីការប្រាក់ ឬថ្លៃសេវាផ្សេងៗក្នុងករណីក្រុមហ៊ុនផ្ទេរដើមទុនពីក្រៅប្រទេស។

- **កាត់បន្ថយបំណុល**

ក្រុមហ៊ុនក៏អាចបោះផ្សាយភាគហ៊ុនលក់ដើម្បីប្រមូលដើមទុន ដោយពុំចាំបាច់ទៅខ្ចីប្រាក់ពីធនាគារឡើយដែលអាចនឹងប្រឈមនឹងអត្រាការប្រាក់ខ្ពស់។

- [24]**ការលើកទឹកចិត្តពន្ធ**

នេះគឺជាការលើកទឹកចិត្តសំខាន់មួយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដែលកំពុងសំឡឹងមើលការប្រមូលមូលនិធិ តាមរយៈការបោះផ្សាយ និងលក់ភាគហ៊ុននៅលើផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។ ក្រុមហ៊ុនទាំងអស់ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% ក្នុងរយៈពេលបីឆ្នាំ ដែលគោរពទៅតាមលក្ខខណ្ឌបានចែងក្នុងអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារ ក្នុងវិស័យមូលបត្រ។

- **កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន**

ការឈានជើងចូលផ្សារមូលបត្រមុនដំបូងគេជួយឱ្យត្រូវបានគេស្គាល់តាមរយៈ ការផ្សព្វផ្សាយក្នុងបណ្តាញផ្សេងៗដែលនាំឱ្យវិនិយោគិនទាំងឡាយមិនថាក្នុងស្រុក និងក្រៅស្រុកបានស្គាល់ និងមានចំណាប់អារម្មណ៍មកធ្វើការវិនិយោគ។

### ៣.២.៣. ចំពោះសេដ្ឋកិច្ច

ដូចដែលយើងបានដឹងរួចមកហើយ វិស័យមូលបត្រមិនត្រឹមតែជួយដល់វិនិយោគិន និងក្រុមហ៊ុនបោះ-ផ្សាយមូលបត្រប៉ុណ្ណោះទេ វាក៏បានជួយដល់សេដ្ឋកិច្ចរបស់ប្រទេសជាតិផងដែរ។ នៅពេលដែលវិស័យនេះមានភាពទូលំទូលាយហើយនោះ វានឹងជំរុញសេដ្ឋកិច្ចរបស់ប្រទេសនោះឱ្យកាន់តែជឿនលឿន។ ពេលក្រុមហ៊ុនរីកចំរើនក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកបន្ថែម និងចូលរួមស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាដើម។

[24] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារ ក្នុងវិស័យមូលបត្ររយៈពេល៣ឆ្នាំ២០២២-២០២៤ (ជំពូកទី២៖ សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ) ៣-៦

# ជំពូកទី ៤

# ការវិភាគ និង

# ការប្រឈមនឹងហានិភ័យ

# ជំពូកទី៤

# ការវិភាគ និងការប្រឈមនឹងហានិភ័យ

## ៤.១. វិភាគលើកត្តាមូលដ្ឋាន និងបច្ចេកទេស

ជាទូទៅការវិនិយោគតែងតែជួបនឹងរឿងហានិភ័យ ដូចនេះយើងត្រូវចេះវិភាគលើការវិនិយោគដើម្បីទទួលបានប្រាក់ចំណេញច្រើន ជៀសវាងការខាតបង់ដោយប្រការណាមួយ។ ការវិភាគដែលវិនិយោគិនត្រូវចេះមាន ២ គឺ៖ ការវិភាគលើកត្តាមូលដ្ឋាន និងការវិភាគលើកត្តាបច្ចេកទេស។

### ៤.១.១. វិភាគផ្អែកលើកកត្តាមូលដ្ឋាន

#### ៤.១.១.១. កត្តាសេដ្ឋកិច្ច

កត្តាដែលអាចមានផលប៉ះពាល់ដល់ទីផ្សារភាគហ៊ុន គឺអាចបណ្តាលមកពីសូចនាករជាច្រើនដែលមានក្នុងម៉ាក្រូសេដ្ឋកិច្ច ហេតុដូចនេះហើយយើងបានលើកយកសូចកនាសំខាន់ៗយកមកបកស្រាយ៖

- **កំណើនផលិតផលក្នុងស្រុកសរុប (GDP)**

នៅពេលដែល GDP មានកំណើនកើនឡើងនោះការចំណាយរបស់អ្នកប្រើប្រាស់ក៏កើនឡើងដែរមានន័យថាអំណាចទិញរបស់អ្នកប្រើប្រាស់កាន់តែខ្លាំងធ្វើឱ្យក្រុមហ៊ុនមានសក្តានុពលក្នុងការពង្រីក និងបង្កើនប្រាក់ចំណេញដែលអាចបង្កើនតម្លៃភាគហ៊ុន។ ការចំណាយរបស់អ្នកប្រើប្រាស់កើនឡើងនៅពេលដែលសេដ្ឋកិច្ចមានភាពរឹងមាំ ដោយសារបុគ្គលម្នាក់ៗមានអារម្មណ៍ជឿជាក់លើស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេ។ ផ្ទុយទៅវិញនៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះធ្វើឱ្យអំណាចទិញរបស់អ្នកប្រើប្រាស់មិនខ្លាំងដូចមុន នោះពួកគេនឹងជ្រើសរើសសន្សំជំនួសឱ្យការចំណាយដែលមិនសំខាន់។ ចំពោះក្រុមហ៊ុននឹងពិបាកក្នុងការពង្រីក និងបង្កើនប្រាក់ចំណូល។




ប្រភព៖ databank.worldbank.org/reports (ដកស្រង់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២)

ទិន្នន័យខាងលើបានបង្ហាញពីបម្រែបម្រួលផលិតផលក្នុងស្រុកសរុប (GDP) គិតជាដុល្លារនៅប្រទេសកម្ពុជាយើងនាចន្លោះឆ្នាំ២០១២ ដល់ឆ្នាំ២០២១។ យោងទិន្នន័យអាចឱ្យយើងដឹងថា គិតចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៩ យើងឃើញថាផលិតផលក្នុងស្រុកសរុប (GDP) មានការកើនពី ១៤ពាន់លានដុល្លារ ទៅ ២៧ពាន់លានដុល្លារ។ ចំណែកឯចាប់ពីឆ្នាំ២០១៩ ទៅឆ្នាំ២០២១ មានបម្រែបម្រួលឡើងចុះ ដូច្នេះហើយក្នុងនាមជាវិនិយោគិនអាចនឹងវិភាគបន្ថែម ឬគិតពិចារណាយ៉ាងណាដើម្បីទិញបានភាគហ៊ុនដែលល្អ។

- **អតិផរណា (Inflation)**

ដូចដែលយើងដឹងហើយថា អតិផរណាតែងតែកើតមានឡើងគ្រប់បណ្ដាប្រទេស ចំពោះប្រទេសកម្ពុជាយើងក៏មិនខុសគ្នាដែរ។ នៅពេលកើតមានអតិផរណានឹងធ្វើឱ្យផលិតផល និងសេវាកម្មផ្សេងៗមានការឡើងថ្លៃជារួមដែលបណ្ដាលឱ្យលទ្ធភាពនៃការទិញរបស់អ្នកប្រើប្រាស់តិចជាងមុន នោះអ្នកប្រើប្រាស់នឹងកាត់បន្ថយចំណាយទាំងឡាយណាដែលមិនចំបាច់សម្រាប់ពួកគេ។ ការកើនឡើងនៃថ្លៃដើមប៉ះពាល់ទៅដល់អាជីវកម្ម និងប្រាក់ចំណេញរបស់ពួកគេ ដោយសារថ្លៃដើមកាន់តែខ្ពស់។ ក្រុមហ៊ុនអាចនឹងបញ្ជូនវាទៅអ្នកប្រើប្រាស់ ឬក្រុមហ៊ុនត្រូវស្រូបយកការចំណាយទាំងនេះ កាត់បន្ថយប្រាក់ចំណេញសាជីវកម្មតាមដែរអាចធ្វើទៅបាន។ ប្រាក់ចំណូល និងប្រាក់ចំណេញទាប អាចរួមចំណែកដល់ការធ្លាក់ចុះនៃតម្លៃភាគហ៊ុន ។




ប្រភព៖ databank.worldbank.org/reports (ដកស្រង់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២)

ក្នុងទិន្នន័យនេះផងដែរបានបង្ហាញពីបម្រែបម្រួលអត្រាអតិផរណានៅប្រទេសកម្ពុជានាចន្លោះ ឆ្នាំ២០១២ ដល់ ឆ្នាំ២០២១មានសន្ទុះប្រែប្រួលឡើងចុះខ្លាំង ជាពិសេសនៅចន្លោះឆ្នាំ២០១៤ ដល់ ២០១៥។ បើយើងងាកមើលប៉ុន្មានឆ្នាំចុងក្រោយនេះពោលចាប់ពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១ ឃើញថាអត្រាអតិផរណាមានការកើនពី ១.៩៤% ទៅ ២.៩២%។ តាមទិន្នន័យទទួលបានខាងលើបានឱ្យដឹងថា អត្រាអតិផរណាជាមធ្យមគឺ ២.៧២%។

- **ភាពគ្មានការងារធ្វើ (Unemployment)**

ប្រាក់ឈ្នួលជាប្រភពចំណូលមួយរបស់អ្នកប្រើប្រាស់ទូទៅ បើប្រាក់ចំណូលតិចការចំណាយរបស់គេក៏តិចតាមនឹងដែរ។ នៅពេលដែលអត្រាគ្មានការងារធ្វើខ្ពស់ នោះការចំណាយរបស់អ្នកប្រើប្រាស់នឹងធ្លាក់ចុះ។ មូលនិធិអាចមានកម្រិត ដូច្នេះអ្នកប្រើប្រាស់នឹងចំណាយតិចជាងមុនលើវត្ថុដែលចង់បាន ហើយបែងចែកការចំណាយសម្រាប់តែធាតុសំខាន់ៗប៉ុណ្ណោះ។ ភាពគ្មានការងារធ្វើនេះអាចដាក់កម្រិតលើសមត្ថភាពរកប្រាក់ចំណូលរបស់ក្រុមហ៊ុនដែលនាំឱ្យប៉ះពាល់ដល់តម្លៃភាគហ៊ុន។




ប្រភព៖ databank.worldbank.org/reports (ដកស្រង់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២)

យោងតាមទិន្នន័យនេះបានបង្ហាញពីអត្រាគ្មានការងារធ្វើនៅប្រទេសកម្ពុជាយើង នាចន្លោះឆ្នាំ២០១២ ដល់ ឆ្នាំ២០២១។ ភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាយើងមានអត្រាខ្ពស់តាំងពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៦ ជាមួយអត្រាប្រែប្រួលចន្លោះពី ៥១% ទៅ ៧២%។ ទើបតែក្នុងឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ សេដ្ឋកិច្ចដំណើរការល្អធ្វើឱ្យអត្រាគ្មានការងារធ្វើធ្លាក់មកត្រឹម១៤% ទៅ ១៥%។

### ៤.១.១.២. កត្តាអាជីវកម្ម

វិនិយោគិនត្រូវតែសិក្សាស្វែងយល់នូវក្រុមហ៊ុនដែលខ្លួនចង់វិនិយោគ ដើម្បីដឹងពីដំណើរការរបស់ក្រុមហ៊ុនមានការគ្រប់គ្រង និងចក្ខុវិស័យរបស់ក្រុមហ៊ុននោះ។ ចំណុចទាំងនោះមានដូចជា៖

- ព័ត៌មានអំពីអាជីវកម្មចម្បងរបស់ក្រុមហ៊ុន និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់ក្រុមហ៊ុន។
- ភាពល្បីល្បាញ ឬកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន
- ប្រវត្តិនៃការវិវត្តរបស់ក្រុមហ៊ុន
- ផែនការ និងយុទ្ធសាស្ត្រអាជីវកម្មសម្រាប់អនាគតនៃក្រុមហ៊ុន

- ប្រវត្តិ និងសមត្ថភាពរបស់ស្ថាបនិក និងថ្នាក់ដឹកនាំសំខាន់ៗរបស់ក្រុមហ៊ុន
- នយោបាយគ្រប់គ្រងបុគ្គលិក (ការទំនាក់ទំនងជាមួយសហជីព)
- ប្រាក់បៀវត្ស និងប្រាក់លើកទឹកចិត្តផ្សេងៗរបស់ថ្នាក់ដឹងនាំក្រុមហ៊ុន
- គោលនយោបាយដឹកនាំក្រុមហ៊ុនរបស់អភិបាល
- នយោបាយបែងចែកភាគលាភដល់ម្ចាស់ភាគហ៊ុន។ល។

### ៤.១.១.៣. កត្តារបាយការហិរញ្ញវត្ថុ

ក្រុមហ៊ុនមានសុខភាពហិរញ្ញវត្ថុល្អ ឬមិនល្អ វិនិយោគិនក៏អាចដឹងតាមរយៈការពិនិត្យទៅលើរបាយ-ការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ តួលេខក្នុងរបាយការណ៍ហិរញ្ញវត្ថុនឹងបង្ហាញពីសុខភាពរបស់ក្រុមហ៊ុននោះ។ ការវិភាគលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of Financial Position) ជាវិធីមួយដែលវិនិយោគិននិយមប្រើ ក្នុងនោះក៏មានរបាយការណ៍ចំណូល (Income Statement) របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flow) វិនិយោគិនពឹងលើការវិភាគរបាយការណ៍ទាំង ៣ នេះដើម្បីប្រាកដថាក្រុមហ៊ុនមានសុខមាលភាពហិរញ្ញវត្ថុល្អក្នុងការធ្វើដំណើរឆ្ពោះទៅគោលដៅខាងមុខដែលបានកំណត់។

- **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of Financial Position)**

[25]របាយការណ៍ហិរញ្ញវត្ថុមានធាតុផ្សំពី៖

| ទ្រព្យសកម្ម = បំណុល + មូលធនម្ចាស់ |
|---|

វិនិយោគិនអាចពិនិត្យ និងវិភាគលើទ្រព្យសកម្ម បំណុល និងមូលធនម្ចាស់ ដើម្បីដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ វិនិយោគិនគួរពិនិត្យមើលទ្រព្យសកម្មរយៈខ្លីដូចជាគណនីអតិថិជនជំពាក់ (Account-Receivable) និងបំណុលរយៈពេលខ្លី។ គណនីទាំងនេះនឹងបង្ហាញឱ្យយើងឃើញនូវរឿងរ៉ាវមួយចំនួនដែលវិនិ-យោគិនត្រូវតែដឹងដូចជា៖

១. ថាតើក្រុមហ៊ុននៅមានអតិថិជនជំពាក់ចំនួនប៉ុន្មាន? ហើយការជំពាក់នេះអាចនឹងទទួលបានវិញទេ និងចំនួនប៉ុន្មានដែលនឹងក្លាយជាបំណុលពិបាកទារ។ ដែលវាអាចនឹងប៉ះពាល់ដល់ហិរញ្ញវត្ថុអនាគតរបស់ក្រុមហ៊ុន ។

២. ថាតើក្រុមហ៊ុនមានទំហំបំណុលធំ ឬទេ? ហើយបំណុលទាំងនោះមានប្រភពពីណាខ្លះ? តើវាជាបំណុលរយៈពេលខ្លី ឬវែង? តើក្រុមហ៊ុនមានលទ្ធភាពក្នុងការសងបំណុលទាន់កាលកំណត់ឬទេ?

[25] សាស្ត្រាចារ្យ អឿន មុនីរដ្ឋ, "គណនេយ្យមូលដ្ឋាន១", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ),១៦។

ករណីខាងលើនេះអាចនឹងកើតមានឡើង ដូចនេះវិនិយោគិនគួរគិតពិចារណាលើសំណួរខាងលើនេះដើម្បីធានាថាក្រុមហ៊ុនមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ។

- **របាយការណ៍ចំណូល (Income Statement)**

[26]ក្នុងរបាយការណ៍ចំណូលមានធាតុពីរ៖

| ចំណេញ ឬខាត = ចំណូល - ចំណាយ |
|---|

របាយការណ៍ចំណូលនឹងបង្ហាញពីប្រាក់ចំណេញ ឬខាតបន្ទាប់ពីទូទាត់នូវរាល់ចំណាយរួចរាល់ ថាតើក្រុមហ៊ុនបានបង្កើតចំណូលទេ។ ជាទូទៅក្រុមហ៊ុនមិនអាចធានាបានថានឹងចំណេញរៀងរាល់ឆ្នាំនោះទេ ប៉ុន្តែយើងអាចពិនិត្យលើរបាយការណ៍ចំណូលនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីដឹងពីការកម្រិតចំណេញ និងខាតមួយដែលអាចឱ្យយើងទទួលយកបាន។

- **របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flow)**

ក្នុងរបាយការណ៍លំហូរសាច់ប្រាក់នឹងបង្ហាញពីការហូរចេញ និងហូរចូលរបស់សាច់ប្រាក់ក្នុងខណៈពេលក្រុមហ៊ុនធ្វើអាជីវកម្ម ហើយសាច់ប្រាក់នោះជាសាច់ប្រាក់ដែលសល់ពីការទូទាត់ចំណាយរួចរាល់។ វិនិយោគិនគួរដឹងថា សាច់ប្រាក់ក្នុងធនាគាររបស់ក្រុមហ៊ុនមានគ្រប់គ្រាន់ក្នុងការទូទាត់បៀវត្សជូនទៅបុគ្គលិករបស់ខ្លួនជារៀងរាល់ខែ។ មួយវិញទៀត វិនិយោគិនផ្តោតសំខាន់លើសាច់ប្រាក់របស់ក្រុមហ៊ុនក្នុងដោះស្រាយបញ្ហាណាមួយដែលកើតឡើងជាយថាហេតុដោយប្រការណាមួយ។ បើសិនជាសាច់ប្រាក់មិនគ្រប់គ្រាន់ទេក៏ក្រុមហ៊ុនពិបាកក្នុងការអភិវឌ្ឍដែរ។

- **អនុបាត (Ratio)**

ក្រោយពីបានដឹងពីការវិភាគកត្តាខាងលើរួចមក យើងគួរក្រឡេកងាកមើលាការវិភាគតាមអនុបាតមួយទៀតដែលអាចជួយឱ្យយើងវិភាគបន្ថែមបានមួយកម្រិតទៀត។ អនុបាតជួយយើងក្នុងការប្រៀបធៀបនូវតម្លៃភាគហ៊ុនដែលល្អ និងមានតម្លៃធូថ្លៃ។ អនុបាត ២ ដែលយើងគួរតែដឹង៖

១. អនុបាត ថ្លៃ/ចំណូល (P/E Ratio)

អនុបាតនេះត្រូវបានគេនិយមប្រើ ដោយថ្លៃរបស់ភាគហ៊ុនទៅធៀបនឹងចំណូលដែលទទួលបានក្នុងមួយហ៊ុន ហើយអនុបាតដែលទទួលបាននឹងបង្ហាញថាអនុបាតដែលមានតម្លៃតូចបំផុតជាភាគហ៊ុនដែលមានតម្លៃល្អ និងអាចកើនថ្លៃនាពេលអនាគត (P ជាតម្លៃរបស់ភាគហ៊ុន និង E ជាចំណូលទទួលបានក្នុងមួយភាគហ៊ុន)។

[26] សាស្ត្រាចារ្យ អឿន មុនីរដ្ឋ, “គណនេយ្យមូលដ្ឋាន១”, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ),១៦។

២. អនុបាត ថ្លៃ/តម្លៃភាគហ៊ុន (P/B Ratio)

អនុបាតនេះគឺយក ថ្លៃរបស់ភាគហ៊ុនទៅធៀបនឹងតម្លៃចុះបញ្ជីក្នុងមួយហ៊ុន ហើយអនុបាតទទួលបាននឹងបង្ហាញពីក្រុមហ៊ុនមួយណាដែលសាកសមជាមួយនឹងតម្លៃល្អ។ អនុបាតកាន់តែតូចគឺកាន់តែល្អ។ (P ជាតម្លៃរបស់ភាគហ៊ុន និង B ជាតម្លៃចុះបញ្ជីក្នុងមួយភាគហ៊ុន)។

ព័ត៌មានទាក់ទងនឹងអនុបាតខាងលើយើងអាចរកស្វែងរកបាននៅក្នុងគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា (i.csx.com.kh) សម្រាប់វិនិយោគិនដែលមានគណនីវិនិយោគទើបអាចចូលបាន។

### ៤.១.២. វិភាគផ្អែកលើបច្ចេកទេស

ការវិភាគផ្អែកលើច្ចេកទេស គឺជាការវិភាគដោយប្រើប្រាស់វិធីសាស្ត្រគណនា ដោយផ្អែកលើទិន្នន័យស្ថិតិដែលទទួលបាន ដើម្បីធ្វើការព្យាករណ៍ពីចលនាប្រែប្រួលរបស់ភាគហ៊ុន សញ្ញាបត្រ និងមូលបត្រផ្សេងៗ។ល។ ចំណែកឯសូចនាករដែលដើរតួរសំខាន់ក្នុងការវិភាគផ្អែកលើបច្ចេកទេសនេះគឺ ថ្លៃ ហើយទិន្នន័យនេះយើងអាចរកបានយ៉ាងងាយស្រួលដែលមាននៅក្នុងទីផ្សារស្រាប់។

#### ៤.១.២.១. ទិន្នន័យទីផ្សារ

ប្រវត្តិថ្លៃអាចកើនឡើង ឬថយចុះដដែលៗជារៀងរាល់ថ្ងៃ។ ការប្រែប្រួលថ្លៃក្នុងទីផ្សារនេះអាចមានជាកត្តាអ្នកចូលរួម ហេតុនេះហើយវិនិយោគិនប្រើប្រាស់ទិន្នន័យប្រវត្តិថ្លៃយកមកព្យាករណ៍រកថ្លៃទីផ្សារនៅពេលបច្ចុប្បន្ន និងពេលខាងមុខ។ ការព្យាករណ៍បែបនេះគឺផ្តោតសំខាន់លើតួលេខដែលទទួលបានពីប្រវត្តិថ្លៃពីមុនៗមក ដើម្បីយកមកផ្ទៀងផ្ទាត់ និងវិភាគស្វែងរកកម្រិតប្រែប្រួលក្នុងការជួញដូរ។

#### ៤.១.២.២. តម្រូវការ និងផ្គត់ផ្គង់

តម្លៃរបស់ភាគហ៊ុនមានការប្រែប្រួលកើនឡើង និងថយចុះឥតឈប់ឈរដោយសារតែអ្នកទិញ និងអ្នកលក់ឱ្យតម្លៃទៅភាគហ៊ុនខុសពីគ្នា យើងអាចនិយាយបានម៉្យាងទៀតថាវាប្រែប្រួលតាមតម្រូវការ និងផ្គត់ផ្គង់។[27] តាមច្បាប់តម្រូវការ ប្រសិនបើកត្តាផ្សេងទៀតនៅថេរដដែល ហើយថ្លៃទំនិញ **ក** មួយកើនឡើងនាំឱ្យបរិមាណទំនិញ **ក** នោះថយចុះ និងច្រាសមកវិញ។ ហើយការប្រែប្រួលរបស់តម្រូវការបណ្តាលមកពីកត្តាដូចជា៖

- ចំណង់ចំណូលចិត្តរបស់អតិថិជន
- ចំណូលអតិថិជន

[27] សាស្ត្រាចារ្យ ទូន ផល្លា, "គោលការណ៍មីក្រូសេដ្ឋកិច្ច", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ១០-១១។

- ថ្លៃទំនិញដទៃទៀតអាចជំនួសបាន
- ក្តីសង្ឃឹមនាពេលអនាគត។

[28]ចំពោះច្បាប់ផ្គត់ផ្គង់វិញ ប្រសិនបើកត្តាដទៃទៀតនៅថេរដដែល ហើយថ្លៃទំនិញ **ក** មួយបានកើនឡើងនាំឱ្យអ្នកលក់ ឬអ្នកផ្គត់ផ្គង់ទំនិញ **ក** កាន់តែច្រើនថែមទៀត និងច្រាសមកវិញ។ ហើយការប្រែប្រួលរបស់ផ្គត់ផ្គង់បណ្តាលមកពីកត្តាដូចជា៖

- ថ្លៃវត្ថុធាតុដើម
- បច្ចេកវិទ្យា
- ពន្ធ និងឧបសគ្គផលិតកម្ម
- ចំនួនអ្នកផ្គត់ផ្គង់លើទីផ្សារ
- ថ្លៃទំនិញដទៃទៀត
- ក្តីសង្ឃឹមក្នុងការប្រែប្រួលថ្លៃ។

ឧទាហរណ៍៖ ចំពោះផ្សារហ៊ុន នៅពេលដែលវិនិយោគិន(ទិញ)ទទួលបានព័ត៌មានដែលគិតថានឹងភាគ-ហ៊ុនរបស់ក្រុមហ៊ុន PPAP នឹងអាចនឹងកើនឡើងថ្លៃនាពេលប៉ុន្មានសប្តាហ៍ទៀត នោះធ្វើឱ្យវិនិយោគិនដែលមានបំណងចង់ទិញភាគហ៊ុនរបស់ក្រុមហ៊ុន PPAP ដើម្បីបានចំណេញនាពេលខាងមុខធ្វើឱ្យតម្រូវការកើនឡើងខ្ពស់ជាហេតុដែលបណ្តាលឱ្យថ្លៃភាគហ៊ុនកើនឡើង។

### ៤.១.២.៣. ឧបករណ៍វិភាគទិន្នន័យផ្អែកលើបច្ចេកទេស

ក្រោយពីដឹងពីកត្តាមួយចំនួនដែលមានឥទ្ធិពលដល់ការវិភាគផ្អែកលើបច្ចេកទេសរួចមក បន្ទាប់មកយើងនឹងមកស្គាល់ឧបករណ៍វិភាគទិន្នន័យដែលគេនិយមប្រើក្នុងការព្យាករណ៍។ វិនិយោគិនប្រើការវិភាគនេះដើម្បីប្រមើលមើលឱកាសល្អក្នុងការឈានចូល ឬចាកចេញពីទីផ្សារ។ ឧបករណ៍ដែលគេប្រើក្នុងការវិភាគទិន្នន័យមានដូចជា៖

- **Trend line**

ជាការវិភាគដោយមើលលើបន្ទាត់បម្រែបម្រួលថ្លៃក្នុងទីផ្សារមានការកើនឡើង ឬថយចុះ។ បន្ទាត់ទាំងនេះផ្អែកលើការដាក់ការបញ្ជាទិញ ឬលក់ពីអ្នកចូលរួមក្នុងទីផ្សារ និងការបង្កើន ឬបន្ថយកម្រិតបញ្ឈប់ ឬកន្លែងដែលការទាញយកប្រាក់ចំណេញដែលអាចកើតមានឡើងត្រង់ចំណុចណាមួយ។ Trend line នេះមាន ៣ ប្រភេទ៖ ឡើង(Up) ចុះ(Down) និងចំហៀង(Sideways)។

[28] សាស្ត្រាចារ្យ ទូន ផល្លា, "គោលការណ៍មីក្រូសេដ្ឋកិច្ច", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ១៤-១៥។

រូបភាពទី៦៖ គំរូបន្ទាត់និន្នាការ (Trend lines)




ប្រភព៖ www.gsimarkets.com (ដកស្រង់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២)

- **Support and Resistance levels**

ជាមួយនឹងការវិភាគមួយនេះ វាបានជួយឱ្យយើងមើលដឹងពីទំនោរបស់ទីផ្សារ ថាតើវិនិយោគិនគួរឈានចូល ឬចាកចេញពីទីផ្សារ។ នៅក្នុងការវិភាគនេះគេមានបន្ទាត់ ២ គឺ៖ Support ដែលសំដៅដល់សញ្ញាណនៃការធ្លាក់ចុះ និង Resistance ដែលជាសញ្ញាណនៃការកើនឡើង។

រូបភាពទី៧៖ គំរូ Support and Resistance




ប្រភព៖ www.dailyfx.com (ដកស្រង់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២)

- **Price patterns**

វិនិយោគិនក៏អាចនឹងវិភាគប៉ាន់ស្មានថ្លៃក្នុងទីផ្សារតាមលំនាំថ្លៃបានផងដែរ វានឹងបង្ហាញពីសញ្ញាណនៃការកើនឡើង ឬថយចុះក្នុងទីផ្សារ។ សញ្ញាណទាំងនោះមានដូចជា៖

រូបភាពទី៨៖ សញ្ញាណនៃ Price patterns




ប្រភព៖ www.aimarrow.com (ដកស្រង់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២)

យ៉ាងណាមិញឧបករណ៍វិភាគទិន្នន័យខាងលើទាំងនេះក៏មិនអាចធានាបាន ១០០% ដែរថាមិនអាចមានកំហុសឆ្គង។ វាគ្រាន់តែជាការព្យាករណ៍មួយដោយប្រើប្រាស់ទិន្នន័យពីអតីតកាលតែប៉ុណ្ណោះ។

## ៤.២. បញ្ហាប្រឈម

វិនិយោគិនល្អគឺ ជាវិនិយោគិនដែលយល់ដឹងពីបញ្ហាប្រឈម ឬហានិភ័យទាំងឡាយដែលអាចកើតមានឡើង ហើយជៀសវាងហានិភ័យនោះតាមដែលអាចធ្វើទៅបាន ស្របពេលជាមួយគ្នានោះវិនិយោគិនក៏ត្រូវទទួលយកនូវកម្រិតហានិភ័យទាំងនោះផងដែរនៅពេលជួបប្រទះនឹងហានិភ័យក្នុងប្រការណាមួយ។ កត្តាដែលវិនិយោគិនអាចនឹងប្រឈមមានដូចជា៖

### ៤.២.១. ស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយ

ប្រទេសកម្ពុជាយើងជាប្រទេសកំពុងអភិវឌ្ឍ ហើយទីផ្សារមូលបត្រនៅប្រទេសកម្ពុជាមានលក្ខណៈថ្មីចំពោះប្រជាពលរដ្ឋយើង បូករួមទាំងការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត ជាហេតុដែលធ្វើឱ្យទីផ្សារមូលបត្រនៅប្រទេសកម្ពុជាមានការរីកចម្រើនយឺត។ ដោយសារហេតុនេះហើយទើបធ្វើឱ្យម្ចាស់សហគ្រាសមើលរំលងលើទីផ្សារមូលបត្រកម្ពុជា និងមិនទាន់មានភាពជឿជាក់ក្នុងការចុះបញ្ជីនៅផ្សារមូលបត្រ។ ទន្ទឹមនឹងគ្នានេះផងដែរ យើងរាល់គ្នាក៏បានដឹងហើយថាវិបត្តិជំងឺ Covid-19 បានធ្វើពិភពលោកទាំងមូលជួបប្រទះនឹងការធ្លាក់ចុះសេដ្ឋកិច្ចក្នុងអំឡុង២០២០។ ប្រទេសកម្ពុជាយើងក៏មានការធ្លាក់ចុះខ្លះដែរដោយសារការបិទប្រទេសក្នុង

ចូលរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជម្ងឺ Covid-19 ហើយវិស័យមួយចំនួនត្រូវបានផ្អាកដំណើរការស្ទើរតែទាំងស្រុង។ ដូចនេះវិនិយោគិនអាចនឹងប្រឈមនឹងវិបត្តិសេដ្ឋកិច្ចផ្សេងៗប្រសិនស្ថានភាពសេដ្ឋកិច្ចនៅតែមិនល្អបែបនេះបន្តទៀត។

### ៤.២.២. ទំហំទីផ្សារ ព័ត៌មាន និងចំណាយ

ទោះបីជាផ្សារមូលបត្រកម្ពុជាបានចាប់បដិសន្ធិនៅឆ្នាំ២០១១ ក៏ពិតមែន បើគិតមកដល់ពេលនេះវិស័យ-មូលបត្រនៅតែមិនទាន់មានប្រជាប្រិយភាពខ្លាំងគ្រប់គ្រាន់ ដែលអាចទាក់ទាញវិនិយោគិនពីគ្រប់មជ្ឈដ្ឋានឱ្យមកវិនិយោគបានឡើយ។ មួយវិញទៀត បើយើងមើលការវិនិយោគទីផ្សារបច្ចុប្បន្នមិនទាន់មានលក្ខណៈមមាញឹកខ្លាំងដូចបណ្តាប្រទេសនៅសហភាពអឺរ៉ុបទេ ជាក់ស្តែងក្នុងផ្សារមូលបត្រកម្ពុជាមានតែក្រុមហ៊ុន ៩ប៉ុណ្ណោះដែលបានចុះបញ្ជីជាមួយនឹងផ្សារមូលបត្រកម្ពុជា។ ដូច្នេះហើយ ទើបដំណើរការនៃការជួញដូរពុំសូវមានភាពងាយស្រួលសម្រាប់វិនិយោគិនក្នុងការទិញ ឬលក់ភាគហ៊ុនឡើយ។

វិនិយោគិនទោះបីជាវិនិយោគក្នុងរយៈពេលខ្លី ឬវែងក៏ដោយគប្បីតាមដានព័ត៌មានឱ្យបានខ្ជាប់ខ្ជួនជានិច្ចនូវព័ត៌មានថ្មីៗដែលពាក់ព័ន្ធ ដើម្បីសម្រេចចិត្តក្នុងលក់ចេញ ឬទិញបន្ថែមទុកចំណេញនាពេលអនាគត។ ភាគ-ច្រើនវិនិយោគិនរយៈពេលវែងតែងមានការធ្វេសប្រហែសជាមួយនឹងព័ត៌មានដែលទទួលបាន។

មួយវិញទៀត ចំណាយកម្រៃជើងសារពិតជាសំខាន់ណាស់ដែរ បើវិនិយោគិនជ្រើសរើសឈ្មួញជើងសារដែលយកកម្រៃជើងសារថ្លៃនោះផលចំណេញដែលត្រូវទទួលបាននឹងត្រូវបានកាត់បន្ថយឱ្យនៅតិចជាងមុន។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ និងឯកសារដែលទទួលបានពីប្រភពផ្សេងៗ ជាពិសេសឯកសារដែលមានពាក់ព័ន្ធនឹងការវិនិយោលើផ្សារមូលបត្រនៅប្រទេសកម្ពុជា។ វិស័យមូលបត្រនៅប្រទេសកម្ពុជាបានចាប់បើកដំណើរការឱ្យមានការជួញដូរក្នុងឆ្នាំ២០១២ រហូតមកដល់ពេលនេះមានអាយុកាលជិត ១០ឆ្នាំហើយ។ ឆ្លងតាមការសិក្សាអស់មួយរយៈនេះ ដោយសារកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត និងប្រជា-ពលរដ្ឋសក្តានុពលក្នុងទីផ្សារមូលបត្រខ្លះទៀត មិនទាន់បានត្រៀមខ្លួនរួចរាល់ក្នុងការឈានជើងចូលក្នុងផ្សារ-មូលបត្រកម្ពុជា ដោយមានភាពភ័យខ្លាចនឹងហានិភ័យក្នុងផ្សារមូលបត្រកម្ពុជា។ ផ្ទុយទៅវិញ យើងគិតថាវាឱកាសល្អទៅវិញទេក្នុងការវិនិយោគ និងឆ្លៀតពេលបានរៀនពីវាថែមទៀតផង បន្ថែមពីនេះវិនិយោគិនអាចនឹងចំណេញពីការវិនិយោគស្របពេលរដ្ឋាភិបាលកំពុងផ្តល់អត្ថប្រយោជន៍ផ្សេងៗក្នុងន័យជួយជំរុញដល់វិស័យមួយនេះ។

ទោះបីត្រឹមតែវិស័យមូលបត្រមានក្រុមហ៊ុនចុះបញ្ជីត្រឹម ៩ក្រុមហ៊ុនក៏ពិតមែន ប៉ុន្តែតាមដែលសិក្សាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានកើននូវក្រុមហ៊ុនចុះបញ្ជីចំនួន ៤បន្ថែមទៀតបើធៀបទៅនឹងប៉ុន្មានឆ្នាំមុន។ វិស័យមូល-បត្រនៅប្រទេសកម្ពុជាពិតជាមានការរីកចំរើនគួរឱ្យកត់សម្គាល់ខ្លាំងណាស់ដែរ ខណៈពេលរាជរដ្ឋាភិបានកំពុងបន្តទាក់ទាញវិនិយោគិនឱ្យចូលមកវិនិយោគក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។

ផ្អែកលើការស្រាវជ្រាវខាងលើអំពីចំណុចដំណើរការនៃផ្សារមូលបត្រកម្ពុជាយើង បានបង្ហាញឱ្យឃើញហើយថាវិនិយោគិនគ្រាន់តែអនុវត្តតាម ៣ ដំណាក់កាលៈ ១.ជ្រើសរើស Broker, ២.ស្នើសុំលេខអត្តសញ្ញាណវិនិយោគិន, ៣.បើកគណនីជួញដូរជាការស្រេចដើម្បីអាចជួញដូរលើផ្សារមូលបត្របាន ចំណែកឯដំណើរក្នុងការជួញដូរក្នុងផ្សារមូលបត្រកម្ពុជាវិញត្រូវបានពន្យល់យ៉ាងល្អិតល្អន់ដោយក្រុមហ៊ុនមូលបត្រកម្ពុជា។

ចំពោះហានិភ័យ និងបញ្ហាប្រឈមវិញជារឿងមួយដែលមិនយើងមិនអាចធានាបាន ១០០% ថានឹងគ្មានហានិភ័យនោះទេ ទោះជាយើងបើកអាជីវកម្មខ្លួនឯង ឬដាក់លុយក្នុងធនាគារក៏ដោយក៏មិនអាចធានាថាមិនជួបនឹងហានិភ័យនោះដែរ។ ការដែរប្រសើរបំផុតនោះមានតែយើងខ្លួនឯងត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តក្នុងការវិនិយោគលើអ្វីមួយ ហើយត្រូវទទួលស្គាល់នូវកម្រិតហានិភ័យណាមួយដែលខយើងអាចទទួលយកបាន។ ក្រោយពីបានសិក្សាលើប្រធានបទខាងលើនេះអស់មួយរយៈពេលកន្លងមកយើងសម្គាល់ឃើញថាហានិភ័យរបស់ផ្សារមូលបត្រកម្ពុជានៅមានកម្រិតទាបជាងបណ្តាប្រទេសដទៃឆ្ងាយណាស់ ។ ដោយសារផ្សារមូលបត្រកម្ពុជាត្រូវបានគ្រប់គ្រងដោយគណៈកម្មាការមូលបត្រកម្ពុជា។ ជាក់ស្តែកដូចកម្រិតប្រែ-ប្រួលថ្លៃប្រចាំថ្ងៃរបស់ភាគហ៊ុនអាចប្រែប្រួលបានតែក្នុងចន្លោះ បូក ឬដក ១០% ប៉ុណ្ណោះក្នុងមួយថ្ងៃ។ ម៉្យាងវិញ

ទៀត បើនិយាយពីបញ្ហាប្រឈមដែលបានលើកឡើងពីខាងលើវិញ គឺអាចនិយាយបានថាជាបញ្ហាទូទៅដែលប្រទេសណាក៏អាចនឹងជួបប្រទះដែរការសំខាន់នោះគឺសិក្សាឱ្យបានច្បាស់មុននឹងវិនិយោគលើអ្វីមួយ។

សរុបសេចក្តីជារួម ការវិនិយោគលើផ្សារមូលបត្រកម្ពុជាអាចជាឱ្យកាសមួយល្អដល់វិនិយោគិនដើម្បីទទួលបានទទួលបានផលចំណេញនាពេលអនាគត និងជាឱកាសក្នុងការរៀនសូត្របន្ថែមពីវិស័យមូលបត្រនេះដោយផ្តើមពីវិនិយោគតិចតួច។

## ២. អនុសាសន៍

ជាការពិតណាស់ផ្សារមូលបត្រកម្ពុជាមានអាយុកាលជិត ១០ឆ្នាំហើយប៉ុន្តែការរីកចំរើនរបស់ផ្សារមូល-បត្រនៅតែមិនទាន់ឈានដល់កម្រិតមួយ ដែលអាចទាក់ទាញឱ្យវិនិយោគិនសាធារណៈទូទៅមកវិនិយោគបានទូលំទូលាយនៅឡើយ ឬអាចនិយាយបានថានៅមានប្រជាពលរដ្ឋមួយចំនួនមិនទាន់ស្គាល់ច្បាស់ពីផ្សារមូល-បត្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាទាំងនេះយើងខ្ញុំសូមចូលរួមផ្តល់អនុសាសន៍មួយចំនួនដូចជា៖

- យោងក្នុងជំពូកទី៣ ទាក់ទងនឹងចំណុចការដាក់បញ្ជា CSX គួរយកចិត្តទុកដាក់បន្ថែមទៀតចំពោះប្រព័ន្ធជួញដូរចល័ត (MTS) ដោយធ្វើការអភិវឌ្ឍបន្ថែមទៀត ដើម្បីងាយស្រួលក្នុងការប្រើប្រាស់បានលើគ្រប់ឧបករណ៍ដូចជា ទូរស័ព្ទ កុំព្យូទ័រ ។ល។
- លទ្ធផលដែលទទួលពីការផ្សព្វផ្សាយនាពេលប៉ុន្មានឆ្នាំនេះឃើញថាមានប្រសិទ្ធិភាព ដូចនេះ CSX គួរធ្វើការផ្សព្វផ្សាយបន្ថែមទៀតតាមលទ្ធភាពដែលមានដើម្បីបញ្ជ្រាបវិស័យនេះទៅដល់ប្រជាជនយើង។
- CSX គួរបង្កើតកម្មវិធីអប់រំ និងការចែករំលែកពីបទពិសោធន៍របស់វិនិយោគិនផ្ទាល់ក្នុងផ្សារមូលបត្រដល់ក្រុមមនុស្សសក្តានុពលក្នុងទីផ្សារមូលបត្រ គួរតែទទួលបានការយល់ដឹងអំពីកម្រិតហានិភ័យ និងអត្ថប្រយោជន៍ទទួលបាននោះ បន្ទាប់មកធ្វើថ្លឹងថ្លែងរវាងការដាក់ប្រាក់ក្នុងធនាគារ ឬវិនិយោគផ្សេងៗដែលមាន។

# ឯកសារយោង

# ឯកសារយោង


## ឯកសារជាភាសាខ្មែរ

១. ប្រកាសស្តីពីការកំណត់កម្រៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ, លេខ០០១/១២ គ.ម.ក/ប្រ.ក, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២, ប្រការ៣។

២. ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ, លេខ០១១ គ.ម.ក, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩។

៣. ប្រកាសស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងមូលបត្រ និងសេវារក្សាទុកមូលបត្រ, លេខ០០៤ គ.ម.ក.ប្រ.ក, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។

៤. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រ, លេខ០១៧/១៧ គ.ម.ក./ប្រ.ក., ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧។

៥. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, លេខ០០៣/១៩ គ.ម.ក./ប្រ.ក., ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩។

៦. អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។

៧. គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ០០១ គ.ណ.ន., ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១២។

៨. សេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យដំណើរការ វិធិសាស្រ្តជួញដូរតាមការចរចា, បញ្ជោទីផ្សារ, និងដែនកំណត់ថ្លៃប្រចាំថ្ងៃ១០%សម្រាប់ទីផ្សារមូលបត្រកម្មសិទ្ធិ, លេខ១០៥/១៧, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧។

៩. សាស្រ្តាចារ្យ អឿន មុនីរដ្ឋ. គ្មានកាលបបរិច្ឆេទ. គណនេយ្យមូលដ្ឋាន១. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី-២. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តាសេដ្ឋកិច្ច។

១០. សាស្រ្តាចារ្យ ទួន ផល្លា. គ្មានកាលបរិច្ឆេទ. គោលការណ៍មីក្រូសេដ្ឋកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំ-ទី២. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

១១. សាស្រ្តាចារ្យ ឈាង ម៉េងហៀក គ្មានកាលបរិច្ឆេទ មូលដ្ឋានគ្រឹះវិនិយោគ. មេរៀនសម្រាប់បរិញ្ញាបត្រឆ្នាំទី៣. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

## ឯកសារជាភាសាបរទេស

១២. Dr. Prerti Singh, 2018, *“Fundamentals of Investment [មូលដ្ឋានគ្រឹះនៃវិនិយោគ]”*, first edition, Himalaya publishing house។

១៣. www.bankrate.com/banking, *biggest banks in America* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

១៤. www.nirmalbang.com/knowledge-center, *benefits of investing in stocks* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

១៥. www.serc.gov.kh/khmer/m23.p?pn=3, *អំពី ន.ម.ក.* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

១៦. http://csx.com.kh/laws/ipo/listPosts.do?MNCD=653, *អំពី ផមក* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

១៧. phsarhun.com/trade/benefits, *អត្ថប្រយោជន៍* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

១៨. www.cathaybk.com.kh/km/personal/fixed-deposit, *គណនីបញ្ញើសន្សំមានកាលកំណត់* (ចូល-ទស្សនាថ្ងៃទី១ ខែសីហា ឆ្នាំ២០២២)

១៩. databank.worldbank.org/reports.aspx, *Cambodia* (ចូលទស្សនាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២)

២០. data.worldbank.org/indicator/KH&start=2010, *Inflation, consumer prices (annual %)-Cambodia* (ចូលទស្សនាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២)

២១. Dirk Hartig, *Technical analysis,* primexbt.com/for-traders/what-is-technical-analysis/ (ចូលទស្សនាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២)

២២. CFI Team, *Technical Analysis – A Beginner's Guide,* corporatefinanceinstitute.com, (ចូលទស្សនាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២)

២៣. en.wikipedia.org/wiki/, *Macroeconomic indicators* (ចូលទស្សនាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២)

២៤. www.dailyfx.com/education/learn-technical-analysis/support-and-resistance-trading.html (ចូលទស្សនាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២)

២៥. www.aimarrow.com/technical/technical-analysis (ចូលទស្សនាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២)

២៦. www.investor.gov/introduction-investing/investingbasicsglossary, *Convertible Securities* (ចូលទស្សនាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២)

២៧. Coryanne Hicks and Debbie Carlson, *4 Things to Know About Margin Brokerage Accounts*, money.usnews.com/investing/portfolio-management/articles/-margin-accounts (ចូលទស្សនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

២៨. www.thestreet.com/dictionary/d/derivative (ចូលទស្សនាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២)

២៩. www.wallstreetmojo.com/total-return-formula/ (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២)

៣០. Cecily Gray, *Chapter 11 risk & return in capital markets*, slideplayer.com/slide/872682/ (ចូលទស្សនាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)

៣១. www.getsmarteraboutmoney.ca/invest/investing-basics/understanding-risk/types-of-investment-risk/ (ចូលទស្សនាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)

៣២. James Chen, *Investing: An Introduction*, www.investopedia.com/ask/answers, (ចូលទស្សនាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០១/១៤ គ.ម.ក/ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់តម្លៃសេវាសម្រាប់ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន នៅក្នុងវិស័យមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៨ គ.ម.ក.ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ
- យោងតាមការចាំបាច់របស់គណៈកម្មការមូលបត្រកម្ពុជា

# ស ម្រេ ច

**ប្រការ ១.-**

បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) អាចធ្វើឡើងដោយផ្ទាល់មក គ.ម.ក. ឬតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។

**ប្រការ ២.-**

បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំ ឬស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិននៅ គ.ម.ក. ទៅតាមចំនួនដូចខាងក្រោម÷

- ជាសាច់ប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះរូបវន្តបុគ្គល។
- ជាសាច់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះនីតិបុគ្គល។

លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពសម្រាប់រយៈពេល ៣ (បី) ឆ្នាំ ឬរយៈពេលតិចជាងនេះ ដោយស្របតាមសុពលភាពនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ឬសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រពាក់ព័ន្ធ។ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាពរយៈពេល ១ (មួយ) ខែ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន និងអង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២

គាត ឈន់

**កន្លែងទទួល÷**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ.......០០១..........គ.ម.ក/គ.ណ.ន.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១២

# គោលការណ៍ណែនាំ

# ស្តីពី

# ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងប្រកាសលេខ ០០៨ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) សូមចេញនូវគោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន (Investor Identification Number) ដូចខាងក្រោម៖

## ១. ការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

បុគ្គលទាំងឡាយណាដែលមានបំណងធ្វើការវិនិយោគនៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវចុះឈ្មោះនៅ **គ.ម.ក** ដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី **គ.ម.ក** មុននឹងធ្វើសកម្មភាពជួញដូរមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការចុះឈ្មោះដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនមានជម្រើសពីរគឺដាក់ពាក្យស្នើសុំមក **គ.ម.ក.** ដោយផ្ទាល់ ឬដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

## ២. ដំណើរការនៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន និងឯកសារភ្ជាប់

វិនិយោគិនដែលមានបំណងសុំលេខអត្តសញ្ញាណវិនិយោគិនត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

### ក. សម្រាប់វិនិយោគិនជារូបវន្តបុគ្គល

វិនិយោគិនជារូបវន្តបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវ៖

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
E-mail : info@secc.gov.kh

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ក**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។
  - លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ។
  - ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

### ខ. សម្រាប់វិនិយោគិនជានីតិបុគ្គល

វិនិយោគិនជានីតិបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវ:

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ខ**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាបណ្ណធ្វើអាជីវកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។
  - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន។
  - ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវរបស់អភិបាលនីមួយៗ។
  - លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
  - បញ្ជីឈ្មោះអ្នកដែលមានសិទ្ធិ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ។

<u>**បញ្ជាក់:**</u> ករណីវិនិយោគិនដាក់ពាក្យស្នើសុំមក **គ.ម.ក.** ដោយផ្ទាល់ វិនិយោគិនត្រូវផ្តល់នូវពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ព្រមទាំងឯកសារភ្ជាប់ដែលមានភាពត្រឹមត្រូវមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

ករណីវិនិយោគិនដាក់ពាក្យស្នើសុំ តាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** ក្រុមហ៊ុនមូលបត្រត្រូវពិនិត្យពីភាពត្រឹមត្រូវ និងទទួលខុសត្រូវលើព័ត៌មានរបស់វិនិយោគិន មុនបញ្ជូនឯកសារទាំងនោះមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

**៣. ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន**

បន្ទាប់ពីវិនិយោគិនបានបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនត្រឹមត្រូវតាមការណែនាំខាងលើ និងបានផ្តល់ជូនឯកសារភ្ជាប់ត្រឹមត្រូវ និងគ្រប់គ្រាន់មក **គ.ម.ក.** **គ.ម.ក.** នឹងផ្តល់ជូនលេខអត្តសញ្ញាណវិនិយោគិន ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រក្នុងរយៈពេល ០២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់អេឡិចត្រូនិច (Soft copy) ឬរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់បោះពុម្ព (Hard copy) ។ វិនិយោគិនមួយទទួលបានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។

**គណៈកម្មការមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:....០១២.............គ ម ក

# ប្រកាស

# ស្តីពី

# ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និង ប្រតិបត្តិករក្សាទុកមូលបត្រ

*****

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ នីតិវិធីដើម្បីផ្តល់ការអនុញ្ញាតឱ្យបុគ្គលធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ និងកំណត់អំពីកាតព្វកិច្ចរបស់រាល់ប្រតិបត្តិករ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-ប្រព័ន្ធផាត់ទាត់និងទូទាត់ (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញ ទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ ប្រព័ន្ធផាត់ទាត់និងទូទាត់ រួមមាន ៖

ហិរញ្ញប្បទានភាវរកម្ម ឬការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់។

## ជំពូកទី ៣
## ការផ្តល់ការអនុញ្ញាត

### ប្រការ ១១.-

បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមគ្រប់លក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ បទប្បញ្ញត្តិជាធរមាននិងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ **គ.ម.ក.** ត្រូវពិនិត្យនិងសម្រេចលើការស្នើសុំនោះ។ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ការអនុញ្ញាត ឬជូនដំណឹងអំពីការបដិសេធ ដល់បុគ្គលដាក់ពាក្យស្នើសុំតាមការសម្រេចរបស់ **គ.ម.ក.**។ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំកែប្រែ ឬផ្តល់ព័ត៌មានបន្ថែម នោះលក្ខខណ្ឌពេលវេលាក្នុងការពិនិត្យនិងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

### ប្រការ ១២.-

សុពលភាពនៃការអនុញ្ញាតមានរយៈពេលមិនកំណត់។

### ប្រការ ១៣.-

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០.០០០.០០០ (ដប់លាន) រៀល នៅពេលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករនីមួយៗ។ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

បុគ្គលដែលទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ

ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់ប្រតិបត្តិករនីមួយៗ។ សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាត ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតនៅពេលទទួលបានការអនុញ្ញាត។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ យ៉ាងយូរនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធចាស់។

## ជំពូកទី ៤

## ភារកិច្ចរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

**ប្រការ ១៤.-**

បន្ទាប់ពីទទួលបានការអនុញ្ញាត ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលប្រតិបត្តិករបានទទួលការអនុញ្ញាត។

**ប្រការ ១៥.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រត្រូវ ៖

១-ធ្វើប្រតិបត្តិការរបស់ខ្លួនឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់រាល់ហានិភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៣-បំពេញឱ្យអស់ពីសមត្ថភាពនូវភារកិច្ច ដែលមានចែងនៅក្នុងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិនានា ដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។

៤-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការរបស់ខ្លួន និងបទប្បញ្ញត្តិជាធរមាន ដែលកំណត់ដោយ **គ.ម.ក.** ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន និងប្រាកដថាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។

**ប្រការ ១៦.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវធានាឱ្យបាននូវនិរន្តរភាពនៃដំណើរការទីផ្សារមូល-បត្រ និងបំពេញនូវកាតព្វកិច្ចជូនដំណឹង ផ្តល់ព័ត៌មាន និងរក្សាទុកនូវឯកសារ ដូចដែលមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យ។

**ប្រការ ១៧.-**

អនុលោមតាមមាត្រា ២៧ នៃអនុក្រឹត្យ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវផ្តល់របាយការណ៍ដែលធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មដែលធ្វើអាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៨.-**

ក្រៅពីកាតព្វកិច្ចផ្តល់របាយការណ៍ដូចមានចែងក្នុងជំពូកទី៣នៃអនុក្រឹត្យ ប្រតិបត្តិ-ករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ផ្សេងទៀត តាមការកំណត់របស់ **គ.ម.ក.**។

**ប្រការ ១៩.-**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវប្រព្រឹត្តអាកប្បកិរិយាដែលត្រូវបានហាមឃាត់ដូចមានចែងក្នុងជំពូកទី៧ នៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ២០.-**

អភិបាលរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូល-បត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រទាំងឡាយណាដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាព ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការធ្វើសេចក្តីសម្រេចណាមួយ ឬក្នុងការអនុម័តកិច្ចសន្យាណាមួយដែលធ្វើឡើងដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រកាសព័ត៌មាននេះឱ្យបានទូលំទូលាយ ដល់សមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សា-ភិបាល តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយសមស្របមុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលនឹងសម្រេចទាក់ទងនឹងបញ្ហានោះ។ អភិបាលដែលមានផល-ប្រយោជន៍ពាក់ព័ន្ធដូចដែលបានរៀបរាប់នេះ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំ

ក្រុមប្រឹក្សាភិបាល និងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចឬក្នុងការអនុម័តកិច្ចសន្យានោះឡើយ។

**ប្រការ ២១.-**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ សហព័ទ្ធ បុព្វញាតិ ឬបច្ឆាញាតិរបស់ខ្លួនគិតត្រឹមថ្នាក់ទី៣ មិនត្រូវទទួលអំណោយឬផលប្រយោជន៍តាមគ្រប់រូបភាពពីបុគ្គលដែលខ្លួនមានទំនាក់ទំនងអាជីវកម្មឬហិរញ្ញវត្ថុជាមួយ នៅក្នុងការបំពេញមុខងារនិងតួនាទីរបស់ខ្លួន។

**ប្រការ ២២.-**

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបង្កើតឱ្យមានមូលនិធិធានាការទូទាត់សងមួយដាច់ដោយឡែក ដើម្បីធានាការទូទាត់សងនូវរាល់ប្រតិបត្តិការទូទាត់មិនបានសម្រេច។ នីតិវិធីនៃការបង្កើត ការកំណត់ចំនួនទឹកប្រាក់ ការថែរក្សា និងការចាត់ចែងប្រើប្រាស់មូលនិធិនេះត្រូវកំណត់ដោយ **គ.ម.ក.**។

**ប្រការ ២៣.-**

មុននឹងតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ណាមួយ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

ប្រសិនបើតំណែងរបស់បុគ្គលិកជាន់ខ្ពស់ណាមួយនៅទំនេរ ប្រតិបត្តិករត្រូវតែជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវឆ្លើយតបទៅនឹងសំណើសុំតែងតាំងបុគ្គលិកជាន់ខ្ពស់នៃប្រតិបត្តិករក្នុងរយៈពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។ ករណីហួសរយៈពេលកំណត់នេះ សំណើសុំតែងតាំងត្រូវសន្មតថាបានទទួលការយល់ព្រម។

**ប្រការ ២៤.-**

អនុលោមតាមមាត្រា ២៧ នៃច្បាប់ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដឹកនាំកែតម្រង់ ដាក់លក្ខខណ្ឌ ឬដាក់កំហិតបន្ថែម ព្យួរ ឬដកហូតការអនុញ្ញាត ក្នុងករណីដែលប្រតិបត្តិករ ៖

# ជំពូកទី ៦

# អវសានប្បញ្ញត្តិ

**ប្រការ ២៧.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹងនិងការអនុវត្ត តាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៩.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា និងសមាជិក **គ.ម.ក.**
- ដូចប្រការ ២៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០១៧/១៧ គ.ម.ក. /ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ, ប្រកាសលេខ ០០១/១៣ គ.ម.ក.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រកាសលេខ ០០៥/១៤ គ.ម.ក.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងប្រការ១ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែកត្តិក ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ១០ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ ០២៣/១៧**
**ចុះថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១៧**

# ស្ដីពី
# វិធានប្រតិបត្តិការទីផ្សារមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

វិធាននេះមានគោលបំណងកំណត់ពីវិធីសាស្ត្រ យន្តការ នីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

**- សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ របស់ **ផ.ម.ក.** និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ **ផ.ម.ក.**។

- **បញ្ជា** សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃជួញដូរ** សំដៅដល់ថ្ងៃដែលទទួលបានពីការផ្គូផ្គងបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃចុងក្រោយ** សំដៅដល់ថ្ងៃជួញដូរចុងក្រោយ ឬថ្ងៃមូលដ្ឋាន ករណីគ្មានថ្ងៃជួញដូរនៅថ្ងៃជួញដូរនីមួយៗ។

ម៉ោងជួញដូរចាប់ផ្ដើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ១១:៣០នាទី ព្រឹក ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម÷

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:០០ - ៩:០០ | ៩:០០ | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ - ១១:០០ | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១១:០០ - ១១:៣០ | ១១:៣០ | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្ដើមពីម៉ោង ៩:០០នាទី ព្រឹកដល់ម៉ោង ១១:៣០នាទី ព្រឹក។

## ជំពូកទី ២

## លក្ខខណ្ឌនៃការជួញដូរមូលបត្រកម្មសិទ្ធិ

### ប្រការ ១៥.- ឯកតាបញ្ជា បញ្ជាអប្បបរមា និងឯកតាគម្លាតថ្លៃ

ឯកតាបញ្ជាគឺ ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រដេញថ្លៃ ឯកតាគម្លាតថ្លៃត្រូវកំណត់ដូចខាងក្រោម÷

១- ១០ (ដប់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៤.០០០ (បួនពាន់)រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

២- ២០ (ម្ភៃ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤.០០០ (បួនពាន់) រៀល ប៉ុន្តែទាបជាង ២០.០០០(ពីរម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៣- ៥០ (ហាសិប) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០.០០០ (ពីរម៉ឺន) រៀល ប៉ុន្តែទាបជាង ៤០.០០០(បួនម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៤- ១០០ (មួយរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ៤០.០០០ (បួនម៉ឺន) រៀល ប៉ុន្តែទាបជាង ១០០.០០០(មួយសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៥- ២០០ (ពីររយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ១០០.០០០ (មួយសែន) រៀល ប៉ុន្តែទាបជាង ២០០.០០០(ពីរសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៦- ៥០០ (ប្រាំរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ២០០.០០០ (ពីរសែន) រៀល ប៉ុន្តែទាបជាង ៤០០.០០០(បួនសែន) រៀល ក្នុង ១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៧- ១.០០០ (មួយពាន់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រជួញដូរតាមការចរចា បញ្ជាអប្បបរមាគឺ ៥០.០០០ (ប្រាំម៉ឺន) ឯកតាមូលបត្រកម្មសិទ្ធិ ឬ២០០.០០០.០០០ (ពីររយលាន) រៀល យកមួយណាដែលតូចជាង ហើយឯកតាគម្លាតថ្លៃ គឺ ១(មួយ)រៀល។

### ប្រការ ១៦.- ថ្លៃមូលដ្ឋាន

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រចុះបញ្ជីលក់លើកដំបូង សំដៅដល់ថ្លៃជួញដូរដំបូងដែលត្រូវបានកំណត់នៅចន្លោះពី ៩០% (កៅសិបភាគរយ) ទៅ ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

ថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ ត្រូវកំណត់ដូចខាងក្រោមលើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយ **គ.ម.ក.**÷

១-ក្រៅពីថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិដូចមានក្នុងចំនុច ២ ដល់ ៤ ខាងក្រោម ថ្លៃមូលដ្ឋាននៃមូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

២-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលបានចែកភាគលាភជាមូលបត្រកម្មសិទ្ធិ ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

| |
|---|
| **ចំណាំ**÷មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ = ថ្លៃបិទ x ចំនួនមូលបត្រកម្ម-សិទ្ធិមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

៣-ក្នុងករណីមានការបង្កើនដើមទុនតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| [មូលធនូបនីយកម្មទីផ្សារមុនបង្កើនដើមទុន + (ថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ x ចំនួនមូលបត្រកម្ម-សិទ្ធិដែលបានបោះផ្សាយលក់បន្ថែម)] / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបង្កើនដើមទុន |

៤-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលមានការបម្លែង (ការបំបែក ការបង្រួម ឬកាត់បន្ថយដើមទុនមូលបត្រកម្មសិទ្ធិ) ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| ថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ x អនុបាតបម្លែង (Split Ratio) (អនុបាតបម្លែង = ចំនួនមូលបត្រកម្មសិទ្ធិមុនបម្លែង / ចំនួនមូលបត្រកម្មសិទ្ធិក្រោយបម្លែង) |

ក្នុងករណីថ្លៃមូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវកំណត់ស្មើនឹងឯកតាគម្លាតថ្លៃ។

**ប្រការ ១៧.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ**

ដែនកំណត់ថ្លៃប្រចាំថ្ងៃ សម្រាប់មូលបត្រកម្មសិទ្ធិជួញដូរតាមវិធីសាស្ត្រដេញថ្លៃ ត្រូវស្មើនឹងថ្លៃមូលដ្ឋាន ±១០%(បូកឬដកដប់ភាគរយ) ដោយតម្លៃ ១០% នៃថ្លៃមូលដ្ឋានត្រូវបង្គត់ចុះតាមឯកតាគម្លាតថ្លៃមុននឹងយកទៅបូកឬដកថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០ (មួយរយ) រៀល ដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់ នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ **គ.ម.ក.** **ផ.ម.ក.** អាចកំណត់យកដែនកំណត់ថ្លៃប្រចាំថ្ងៃផ្សេងពីនេះក្នុងករណីដូចខាងក្រោម÷

១-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ។

២-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣-ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់ថ្លៃប្រចាំថ្ងៃ។

ដែនកំណត់ថ្លៃប្រចាំថ្ងៃ មិនត្រូវអនុវត្តចំពោះវិធីសាស្ត្រជួញដូរតាមការចរចា។

**ប្រការ ១៨.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ**

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ ផ.ម.ក. ឬកំហុសរបស់សមាជិក។

ផ.ម.ក. ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ ផ.ម.ក.÷ ក្នុងករណីនេះ ផ.ម.ក. ត្រូវធ្វើការកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់ដែលបណ្តាលមកពីការកែតម្រូវនេះ ផ.ម.ក. ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវធ្វើការកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែលបញ្ជាក់ពីមូលហេតុ ឬឯកសារភស្តុតាង ផ្ញើជូន ផ.ម.ក. ឱ្យបានមុនម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់នៃថ្ងៃជួញដូរបន្ទាប់។

## ជំពូកទី ៣
## លក្ខខណ្ឌនៃការជួញដូរមូលបត្របំណុល

### ប្រការ ១៩.- វិធីសាស្ត្រកំណត់ថ្លៃជួញដូរមូលបត្របំណុល

ថ្លៃជួញដូរមូលបត្របំណុលត្រូវកំណត់តាមវិធីសាស្ត្រដេញថ្លៃ និងវិធីសាស្ត្រជួញដូរតាមការចរចាដូចមានចែងក្នុងជំពូកទី១នៃវិធាននេះ លើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ ថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គងខ្ពស់បំផុតនិងថ្លៃផ្គូផ្គងទាបបំផុត។ ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ ថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

### ប្រការ ២០.- ឯកតាបញ្ជា បញ្ជាអតិបរមា ឯកតាគម្លាតថ្លៃ និងថ្លៃបញ្ជា

ឯកតាបញ្ជានៃមូលបត្របំណុលគឺ ១ (មួយ) ឯកតាមូលបត្របំណុល។

បញ្ជាអតិបរមាសម្រាប់ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃគឺ ១០.០០០ (មួយម៉ឺន) ឯកតាមូលបត្របំណុល។

ឯកតាគម្លាតថ្លៃគឺ ១ (មួយ) រៀល។

សម្រាប់ការជួញដូរមូលបត្របំណុល ថ្លៃបញ្ជា និងថ្លៃជួញដូរគឺជាថ្លៃដុល។

### ប្រការ ២១.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវអនុវត្តចំពោះការជួញដូរមូលបត្របំណុល។

## ជំពូកទី ៤
## ការគ្រប់គ្រងទីផ្សារ

### ប្រការ ២២.- ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

ផ.ម.ក. ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម÷

១-ថ្ងៃបើក និង ថ្ងៃបិទ។

២-បរិមាណ និង តម្លៃសរុបនៃការជួញដូរ។

៣-ថ្ងៃរំពឹងទុក និង បរិមាណរំពឹងទុក។

ផ.ម.ក. អាចធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការសម្រេចចិត្តវិនិយោគ ដើម្បីការពារផលប្រយោជន៍វិនិយោគិន។

### ប្រការ ២៣.- ព័ត៌មានដែលត្រូវជូនដំណឹងទៅសមាជិក

ផ.ម.ក. ត្រូវជូនដំណឹងទៅសមាជិករបស់ខ្លួននូវព័ត៌មាននីមួយៗដូចខាងក្រោម÷

១-វិធានប្រតិបត្តិការរបស់ ផ.ម.ក. និងវិសោធនកម្មដែលអាចកើតមាន។

២-មូលបត្រចុះបញ្ជីលក់លើកដំបូង មូលបត្រចុះបញ្ជីលក់បន្ថែម មូលបត្រដកចេញពីការចុះបញ្ជីលក់ និងមូលបត្រដែលត្រូវបានព្យួរការជួញដូរ។

៣-ការបិទទីផ្សារជាបណ្ដោះអាសន្ន ការផ្អាកដំណើរការទីផ្សារ និងការផ្លាស់ប្ដូរម៉ោងជួញដូរ។

៤-សមាជិកដែលត្រូវបានអនុញ្ញាត ឬសមាជិកដែលបានដកខ្លួនពីសមាជិកភាព ឬត្រូវបានដកចេញពីសមាជិកភាព។

៥-សមាជិកដែលត្រូវបានព្យួរពីការជួញដូរ និងការអនុញ្ញាតឱ្យជួញដូរឡើងវិញ។

៦-ព័ត៌មានលម្អិតនៃការជួញដូរ រួមមាន÷ ឈ្មោះមូលបត្រ បរិមាណនិងថ្លៃជួញដូរ ប្រភេទបញ្ជាទិញ ឬលក់ប្រតិបត្តិការសម្រាប់គណនីសមាជិក ឬគណនីអតិថិជន។

ផ.ម.ក. ត្រូវរក្សាទុករាល់ព័ត៌មានទាក់ទងនឹងបញ្ហា ការកែតម្រូវកំហុសប្រតិបត្តិការ និងព័ត៌មានលម្អិតលើការជួញដូរសម្រាប់រយៈពេល ១០(ដប់) ឆ្នាំ។

### ប្រការ ២៤.- ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់សមាជិក

សមាជិកទាំងអស់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ និងវិធាននេះ។

**ប្រការ ២៥.- កាលបរិច្ឆេទអិចឌីវីដឺនដ៍ ឬអិចរាយថ៍**

កាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) គឺកាលបរិច្ឆេទជួញដូរនៅរយៈកាល ១ (មួយ) ថ្ងៃ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ (Record Date)។

**ប្រការ ២៦.- អ្នកតំណាងនៅក្នុងទីផ្សារ**

សមាជិកនីមួយៗត្រូវតែងតាំងអ្នកតំណាងនៅក្នុងទីផ្សារយ៉ាងហោចណាស់ ១ (មួយ) រូប ដែលនឹងត្រូវបណ្តុះបណ្តាលដោយ **ផ.ម.ក.** ដើម្បីប្រើប្រាស់ប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដែលរៀបចំសម្រាប់សមាជិក។ **ផ.ម.ក.** អាចតម្រូវឱ្យអ្នកតំណាងនោះ មកធ្វើការនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.** ក្នុងករណីចាំបាច់។

សមាជិកនីមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកតំណាងនៅក្នុងទីផ្សាររបស់ខ្លួននៅ **ផ.ម.ក.**។ មានតែអ្នកតំណាងនៅក្នុងទីផ្សារទេ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិកដែលស្ថិតនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.**។

**ប្រការ ២៧.- ថ្លៃសេវាជួញដូរមូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាប្រាក់ថ្លៃសេវាជួញដូរ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ត្រូវបានកំណត់ដូចខាងក្រោម÷

១-អត្រា÷ ប្រាក់ថ្លៃសេវាសម្រាប់ជួញដូរមូលបត្រ ត្រូវគណនាលើទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ (ប្រាក់ថ្លៃសេវាដែលគណនាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ៧,៥/១០.០០០ ឬ ០,០៧៥ % (សូន្យក្បៀសសូន្យចិតសិបប្រាំភាគរយ) សម្រាប់មូលបត្រកម្មសិទ្ធិ និងតាមអត្រា ២,៥/១០.០០០ ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) សម្រាប់មូលបត្របំណុល។

២-អ្នកត្រូវបង់ប្រាក់÷ ក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ **ផ.ម.ក.**។

៣-ពេលវេលាបង់ប្រាក់÷ ម៉ោង ៨:៣០នាទី ព្រឹក នៃកាលបរិច្ឆេទទូទាត់។

## ជំពូកទី ៥
## ការតាមដានការជួញដូរមូលបត្រ

**ប្រការ ២៨.- យន្តការបង្ការរបស់ ផ.ម.ក.**

ដើម្បីធានាបាននូវបរិស្ថានជួញដូរដែលមានយុត្តិធម៌ និងការពារវិនិយោគិន **ផ.ម.ក.** អាចដាក់ចេញនូវយន្តការបង្ការមួយចំនួនដើម្បីទប់ស្កាត់ការជួញដូរមូលបត្រមិនស្មោះត្រង់ ឬមិនប្រក្រតី។

**ប្រការ ២៩.- ការឃ្លាំមើលទីផ្សារ**

**ផ.ម.ក.** ធ្វើការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ដោយប្រើប្រាស់នូវព័ត៌មានមួយចំនួនដូចជា របៀបនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំនៃការជួញដូរ ព្រមទាំងកម្រិតនៃទំនាក់ទំនងរវាងថ្លៃទីផ្សារនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។

* * *

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ..០០៣/..១៩....គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៤ ថ្មី និងប្រការ១៨ ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៤ និងប្រការ១៨ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  “ដើម្បីជូនជ្រាប”
- ដូចប្រការ ២
  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ០០៣/១៩/ន.ម.ក.**
**ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៩**

**ស្តីពី**

**ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ**
**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

### ប្រការ១៤ ថ្មី.- ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការងារ។

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ១៥:០០នាទី រសៀល ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម÷

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:០០ ព្រឹក - ៩:០០ ព្រឹក | ៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ ព្រឹក - ១៤:៥០ រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១៤:៥០ រសៀល - ១៥:០០ រសៀល | ១៥:០០ រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៩:០០នាទី ព្រឹក ដល់ម៉ោង ១៥:០០នាទី រសៀល។

### ប្រការ១៨ ថ្មី.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.**÷ ក្នុងករណីនេះ **ផ.ម.ក.** ត្រូវកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់បណ្ដាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងដែលបញ្ជាក់ពីមូលហេតុ ឬឯកសារភស្ដុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ១៥:៣០នាទីរសៀលនៃថ្ងៃជួញដូរបន្ទាប់។

*  *  *

# ឧបសម្ព័ន្ធទី៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា២.- វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១.ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (សរសេរកាត់ថា **ន.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២.មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ។

៣.អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬ ទិញ- លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជននិងអនិវាសនជន។

## ជំពូកទី២

## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៣.- ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **គ.ម.ក.** នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្ដើមពី÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣- អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.- លក្ខខណ្ឌដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោម÷

១- ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ នឹងទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់។

២-ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០(ម្ភៃ) ភាគរយ ឬតិចជាង នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០(ម្ភៃ) ភាគរយ ឬ តិចជាងនៃទ្រព្យសកម្មសរុបនឹងទទួលបាននូវការលើកទឹកចិត្តពន្ធតាមសមាមាត្រចុះដោយយក ២០,០០១ ជាគោល (ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ) ដែលក្នុងនោះ÷

- ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ២០(ម្ភៃ) ប៊ីលានរៀល។

- ការបោះផ្សាយមូលបត្របំណុល÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨(ប្រាំបី) ប៊ីលានរៀល។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈ ដើម្បីទទួលបានហិរញ្ញប្បទានក្នុងគោលដៅនៃការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ឬការអភិវឌ្ឍក្នុងវិស័យអាទិភាពណាមួយ នឹងទទួលបានការលើកទឹកចិត្តពន្ធដារពិសេសបន្ថែម តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.- ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១-បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-3 ដល់ N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២-បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។(ឆ្នាំN គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈត្រូវផ្តល់ជូន **ន.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញ

ដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.-ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬ ភាគលាភដែលបានមកពីការកាន់កាប់ និង/ឬ ការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលសម្រាប់រយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬ ភាគលាភត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០(ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ការកំណត់អត្រាពន្ធលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.- ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា៣ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់-គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-ការបញ្ឈប់ និងការដកហូតការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **ន.ម.ក.** ដើម្បីបញ្ឈប់ និងដកហូតការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។
- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមានតារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។

- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

- អគ្គនាយកដ្ឋានពន្ធដាររកឃើញថាក្រុមហ៊ុន/សហគ្រាសមានចេតនាគេចវេះពន្ធ តាមរយៈការបោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ។

ក្នុងករណីក្រុមហ៊ុន/សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **ន.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតមិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/-សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជី ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៩.- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច**

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-ការជំនួស**

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រនឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអាសាឍ ឆ្នាំម្សាញ់ ត្រីស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ